# មជ្ឈមណ្ឌលឯកសារកម្ពុជា

## *សម្ភាសជាមួយ ឆាន មាំរាំឌី ភេទប្រុស អាយុ៤៣ឆ្នាំ*
## *នៅភូមិត្រពាំងកែស ឃុំត្រាំកក់ ស្រុកត្រាំកក់ ខេត្តតាកែវ*
## *ថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ ២០០៤*
## *សម្ភាសដោយៈ ជួង សុភារិទ្ធ*

*ភារិទ្ធៈ ខាងខ្ញុំហ្នឹងមកពីខាងមជ្ឈមណ្ឌលឯកសារកម្ពុជា ហើយអើខាងខាងមជ្ឈមណ្ឌលឯកសារកម្ពុជាហ្នឹង ខ្ញុំចង់ជំរាបបងម្ដងទៀត គឺមានគោលបំណងធំៗពីរ គឺទី១ ប្រមូលចងក្រងនិងរក្សាទុកនូវប្រវត្តិសាស្ត្រកាលពីជំនាន់ប៉ុល ពតហ្នឹងដើម្បីទុកអោយក្មេងជំនាន់ក្រោយបានដឹងបានលឺ ហើយទីពីរ ការសួរនាំអញ្ចឹង ពត៌មានដែលទទួលបានហ្នឹង វាអាចជាភស្តុតាងខាងផ្លូវច្បាប់នៅពេលដែលមានតុលាការកាត់ទោសខ្មែរក្រហមខាងមុខហ្នឹងអា៎ ហើយខ្ញុំចុះមកហ្នឹង តាមរយៈគំរោងមួយដែលគេហៅថា ជួយជនរងគ្រោះដោយអំពើទារុណកម្ម ហើយចង់ជួបអ្នកដែលគេធ្លាប់ជាប់ឃុំ ឃាំង គេធ្វើបាប គេវាយដំអី ជំនាន់អើ ខ្មែរក្រហមហ្នឹង ចង់ដឹង ថារឿងរ៉ាវវាយ៉ាងម៉េច ហើយ ដូចថាពេលដែលគាត់បានឆ្លងកាត់អញ្ចឹងទៅតើវាមាន សព្វថ្ងៃហ្នឹងវាមានការប៉ះទង្គិចផ្លូវចិត្តដែររឺអត់ ប៉ុន្តែដូចខ្ញុំជំរាបបងម្ដងមិញដែរថាអ្នកដែលបើសិនជាមើលទៅ បងមិនមែនជាអ្នកគេរងគ្រោះវាយដំអីទេ អញ្ចឹងការដែលរកអ្នកគេឃុំឃាំងហើយវាយដំ ជំនាន់ខ្មែរក្រហមវាមិនងាយនឹងរកបាន ព្រោះដែលជាប់ហើយ ភាគច្រើនស្លាប់ ហើយអ្នកដែលរួចខ្លួនមកដល់សព្វថ្ងៃនេះវាមានតិចតួច អញ្ចឹងខ្ញុំក៏ស្វែងរកអ្នកដែលមានសាច់ញាត់ ប្ដី អី គេយកទៅសម្លាប់ហ្នឹងចង់ដឹងពេលដែលមានរឿងរ៉ាវអញ្ចឹងកើតមានចំពោះគាត់ អារម្មណ៍ប៉ះទង្គិចផ្លូវចិត្តសព្វថ្ងៃហ្នឹងមានរឺអត់ ដោយសារតែបងមានឪពុកគេយកទៅសម្លាប់នៅក្រាំងតាចាន់ហ្នឹង ខ្ញុំចង់ដឹងពីប្រវត្តិសាច់រឿងរបស់ឪពុកបងគេយកទៅសម្លាប់ហ្នឹងវាយ៉ាងម៉េច ហើយចង់ដឹងពីអារម្មណ៍របស់បងសព្វថ្ងៃ ហើយការយល់ឃើញរបស់បងយ៉ាងម៉េចអា៎ ហើយអញ្ចឹងដំបូង ខ្ញុំចង់ស្គាល់ឈ្មោះរបស់បងសិន បើសិនជាបងអត់មានសំនួរអីត្រូវសួរនាំរីក៏ឆ្ងល់អីទេ*

ភ៉ឌី:  ខ្ញុំដូចអត់មានឆ្ងល់ទេ គ្រាន់តែនឹកគិតថាខ្ញុំគ្រាន់តែមានគំនិតមួយបំភ្លឺខ្លះនៅក្នុងរបបខ្មែរក្រហម ដែលខ្ញុំបានឆ្លងកាត់ ការធ្វើទារុណកម្ម ក៏ដូចជាការធ្វើបាបមនុស្ស និយាយរួមការធ្វើបាបខ្មែរគ្នាឯង វាហាក់ដូចជាអយុត្តិធម៌ខ្លាំងដែរ វាមានសកម្មភាពខ្លាំងដែលយើងមិនអាចថា គួរអោយអត់អោនបានអាំ

ភារិទ្ធៈ អញ្ចឹងបងឈ្មោះអីដែរ?

ភ៉ឌី:  បាទ ខ្ញុំឈ្មោះផាន ម៉ាភ៉ឌី

ភារិទ្ធៈ ហើយអើសព្វថ្ងៃបងអាយុប៉ុន្មានហើយ?

ភ៉ឌី:  សព្វថ្ងៃខ្ញុំអាយុ៤៣ឆ្នាំហើយ

ភារិទ្ធៈ ៤៣ឆ្នាំ

ភ៉ឌី:  បាទ

ភារិទ្ធៈ ហើយបងមានស្រុកកំណើតកើតជានៅឯណាដែរ?

ភ៉ឌី:  ខ្ញុំមានស្រុកកើតនៅភូមិតាតៃ ឃុំ ញ៉ែងញ៉ង ស្រុកត្រាំកក់ ខេត្តតាកែវយើងហ្នឹង

ភារិទ្ធៈ ភូមិតាតៃ ឃុំញ៉ែងញ៉ង

ភ៉ឌី:  បាទ បាទ

ភារិទ្ធៈ ហើយចុះទីលំនៅសព្វថ្ងៃដែលបងរស់នៅសព្វថ្ងៃហ្នឹងគេហៅភូមិអី?

ភ៉ឌី:  ទីលំនៅសព្វថ្ងៃ គឺ ភូមិត្រពាំងកែស ឃុំត្រាំកក់ ស្រុកត្រាំកក់ ខេត្តតាកែវ

ភារិទ្ធៈ ហើយរាល់ថ្ងៃបងប្រកបរបរអីដែរ?

ភ៉ឌី:  ខ្ញុំរាល់ថ្ងៃជាមន្ត្រីរាជការ

ភារិទ្ធៈ ហើយបងរៀបការឆ្នាំណាដែរ?

ភ៉ឌី:  ខ្ញុំរៀបការឆ្នាំ១៩៨៦

ភារិទ្ធៈ ហើយប្រពន្ធឈ្មោះអីដែរ?

ភ៉ឌី:  ប្រពន្ធឈ្មោះ នាក់ ប៊ុនណា

ភារិទ្ធៈ នាក់ ប៊ុនណា

ភ៉ឌី:  បាទ

ភារិទ្ធៈ សព្វថ្ងៃ គាត់អាយុប៉ុន្មានដែរ?

ភ៉ឌី: សព្វថ្ងៃគាត់ អាយុ៣៦ឆ្នាំ

ភារិទ្ធ: សព្វថ្ងៃគាត់ធ្វើអីដែរ?

ភ៉ឌី: គាត់ធ្វើជាគ្រូបង្រៀន

ភារិទ្ធ: គ្រូបង្រៀនបឋម

ភ៉ឌី: បាទ គ្រូបង្រៀនបឋម

ភារិទ្ធ: បងមានកូនចៅប៉ុន្មាននាក់ដែរ?

ភ៉ឌី: ខ្ញុំមានកូនចៅ៤នាក់

ភារិទ្ធ: ស្រី ប៉ុន្មាន ប្រុសប៉ុន្មាន?

ភ៉ឌី: ស្រី មួយ ប្រុសបី

ភារិទ្ធ: ហើយចុះឪពុកម្ដាយបង ឪពុកឈ្មោះអី?

ភ៉ឌី: ឪពុកខ្ញុំឈ្មោះធាន សិន

ភារិទ្ធ: ធាន សិន

ភ៉ឌី: បាទ

ភារិទ្ធ: ហើយចុះពេលដែលបាត់គាត់ហ្នឹង គាត់ កាលហ្នឹងគាត់អាយុប៉ុន្មាន?

ភ៉ឌី: ខ្ញុំមិនអាចចាំបានដែរ ប៉ុន្តែអាយុខ្ទង់ ៤០ជាង ដែរ

ភារិទ្ធ: អូ

ភ៉ឌី: បាទ នៅក្នុងឆ្នាំ ១៩៧៥ ហើយពេលដែលគាត់វិលមកស្រុកកំណើតរបស់គាត់ បានមួយសប្ដាហ៍

ភារិទ្ធ: បាទ

ភ៉ឌី: អង្គការគេហៅទៅបំរើការងារវិញ គាត់ជាអតីតអ្នករោងចក្រស៊ីម៉ង់ ចក្រទីងយើងនេះ

ភារិទ្ធ: ហើយចុះម្ដាយបងឈ្មោះអី?

ភ៉ឌី: ម្ដាយខ្ញុំឈ្មោះម៉ក់ ឃុន

ភារិទ្ធ: ម៉ក់ ឃុន

ភ៉ឌី: បាទ

ភារិទ្ធ: ហើយសព្វថ្ងៃគាត់នៅរស់ដែរ?

វ៉ឌី៖ គាត់ស្លាប់ប្រហែលជាបីខែ បួនខែ

ភារិទ្ធ៖ អូ ទើបតែស្លាប់ឥលូវហ្នឹងទេ?

វ៉ឌី៖ បាទ

ភារិទ្ធ៖ គាត់ស្លាប់ដោយសារអីដែរ?

វ៉ឌី៖ គាត់ស្លាប់ដោយជំងឺរ៉ាំរ៉ៃរបស់គាត់ដែលជាប់ តាំងពីជំនាន់ប៉ុល ពតមក ជំងឺរ៉ាំរ៉ៃ ការវះកាត់រហូតដល់ពីរដង ក្រោយពេលរំដោះហើយនោះ ទើបតែបានមួយដងគាត់ធ្វើការវះកាត់ ឈឺ ក្រពះ ស្បូន ដែលគាត់ធ្វើការខ្លាំងហួសកំលាំងរបស់គាត់ហ្នឹង ធ្វើការហួសកំលាំង ហើយជំងឺគាត់ រ៉ាំរ៉ៃខ្លាំងៗរហូត មកដល់បច្ចុប្បន្ន គឺយើងមិនអាចទ្រទ្រង់សភាពការហ្នឹងបានទេ ទោះបី ពេទ្យជំនាញៗនៅកាល់ម៉ែត្រអី ដែលខ្ញុំបាននាំគាត់ទៅ ព្យាបាលគាត់មិនអាចធ្វើអីជួយសង្គ្រោះគាត់បានអា៎ ហើយជំងឺហ្នឹងវារ៉ាំរ៉ៃយូរពេក ហើយដូចវាលទ្ធផលដែរ ដែលបន្សល់ទុកពីរបបប៉ុល ពត ធ្វើអោយគាត់រ៉ាំរ៉ៃទាំងផ្លូវចិត្តទាំងផ្លូវកាយរហូតដល់គាត់ ជំងឺវាជ្រាបចូលម្តងបន្តិចៗ បាត់បង់ជីវិត

ភារិទ្ធ៖ និយាយអញ្ចឹងបងមានបងប្អូនបង្កើតប៉ុន្មាននាក់?

វ៉ឌី៖ ខ្ញុំមានបងប្អូនបង្កើត៨នាក់នៅក្នុងរបបប៉ុល ពតហ្នឹងក្រោយពេលដែលសម្លាប់ឪពុកបានប្រហែលជាមួយ ខែ កូនទោលរបស់ខ្ញុំមួយត្រូវស្លាប់ ក្រោយពេលដែលមួយឆ្នាំបានកន្លងផុត ប្អូនដែលបន្ទាប់ខ្ញុំនេះត្រូវស្លាប់មួយទៀតដោយសារ ខ្វះខាតថ្នាំសង្កូវផងហើយវា ដូចថា ម្តាយខ្ញុំគាត់គ្រាំគ្រាផង ពិបាកវា អាហ្នឹងវាចូលដល់ទុកវាមិនអាចជួយរំលែកបាន វាចេះតែបាត់បង់បណ្តើរៗ អាហ្នឹងវាមានតែបងប្អូនពីរនាក់ប្រុសមួយស្រីមួយ

ភារិទ្ធ៖ សព្វថ្ងៃគាត់នៅភូមិដែរ?

វ៉ឌី៖ បាទ សព្វថ្ងៃប្អូនរបស់ខ្ញុំនៅភូមិតាតែ ឃុំញ៉ែងញ៉ង ស្រុកត្រាំកក់ ខេត្តតាកែវ

ភារិទ្ធ៖ គាត់ឈ្មោះអីដែរ?

វ៉ឌី៖ ប្អូន របស់ខ្ញុំឈ្មោះ ឆាន ឌីវ៉ាន់ណា

ភារិទ្ធ៖ ឆាន ឌីវ៉ាន់ណា

វ៉ឌី៖ បាទ ឆាន ឌីវ៉ាន់ណា

ភារិទ្ធ៖ នៅអើ

រ៉ាឌី: នៅភូមិថ្កោ ក្រាំងដែក

ភារិទ្ធ: បាទ អ៊ី ខ្ញុំចង់អោយបងជួយរៀបរាប់ពីប្រវត្តិឪពុករឺបងប្អូនដែលស្លាប់ទៅ ដូចថាគាត់ស្លាប់ទៅយ៉ាងម៉េច មូលហេតុអី ហើយនៅពេលណា?

រ៉ាឌី: ខ្ញុំគិតថាប្រវត្តិដូចជាក្រុមគ្រួសារខ្ញុំនេះ មិនជាអច្ចរិយៈសំរាប់របបប៉ុល ពតទេ វាមិនមែនជាអស្ចារ្យជាងគេ ខ្ញុំជឿថាមានគេអស្ចារ្យហើយលំបាកជាងខ្ញុំទៀត វេទនាជាងខ្ញុំទៀត ប៉ុន្តែតែថា ប្រវត្តិឪពុករបស់ខ្ញុំហ្នឹង គឺគាត់ជាអ្នកធ្វើការនៅរោងចក្រស៊ីម៉ង់ ចក្រីទីងនេះ ក្រោយពេលដែលរដ្ឋប្រហារឆ្នាំ១៩៦៨ រដ្ឋប្រហារមក សង្គ្រាមវាចេះតែកើតឡើង អញ្ចឹងទៅរោងចក្រស៊ីម៉ង់ត្រូវកងទ័ពរបស់ប៉ុល ពតនេះ រំដោះបាន គាត់ជម្លៀសមកស្រុកទេសវិញ ក្រោយពេលដែលគាត់មកស្រុកទេសវិញ គាត់ពិនិត្យឃើញថា វាការសិក្សារបស់កូនចៅហ្នឹង វាពុំមាន ព្រោះការនោះវាសង្គ្រាមផង ហើយណាមួយវាសង្គ្រាមផង ហើយវាគ្មានសាលារៀនផង អញ្ចឹងនៅពីរដែលអ្នក កន្លែងដែលមានសាលារៀនគឺនៅតែមានផ្សារ ពីផ្សារដែលរដ្ឋាភិបាលលុន ណុល កាន់កាប់ អញ្ចឹងគាត់ ក៏គិតថា ត្រូវតែនាំកូនចូលទៅវិញ ដើម្បីអោយកូនហ្នឹង បានរៀនសូត្រ ហើយគាត់ ក៏កំពុងតែគិតថាគាត់ហ្នឹងជាអ្នកចេះដឹងម្នាក់ដែរ តែ ខ្ញុំ បានជំរាបអញ្ចឹងអា អញ្ចឹង ក៏គាត់ទៅបន្ទុំខ្ញុំ ប្អូនខ្ញុំនោះបានទៅនៅផ្សារនៅក្រុងនោះ ដើម្បីអោយមានការរៀនសូត្រ

ភារិទ្ធ: ទៅនៅឆ្នាំណាដែរ?

រ៉ាឌី: កាលខ្ញុំ គ្រាន់តែជម្លៀសចេញមកនៅស្រុកកាលពីឆ្នាំ១៩៧០ រហូតទៅដល់ឆ្នាំ១៩៧២ នៅស្រុកបានពីរឆ្នាំ ហើយឃើញថាការដែលបំបាត់សាសនា ការបំបាត់អី ដែលថាអោយលោកចាប់បន្ទសុទ្ធ មើលឃើញសភាពការណ៍ក៏វាមិនល្អប៉ុន្មានដែរអាហ្នឹង ព្រោះអីខ្ញុំនៅទាន់ នៅសម័យហ្នឹង ខ្ញុំមិនទាន់លឺពាក្យមួយដូចលុន ណុល ច្រើនតែនិយាយហើយបាចទាំងដែន បាចទាំងប្រាក់ តាមយន្តហោះទៀត បំបាត់សាសនា អញ្ចឹងកាលណោះកងទ័ពរំដោះរបស់ប៉ុល ពតហ្នឹង គឺចាប់ផ្តើមបំបាត់ហើយ ប៉ុល ពតនឹកឃើញថា សកម្មភាពនោះ ហាក់ដូចជាមិនល្អអ៉ា បំបាត់ភាពទៅក្នុងវិញទៅ ទៅក្នុងទៅ គាត់ទៅជាប់និន្នាការណ៍ជាអ្នកក្បត់ជាតិ

ភារិទ្ធ: ទៅក្នុងហ្នឹង គឺទៅភ្នំពេញហ្នឹង?

ភ៉ឌី: បាទ គឺទៅភ្នំពេញ កាលហ្នឹង គេចែកគ្នាអា៎ តំបន់រំដោះគេហៅខាងក្រៅ អាតំបន់រំដោះរបស់ខ្មែរក្រហមហ្នឹង គេហៅខាងក្រៅ ហើយខាងក្នុងគឺតំបន់ដែលរដ្ឋាភិបាលលុន ណុល កាន់កាប់

ភារិទ្ធ: អញ្ចឹងបានន័យថាទៅភ្នំពេញហ្នឹង ពីរលើកហើយ?

ភ៉ឌី: បាទ គឺអត់ទេ ក្រោយពេលដែលឆ្នាំ ជម្លៀសចេញពីឆ្នាំ៧០អា៎ គាត់បែកនៅរោងចក្រនេះ គឺគាត់ជម្លៀសមកនៅស្រុក សំណង់យើងខ្ពស់នេះ

ភារិទ្ធ: ចក្រីទីងហ្នឹង

ភ៉ឌី: ចក្រីទីងនេះ វាមកនៅស្រុកបានពីរឆ្នាំមើលឃើញមានការលំបាកអញ្ចឹង គាត់ក៏នាំក្រុមគ្រួសារខ្ញុំវិលទៅភ្នំពេញអា៎ អាហ្នឹងចូលទៅក្នុងវិញហើយ អាហ្នឹងចូលទៅក្នុងវិញហើយ អញ្ចឹងនៅក្នុងឆ្នាំ១៩៧២

ភារិទ្ធ: បាទ ១៩៧២ នៅភ្នំពេញ

ភ៉ឌី: បាទ នៅភ្នំពេញនេះបានបីឆ្នាំ

ភារិទ្ធ: ទៅនៅណាភ្នំពេញ

ភ៉ឌី: ទៅនៅភ្នំពេញ គឺនៅម៉ុំបីងទំពន់ បើតាមខ្ញុំដឹងច្បាស់ ប៉ុនតែវាមិនបានគ្រប់គ្រាន់ទេ

ភារិទ្ធ: បាទ

ភ៉ឌី: ដូចថាខ្ញុំបានរៀនសូត្រអីមកឡើងវិញទៅហើយ កាលហ្នឹង

ភារិទ្ធ: កាលហ្នឹងបងរៀនថ្នាក់ទីប៉ុន្មាន?

ភ៉ឌី: កាលហ្នឹងខ្ញុំរៀនថ្នាក់ទី៧

ភារិទ្ធ: អូ

ភ៉ឌី: បាទ ខ្ញុំរៀនថ្នាក់ទី៧ ទី៧ កាលនោះ គេរាប់ពីទី១២ មកវិញ ហើយទៅបែក បែកឆ្នាំ៧៥ ១៧ មេសា ក៏ត្រូវជម្លៀសចេញទាំងអស់គ្នា ថ្ងៃដែល ១៧ មេសាហ្នឹង ម្តាយខ្ញុំត្រូវប្រសូត្រ ឆ្លងទន្លេទៀត វាជាការមួយលំបាក ខ្ញុំហើយនិងប្អូននៅផ្ទះ ដែលនៅប្អូនហើយកាលនោះ ខ្ញុំមិនទាន់ជាធំណាស់ណាទេ ហើយឪពុកខ្ញុំនាំម្តាយ នាំម្តាយទៅឆ្លងទន្លេឆ្លងទន្លេ អីបានរួចរាល់អី យើងទៅនៅ ដូចជាជំរុំវា កងទ័ពរំដោះគេហ្នឹង គេរំដោះហើយហ្នឹង គេមិនអោយនៅទេ គេអោយចេញអោយផុត ជម្លៀសចេញពីភ្នំពេញ ដល់

តែបន្ទិចយន្តហោះអាមេរិកាំងមកទំលាក់ មកអីអញ្ចឹងទៅ អញ្ចឹងក៏គាត់ទៅនាំ ហូបហ្នឹង បណ្តើរៗហ្នឹង ទៅរាវ រាវ ចេញពីភ្នំពេញ មកដល់ចាក់អង្រែហ្នឹង សំរាន្តមួយយប់អី អញ្ចឹងទៅ រហូតមកដល់ផ្លូវជាតិលេខពីរ លេខបីយើងចេញអត់រួច ដែលគេបិទហ្នឹង ហ្នឹងក៏ជិះតាម អា ច្បារអំពៅទៅកើតទៅ ខ្ញុំវាអត់បានចាំដែរទេថាខ្ញុំធ្វើដំណើរប៉ុន្មានថ្ងៃទេ ទើបមកដល់ ស្រុកកំណើតវិញ អញ្ចឹងក្រោយពេលមកដល់ស្រុកកំណើតបានមួយអាទិត្យមេភូមិ ប្រធានភូមិគេនេះ នៅតំបន់រំដោះនេះ ក៏គេថា ឃុំគេអញ្ជើញពូទៅ ពិភាក្សា រឺក៏ចង់សួរនាំពីការងារ ព្រោះឥលូវអង្គការយើងត្រូវការអ្នកដែលបច្ចេកទេស មានបច្ចេកទេសទៅធ្វើការកន្លែងដើមវិញ ហើយគាត់ ក៏មិនដឹងថាខ្លួនគាត់ទៅស្លាប់ដែរ ខ្ញុំជឿថាមនុស្សបើសិនជាដឹងខ្លួនថាដើរទៅស្លាប់ហើយ ប្រហែលជាមានការប្រឡូស្តបន្ទ្រាស់ហើយតដៃតជើងហើយ ប៉ុន្តែគាត់អត់ដឹងទេ ខ្ញុំចាំបានថាគាត់ស្លៀកខ្លី ពាក់អាវខៀវមួយដើរចេញទៅ ចេញពីជើងភូមិ ដើរទៅត្រង់សាលាឃុំ ខ្ញុំខ្លាចចិត្តថាគាត់ដើរទៅស្លាប់អា៎

ភារិទ្ធ: បាទ

រ៉ាឌី: គេបបួល គេមិនបបួលទេ គេនាំគាត់ទៅសម្លាប់ អញ្ចឹងនាំគាត់ទៅសម្លាប់ មនុស្សដែលអត់ដឹងខ្លួន ចេះតែទៅ ទៅ ហើយក្រោយពេលដែលផុតទៅដល់សាលាឃុំញ៉ើងញ៉ើងហ្នឹង អតីត សាលាឃុំ ញ៉ើងញ៉ើងរបស់ខ្មែរក្រហមហ្នឹង គឺបច្ចុប្បន្នក៏ជាសាលាឃុំញ៉ើងញ៉ើងដែរ គឺកន្លែងហ្នឹង ហើយខ្ញុំបានដឹងត្រឹមតែប៉ុណ្ណឹងទេ ហើយបាត់ដំណឹងសូន្យឈឹងតែម្តង ហើយអ្នកយាម បងប្អូននៅជិតខាង បងប្អូនដែលនៅស្រុក បានខ្សឹបប្រាប់ថា គាត់ស្លាប់ហើយ គេសម្លាប់ហើយ គេមិនអោយមកវិញទេ មិនយើងចាំសង្ឃឹមទេ ពេលហ្នឹង ហើយដែលខ្ញុំចេះតែមានអាកំហឹង ចេះតែមានការគិតថា អយុត្តធម៌សំរាប់គាត់អា៎ បើសិនជាគាត់ជាអ្នកនិន្នាការ នយោបាយ រឺក៏ជាអ្នក តែគាត់ជាអ្នកបច្ចេកទេសសោះ គាត់ត្រូវទទួលការកៀបសង្កត់ ការកាប់សំរាប់ពីប៉ុល ពតដែរ

ភារិទ្ធ: ហើយចុះប្រធានភូមិដែលបងនិយាយអំបាញ់មិញ គាត់ឈ្មោះអីដែរ?

រ៉ាឌី: ប្រធានភូមិនេះ ខ្ញុំមិនបានស្គាល់ជីតាទេ តែគ្រាន់តែខ្ញុំបានដឹងថាគាត់ឈ្មោះថន

ភារិទ្ធ: អូ

រ៉ាឌី: មនុស្សនេះ ក៏ជាមនុស្សដែលឪពុកខ្ញុំធ្លាប់ចិញ្ចឹម កាលជំនាន់នោះ គេជ្រើសរើសអ្នកដែល

ក្រី ក្រ អ្នកដែលអវិជ្ជាហ្នឹងធ្វើជាអ្នកដឹកនាំ អាហ្នឹងខ្ញុំដឹងច្បាស់ពីបញ្ហាហ្នឹង គឺគេជ្រើស តែមនុស្សប្រភេទហ្នឹង អញ្ចឹងអ៊ីដែលគេធ្វើសំដៅទៅលើឪពុកខ្ញុំមុន មុនគេនៅក្នុងភូមិដែល ខ្ញុំរស់នៅនេះ គឺគេចង់បង្ហាញពីទឹកចិត្តរបស់គេ ទោះបីថា ជាឪពុកខ្ញុំចិញ្ចឹមមកតាំងពីតូច មកក្តីក៏ តែឪពុកខ្ញុំជាខ្មាំងក៏ត្រូវតែសម្លាប់ដែរ អាហ្នឹងគឺគេបញ្ជាក់ប្រាប់អង្គការគេ សំរាប់ អ្នកដឹកនាំរបស់គេ ថា គេជាអ្នកដឹកនាំដ៏មុះមុតបំផុត ដោយមិនគិតថាបងប្អូន អ្នកមានគុណ មានអី ឪពុកម្តាយអីទេ គឺ គេចង់បង្ហាញថាអញ្ចឹងអាំ ប៉ុល ពតគឺគេចង់បានអញ្ចឹង សក់ នរណាក្បាលអ្នកហ្នឹង បើឪពុកខុស ក៏ត្រូវសម្លាប់ ម្តាយក៏ត្រូវសម្លាប់ ដោយគេមិនបាន គិតថា ជាប់សាច់ឈាមសាលោហិត អ្នកមានគុណអីទេ បំបាត់សាសនា គឺដូចទីមួយដែល ខ្ញុំនិយាយ គឺដើម្បីអោយមនុស្សក្លាហាន

ភារិទ្ធៈ អញ្ចឹងបងខ្ញុំចង់ដឹងថាអ្នកដែលគេយកទៅហ្នឹងគេឈ្មោះអី ហើយដឹងថាយកទៅណាទេ?

រ៉ាឌី: អ្នកដែលគេយកទៅ គឺបងប្អូនរបស់នេះដែរ គឺជីតារបស់ខ្ញុំ ជីតារបស់ខ្ញុំដែលជាឪពុករបស់ គាត់បង្កើតដែលគាត់ស្លាប់បាត់ហើយ គាត់ស្លាប់ហើយ គាត់នៅស្រុកកំណើតមិនបានទៅ ណាទេ កាលហ្នឹង អានេះគាត់អ្នកមូលដ្ឋាន

ភារិទ្ធៈ អញ្ចឹងគាត់ស្លាប់ដោយសារអីដែរ?

រ៉ាឌី: គាត់ស្លាប់ដោយសារជំងឺ គាត់ចាស់អាយុ៨០ជាង គាត់អាយុជាង៦០ ដោយសារជំងឺ

ភារិទ្ធៈ ស្លាប់ជំនាន់ក្រោយនេះអេ?

រ៉ាឌី: បាទ ទើបតែស្លាប់ ក្រោយពេលរំដោះនេះហើយ

ភារិទ្ធៈ ហើយចុះគេថាយកទៅណា?

រ៉ាឌី: គេយកគាត់ចេញមកថាអោយទៅសាលាឃុំ ហើយក៏បាត់ដំណឹងតែម្តងទៅ ខ្ញុំទើបតែទទួល បានពត៌មាននេះទើបតែមួយឆ្នាំមុននេះឯង ដែលគេថាគេយកគាត់មកសម្លាប់នៅក្រាំង តាចាន់នេះ ព្រោះអ្នកដែលជាប់នៅក្រាំងតាចាន់នេះ វាហាក់ដូចជាពុំដែលមានឃើញទៅ វិញ អញ្ចឹងយើងអត់មានបានទទួលពត៌មានអីថា តើគាត់នៅជាប់គុក អីមិនជាប់គុកអីម៉េច ទេ ប៉ុនតែក្រាំងតាចាន់នេះតាមតែខ្ញុំទទួលពត៌មានបានដែលតាមអ្នកដែលគេធ្លាប់បំរើការ ងារនៅក្នុងហ្នឹង យ៉ាងម៉េច មិនដឹងម៉េចទេ ក្តាប់មិនបានច្បាស់ដែរ ប្រហែលជាគាត់មិន បានជាប់គុកយូរទេ ប្រហែលជាក្នុងបី បួន ប្រាំថ្ងៃ គឺអង្គការវាសម្លាប់ វាចោទថា ក្បត់

អន្តការ អាវ៉ាចេញមកហើយ យើងចូលទៅអា៎ បាទ អាហ្នឹងក្បត់ហើយ ដំហ៊ានទី១ គឺការកាប់សម្លាប់របស់គេគឺអញ្ចឹង

ភារិទ្ធ: នរណាគេអ្នកនិយាយប្រាប់ព័ត៌មាន?

រ៉ាឌី: អ្នកដែលនិយាយប្រាប់ព័ត៌មានគឺនៅប៉ែកនេះដែរ ប៉ុន្តែព័ត៌មានហាក់ដូចជាមិនទាន់យកជាផ្លូវការបាន បើខ្ញុំមិនទាន់បានជួបអ្នកហ្នឹង មានតែគេខ្សឹបប្រាប់អ្នកហ្នឹង អោយមកសួរពីបញ្ហាហ្នឹងអា៎ ប៉ុន្តែខ្ញុំមិនទាន់បានជួបសួរនាំទេ ហើយខ្ញុំក៏គិតថា វាល្មមនឹងចប់សព្វគ្រប់នឹងការសួរនាំដេញដល់រឿងចាស់ឡើងវិញហើយ ព្រោះយើងឥលូវវាបានសុខទាំងអស់ទាំងអស់គ្នាទៅហើយ អញ្ចឹងទុកអោយកម្មពៀរវាយ៉ាងម៉េចទៅ អោយយើងដូចថាខ្មែរកាន់ព្រះពុទ្ធសាសនា គឺថាបើកម្មយើងទទួលបានប៉ុន្មានអីប៉ុន្មានគឺត្រឹមហ្នឹងចុះ

ភារិទ្ធ: ហើយចុះអ្នកដែលប្រាប់បងហ្នឹងខ្ញុំចង់ដឹងថាឈ្មោះអី?

រ៉ាឌី: អ្នកដែលប្រាប់ខ្ញុំនេះ ខ្ញុំដូចថាមិនចង់អោយមានរឿងរ៉ាវតទៅទៀត ហើយទុកលទ្ធភាពអោយខ្ញុំ មានពេលណាឱកាសល្អ គឺយើងស៊ើបពីបញ្ហាហ្នឹង បន្តទៅទៀត មិនស៊ើបពីអីទេ ប៉ុន្តែដឹងថាចង់បាន អាធាតុពិតរបស់គាត់ មិនចង់ជាស្អីទេ គ្រាន់តែចង់ធ្វើសក្ការៈបូជា សូមអាធ្យាស្រ័យពីបញ្ហាហ្នឹង

ភារិទ្ធ: បាទ អត់អីទេ អាហ្នឹងជាសិទ្ធរបស់បងនៅក្នុងការ និយាយ

រ៉ាឌី: បាទ គ្រាន់តែវាមិនទាន់ពិត យើងមិនទាន់បានស៊ើបសួរ ហើយក៏ខ្ញុំដូចថាគ្មានបំណងអីវែងឆ្ងាយទេ ខ្ញុំនិយាយអោយត្រង់ស្រាប់តែលើកម្មពៀរព្រះកំណត់ហើយ ខ្ញុំជឿទៅលើព្រះវិញហើយ ហើយក៏គិត អញ្ចឹងថា បើថា ព្រំលិខិត និស្ស័យរបស់មនុស្ស សម្លាប់ទៅលើអី រឿងអី ខ្ញុំគិតថា ឪពុកខ្ញុំបើសិនជាប៉ុល ពតមិនសម្លាប់ ប្រហែលជាមិនទាន់ស្លាប់ទេ អញ្ចឹងមិនមែនជាកម្មពៀររបស់គាត់ទេ មនុស្សជាងបីលាននាក់ហ្នឹងមិនមានកម្មពៀរទេ គឺស្លាប់ដោយបំពានលើកម្មពៀរហ្នឹងឯង អាហ្នឹងនិយាយអោយតាមព្រះពុទ្ធសាសនា កន្លែងហ្នឹងមួយហាក់ដូចថា វា បើនិយាយពីកម្ម ធម៌ ពុទ្ធចក្រ អ្នកដែលត្រូវស្លាប់វាចូលកម្មពៀរ ប៉ុន្តែខ្ញុំចំពោះលើចំនុចនេះ មិនទាន់យល់ស្របតាម

ភារិទ្ធ: ហើយចុះដូចថាពេលដែលយកទៅដូចថាបាត់ដំណឹងគាត់អញ្ចឹង ដូចថាបង ម្តាយបងមានអារម្មណ៍យ៉ាងម៉េចដែរ?

វ៉ាឌីៈ អាហ្នឹង ខ្ញុំជំរាបថា ចំនុចទាំងអស់នេះហើយ ដែលខ្ញុំ គួរតែ លើក តែខ្ញុំគិតថាគេមិនទាន់យល់ ដូចថាវាមានរឿងគេសោកសៅជាងខ្ញុំទៅទៀត ខ្ញុំនៅចាំ ថាម្ដាយខ្ញុំសោកសៅណាស់ ក្រោយពេលដែលបាត់ប្ដី ហើយកូន នៅផ្ទះ បន្ទុក ឈឺពីរនាក់ទៀត គាត់ ដូចថាចង់ចូល វិកលចរិកអា៎ ប៉ុន្តែ ដូចថា បានបងប្អូនរបស់ខ្ញុំដែលបានជួយជ្រុមជ្រែងលើកទឹកចិត្តខ្លះអញ្ចឹងអីទៅណា ប៉ុន្តែការលើកទឹកចិត្តជំនាន់នោះ គឺយើងធ្វើដោយលាក់លាមបំផុត យប់ឡើង គឺតំរង់ឈ្លបសំងាត់ ខ្ញុំនៅចាំបាន កាលហ្នឹងខ្ញុំ អាយុ ១២ ១៣ ឆ្នាំ ឈ្លបសំងាត់របស់អង្គការគេហ្នឹង គឺតែងតែមកលបស្ដាប់នៅក្រោមផ្ទះរាល់យប់ ក្រែងល៎ យើងមានសកម្មភាពអី យើងនិយាយអីពីគេ យើងយប់ឡើងត្រូវនៅស្ងៀម ទោះបីថា យំ យំក៏អត់ហ៊ានអោយលឺដែរ ព្រលឹមឡើងត្រូវចេញទៅធ្វើការអញ្ចឹងទៅ ទៅធ្វើការជាកង តាមកង តាមរបស់គាត់អញ្ចឹងទៅ ខ្ញុំតាមកងរបស់ខ្ញុំអញ្ចឹងទៅ យប់ឡើងគាត់មកសោកសង្វេង ហើយខ្ញុំមិនដឹងធ្វើយ៉ាងម៉េច ហើយដូចថាបច្ចុប្បន្នយើងចេះតែថាអោយអ្នកដទៃ ជួយថាអញ្ចោះអញ្ចុះអីទៅ ជំនាន់នោះដូចថាមិនបានទេ គៀបសង្កត់ទាំងផ្នែកសតិអារម្មណ៍ ផ្នែកផ្លូវចិត្តផងធ្វើបាប បើនិយាយពីប៉ុល ពត ដែលខ្ញុំបានឆ្លងកាត់គឺវាគ្មានអ្វីស្មើទេ គ្មានអីស្មើទេ ហើយខ្ញុំគិតថាមិនមែនមានតែខ្ញុំម្នាក់ទេ មនុស្សជំនាន់ខ្ញុំ មុនខ្ញុំបន្តិចហ្នឹង ធ្លាប់ឆ្លងកាត់ប៉ុល ពត ហ្នឹងគឺមិនអាចនិយាយកើត មិនដឹងចង់យកស្អីមកធៀបនឹងបាន

ភារិទ្ធៈ ហើយអញ្ចឹងខ្ញុំចង់ដឹង បងប្អូនពីរនាក់ទៀតដែលស្លាប់ ស្លាប់ពេលណាខ្លះ ហើយមូលហេតុអី?

វ៉ាឌីៈ ក្រោយពេលដែលឪពុកខ្ញុំយកទៅសម្លាប់បានរយៈពេលមួយខែខ្ញុំស្លាប់បានប្អូនពៅមួយ

ភារិទ្ធៈ ទើបតែកើតហ្នឹងអេ?

វ៉ាឌីៈ បាទ ទើបតែកើតស្លាប់ ប្អូនពៅ មួយ ក្រោយពេលហ្នឹងបានមួយឆ្នាំកន្លះ ខ្ញុំស្លាប់ប្អូនស្រីម្នាក់ ដែលបន្ទាប់ខ្ញុំ

ភារិទ្ធៈ អាហ្នឹងស្លាប់ដោយសារអី?

វ៉ាឌីៈ ស្លាប់ដោយសារជំងឺ

ភារិទ្ធៈ អូ

ភ៉ឌីៈ ហើយគ្នាភ៉ុរ៉ៃ ប្អូនស្រីរបស់ខ្ញុំ ខ្ញុំនិយាយហាក់ដូចជាវាចេះអាំ ហាក់ដូចជាមោទន នៅក្រុមគ្រួសារខ្ញុំ វាទទួលភ៉ាបរ៉ង ហើយវាឈឺចាប់ ឈឺចាប់អាំ

ភារិទ្ធៈ ពេលគាត់ស្លាប់ហ្នឹងអាយុប៉ុន្មានដែរ?

ភ៉ឌីៈ ពេលនោះហ្នឹងប្រហែលជា១២ឆ្នាំ ប្អូនខ្ញុំបន្ទាប់ខ្ញុំមួយឆ្នាំ ស្លាប់ ហើយគេចាប់រុំកន្ទេលទៅកប់ រហូតដល់ឥលូវទៅរកមិនដឹងនៅឯណាទៀតអាំ រកតែកាយឆ្អឹងធ្វើបុណ្យ ក៏កាយអត់ទាន់ ព្រោះកន្លែងដែលគេអោយកប់ហ្នឹង នៅវត្តកាកៃហ្នឹង ឯង ហើយខ្មោចអ្នកដែលស្លាប់នៅក្នុងជំនាន់ហ្នឹងប៉ុន្មាន គេយកទៅកប់ម្ដុំហ្នឹងទាំងអស់ កាយកប់អន្លង់មួយ៤ ៥ហ្នឹង ៤ ១០ បំបែកគ្នាយកគោ ពីលើគ្នាអញ្ចឹងទៅ អាហ្នឹងយើងកាយរកឆ្អឹង រកធាតុគ្នា មកធ្វើបុណ្យណេះផង ចេះតែធ្វើប្រារព ប្រារព

ភារិទ្ធៈ អាហ្នឹងកន្លែងសម្លាប់តើអី អគ្រាន់តែ?

ភ៉ឌីៈ មិនមានជាកន្លែងសម្លាប់ទេ តែវាស្លាប់ដោយជំងឺ

ភារិទ្ធៈ អូ គេយកទៅកប់

ភ៉ឌីៈ បាទ យកទៅកប់ម្ដុំហ្នឹង

ភារិទ្ធៈ ហើយចុះប្អូនម្នាក់ទៀត?

ភ៉ឌីៈ ប្អូនម្នាក់ទៀតដែលរស់មកទល់សព្វថ្ងៃនេះ អាហ្នឹងគ្រូទេ បន្ទាប់ពីប្អូនពៅរបស់ខ្ញុំហ្នឹង គឺគ្នារស់ គឺ គ្នានៅកុមារ

ភារិទ្ធៈ បាទ

ភ៉ឌីៈ នៅតូច ហើយបានថាវានៅកង នៅអីហ្នឹង រៀងព្រាត់ប្រាស់ពីម្ដាយពីបងប្អូនក៏ដោយ គឺនៅគេហ្នឹងទៅ រហូតដល់

ភារិទ្ធៈ អញ្ចឹងប្អូនស្លាប់តែម្នាក់តើអី?

ភ៉ឌីៈ បាទ ខ្ញុំប្អូនស្លាប់ពីរនាក់ តូចមួយ ដូចអាពៅ ហើយនោះបន្ទាប់ខ្ញុំមួយ អញ្ចឹងនៅអាភាពថ្ងៃ គឺ អាកណ្ដាល អាកណ្ដាលរបស់ខ្ញុំ អាហ្នឹងប្អូនទីបី

ភារិទ្ធៈ ខ្ញុំចង់ដឹងថាអំបាញ់មិញដូច និយាយស្លាប់ហ្នឹង ថាមួយតូចនេះទេ

ភ៉ឌីៈ តូចនេះដែលថាម្ដាយខ្ញុំប្រសូត្រថ្ងៃ១៧ មេសានេះ

ភារិទ្ធៈ អូ

រ៉ាឌីៈ បាទ

ភារិទ្ធៈ អញ្ចឹងបងខ្ញុំចង់ដឹង ខ្មែរក្រហមដូចថាក្រោយពីរដ្ឋប្រហារឆ្នាំ៧០ភ្លាមនៅហ្នឹងមានខ្មែរក្រហមមានអីដែរអេ?

រ៉ាឌីៈ កាលក្រោយរដ្ឋប្រហារឆ្នាំ ៧០ ខ្ញុំដេក ខ្ញុំដេកនៅជុំរុំ ដូចថាគេចែកជាតំបន់អាំ៎ ពិសេស កន្លែងណាដែលគេរំដោះបានគឺថា ពិសេស គឺតំបន់មូល អើ ជនបទ ជនបទភាគច្រើន គេកាន់កាប់ អាហ្នឹងគឺប្រជាជនចូល ស្រស្រុក ស្រស្រាក់ ខ្លាំងណាស់ ព្រោះ ដូចថា បើនិយាយពីនយោបាយ គឺលុន ណុល នេះ ជាអាយ៉ងរបស់អាមេរិកអីអញ្ចឹងទៅណា ដូចថាប្រជាជនខ្មែរយើង ដូចថាគាត់មិនធ្លាប់ឆ្លងកាត់អារឿងការបោកប្រាស់អីអញ្ចឹងអាំ៎ គាត់ ចូល រ៉ូង បើយើងរួមគ្នារំដោះ រឿងអីអញ្ចឹងទៅ នៅកងទ័ព កងអីអញ្ចឹងទៅ ដឹងច្បាស់ថា ឪពុកម្តាយខ្លួន ក្រោយពេលរំដោះហើយ ត្រូវទទួល រងកម្ម ខ្ញុំមានបងប្អូនធ្វើទ័ពប៉ុល ពតម្នាក់ដែរ គាត់រស់ដល់សព្វថ្ងៃ ខ្ញុំសួរគាត់ថា បងឯងមានដឹងថានៅក្រោយយ៉ាងម៉េចទេ អត់ គាត់នៅព្រំដែន អត់ដឹង គាត់អត់ដឹងម្តាយ បងប្អូនគាត់ គេយកទៅសម្លាប់អី អត់ដឹងទេ

ភារិទ្ធៈ អូ គាត់មានឪពុកម្តាយគេយកទៅសម្លាប់?

រ៉ាឌីៈ បាទ ឪពុកខ្ញុំត្រូវជាពូ អត់ដឹង

ភារិទ្ធៈ អូ

រ៉ាឌីៈ ក្រោយពេលដែលគេសម្លាប់គាត់ហើយ គេស្រាវជ្រាវ គេស្រាវជ្រាវ ថា អឺ មានពូក្បត់អង្គការអញ្ចឹង ក៏គេដក អោយទៅនៅកន្លែងណាមួយវា លើ ប្រជាជនប៉ុន្តែជាក្រុមកងចល័ត អីមួយអញ្ចឹងដែរ គឺជាក្រុម អញ្ចឹងគាត់ធ្លាប់ខ្លួននៅពេលដឹងអញ្ចឹងដែរ ដឹងថាអូ អញ្ចឹងក្រុមគ្រួសារគាត់នៅក្រោយគេមានបញ្ហាអីហើយ ហើយគាត់ជាអតីតកងទ័ពម្នាក់ដែលរំដោះហ្នឹងអាំ៎

ភារិទ្ធៈ គាត់ឈ្មោះអីដែរខ្ញុំចង់ដឹង?

រ៉ាឌីៈ គាត់ ឥលូវនៅ កុល ស្អែម

ភារិទ្ធៈ គាត់មិនមែនស្រុកកំណើតនៅហ្នឹងទេ?

រ៉ាឌីៈ គាត់មិនមែននៅហ្នឹងទេ គាត់នៅប៉ៃលិនអោះ

ភារិទ្ធៈ ហើយចុះកាលហ្នឹង ក្រោយរដ្ឋប្រហារភ្លាម ខ្ញុំចង់ដឹងហេតុការណ៍អីខ្លះកើតមាននៅក្នុងភូមិ

រ៉ាឌីៈ កាលហ្នឹង ខ្ញុំនៅតូចៗ ដូចជាចេះតែមានហេតុការណ៍ហើយ គ្រាន់តែថា អ្នកនៅជនបទ អ្នកនៅស្រុកភូមិហ្នឹង គ្រាន់តែគេចគ្រាប់ គេច គ្រាប់កាំភ្លើងហោះ

ភារិទ្ធៈ មានទំលាក់គ្រាប់បែក

រ៉ាឌីៈ បាទ ទំលាក់គ្រាប់បែក គ្រាប់កាំភ្លើងហោះអីហ្នឹង ហើយទាហ៊ានលុន ណុលចុះធ្វើរះម្តងៗ អីហ្នឹង យើងទៅ គេច អី ចេញ ពាសពីមុខគេអីអញ្ចឹងទៅ កាលហ្នឹង យើងទាហ៊ាន លុន ណុល គឺ នៅតែទីផ្សារទេ ខទាហរណ៍ថាចង់បើកផ្លូវជាតិពីអង្គតាសោមទៅ គូលី អញ្ចឹង ធ្វើរ៉ាសអញ្ចឹងទៅ មានគ្រាប់ មានឡានអីអញ្ចឹង មានយន្តហោះអីអញ្ចឹង ខ្ញុំចាំ បានអាំ មានយន្តហោះអីអញ្ចឹង បើកទៅ គេធ្វើដំណើរអីអញ្ចឹងទៅ បានរយៈពេលមួយ ថ្ងៃហ្នឹង ដែលគេបិទ ដែលគេទុករូបថត ហ្នឹង ក៏ថតទៅ ស្អែកឡើង គេមកជួប ក៏ទៅធ្វើ ដំណើរទៅមក ទៅមក បន្តិចក៏ ព្រោះថា ការកងទ័ពរំដោះហ្នឹង គេចូលរួម ពីប្រជាជន ហ្នឹង គឺគេកាត់ផ្តល់ កាត់អី ផ្តល់អីទៅកាត់មិនអោយធ្វើដំណើរទៅរួច ខ្ញុំនៅចាំបានកាល ហ្នឹង

ភារិទ្ធៈ ផ្តាច់ផ្លូវ

រ៉ាឌីៈ ផ្តាច់ផ្លូវ យុទ្ធសាស្ត្ររបស់គេគឺ គេផ្តាច់ផ្លូវ កុំអោយយើងទាហ៊ានលុន ណុលធ្វើដំណើរ បាន អាហ្នឹងបានថា ផ្លូវផ្តល់ស្បានអីត្រូវខ្ទេចខ្ទាំ ហ្នឹង កាលជំនាន់នោះ មកដែរហ្នឹង អ៊ីដែលការស្តារពេលនេះ វា អ្នកដែលនៅ អ្នកដែលមិនបានដឹង មិនជឿ មិនជឿថា ការស្តាររបស់ប្រទេសខ្មែរវាលំបាកប៉ុណ្ណា វាខ្ទេចខ្ទាំ

ភារិទ្ធៈ ហើយចុះបង ខ្ញុំចង់ដឹងថា ពេលដែលខ្មែរក្រហម បានអំណាចឆ្នាំអើ ៧៥អាំ ពេលដែល បងជម្លៀសពីភ្នំពេញមកដល់ភូមិអញ្ចឹង មកដល់ភ្លាមតើគេ មានស៊ើបសួរពីប្រវត្តិពីអីដែរ

រ៉ាឌីៈ ចំពោះបញ្ហានេះ ខ្ញុំនៅតូច ខ្ញុំមិនបានដឹងទេ ប៉ុន្តែប្រហែលជាមាន ប្រហែលជាមានស៊ើប ពីប្រវត្តិ

ភារិទ្ធៈ អញ្ចឹងមកដល់

រ៉ាឌីៈ ខ្ញុំនៅចាំថា ខ្ញុំនៅចាំបាន ឪពុកឪជាអ្នកជំនាញការរោងចក្រនៅទីនោះ ក្រោយពេលហ្នឹង គាត់នៅភ្នំពេញហ្នឹង គាត់ធ្វើការ នៅជាមួយកាកបាទក្រហម

ភារិទ្ធៈ អូ

រ៉ាឌីៈ ឃើញក្រោយពេលដែលគេយកឪពុកខ្ញុំទៅសម្លាប់ហើយ ខ្ញុំទទួលពត៌មានអ្នកដែលនៅរស់កងជាមួយគ្នាហ្នឹងអាំ គេចោទឪពុកខ្ញុំថាគាត់ពាក់សក្តិ៥ ហើយគាត់អញ្ចឹង អញ្ចឹងបានខ្ញុំថាប្រហែលជាមានការស៊ើបពីគេ គឺក៏មានការគេចោទបំពាន យ៉ាងម៉េច អីអត់បានដឹងទេ ប៉ុនគ្រាន់តែដឹងប្រវត្តិរបស់ខ្ញុំ ឪពុកខ្ញុំធ្វើការជាមួយកាកបាទក្រហម ជាមួយកាកបាទក្រហម ក៏ខ្ញុំគ្រាន់បើដែរ មានខោអាវ មានអង្ករមានអី កាកក្រហមហ្នឹងឈានមុខដែរ

ភារិទ្ធៈ ហើយចុះពេលមកដល់ភ្នាមហ្នឹង ហាក់ដូចជាខ្មែរក្រហមរឺក៏អញ្ញាធម៌ ភូមិឃុំហ្នឹងគេអោយធ្វើអីខ្លះ?

រ៉ាឌីៈ មកដល់ភូមិហ្នឹងមិនទាន់ធ្វើអីនៅឡើយទេ រយៈពេលមួយអាទិត្យហ្នឹង គឺគ្រាន់តែបងប្អូនមកសាកសួរសុខទុក្ខហ្នឹង ក៏មានហ៊ានដែរ អ្នកខ្លះលួច ឧទាហរណ៍ថា ផ្ញើរមាន់ ផ្ញើរអីដែលលួចហ្នឹង គឺគេផ្ញើរតាមរយៈអ្នកផ្សេងមិនអោយមកហ៊ានមកជួបទេ ខ្លាចគេឆ្លើយថាមកពាក់ព័ន្ធ

ភារិទ្ធៈ អូ

រ៉ាឌីៈ ហើយអ្នកដែលនៅស្រុកមូលដ្ឋាននេះ គេចែកដែលនៅមូលដ្ឋាននេះ ពួកថ្មីនេះ គេមិនសូវអោយបានជួបគ្នាទេ អ្នកមូលដ្ឋាន គេខ្លាចអ្នកថ្មីហ្នឹងពាក់ព័ន្ធដល់រឿងរ៉ាវរបស់គេអាំ ហើយបើពាក់ព័ន្ធខ្ញុំជំរាបថា មានបងជីដូនមួយម្នាក់ គាត់មានបញ្ហា គាត់អត់ដឹងអីសោះ គាត់ត្រូវ គេដកចេញពីទ័ព ពីមូលដ្ឋានទ័ព របស់គេចេញដោយអត់ដឹងខ្លួន

ភារិទ្ធៈ អូ

រ៉ាឌីៈ ការក្តាប់ហើយនិងការគ្រប់គ្រងរបស់ ខ្មែរក្រហមជំនាន់នោះគឺ

ភារិទ្ធៈ ហើយចុះមកដល់ភូមិរយៈពេលប៉ុន្មានបានគេចាប់ផ្តើមចែកអង្ករហើយមានការហូបរួមអី?

រ៉ាឌីៈ មកភូមិនេះដូចខ្ញុំចាំបានថារយៈពេលមួយឆ្នាំ ដូចមិនទាន់បានមួយឆ្នាំយូរទេ គេចាប់ផ្តើមរៀបកងអាំ

ភារិទ្ធៈ បាទ

រ៉ាឌីៈ ប៉ុនតែអាការរៀបកងហ្នឹង ដំបូងគឺអ្នកថ្មីហ្នឹង គេរៀបកងដែលនៅភូមិយើងហ្នឹង គេធ្វើជាកងហើយ ប៉ុន្តែគេមិនទាន់បានរៀបថាកងនារី កងមេម៉ាយ កងយុវជន កងចាស់ៗ

ទេ

ភារិទ្ធៈ បាទ

រ៉ាឌីៈ ក្រោយពេលមួយឆ្នាំក្រោយមក គេចាត់ថា អោះ ចាស់ៗ អ៊ីក្រុមចាស់ៗ គឺទៅនៅកង ចាស់ៗទៅ មានក្រុមកងភ្ជួរកងអីហ្នឹង ចាស់ៗហ្នឹង ហើយកងនារីអញ្ចឹងទៅ ហើយម៉េម៉ាយហ្នឹងគេដាក់មួយក្រុមកងម៉េម៉ាយអញ្ចឹងទៅ ហើយកុមារជំទើអញ្ចឹង គឺនៅក្រុមកុមារជំទើអញ្ចឹងទៅ ហើយកុមារតូចហ្នឹង នៅកងកុមារតូចអញ្ចឹង អញ្ចឹងអ្នកកងកុមារតូចនៅក្នុងភូមិ នៅសហករណ៍គឺនៅក្នុងភូមិហ្នឹង ហើយអាកងចាស់ៗ គឺនៅសហករណ៍ផ្សេងផ្សេងទៅ ហើយអញ្ចឹងអារយៈពេលដែលជួបប្ដីប្រពន្ធគេ គេពេលលួចទៅ គេអោយ ១០ថ្ងៃ ជួនកាលឆ្ងៀតមកបានបន្តិចៗ ជួនដោយឡែក ដោយឡែកពីគ្នាអញ្ចឹង បើកាត់ផ្ដាច់មនោសញ្ចេតនា ប្រពន្ធកូន វា កាត់ផ្ដាច់នៅមួយក្រុមៗ

ភារិទ្ធៈ ហើយចុះការងាររបស់ហូបចុករស់នៅយ៉ាងម៉េចដែរ?

រ៉ាឌីៈ ការហូបចុកហើយការរស់នៅ បើនិយាយពីការងារ វាស្ទើរពីហួសកំលាំងទៅហើយ ហើយអាហូបចុកក៏អញ្ចឹង មិនដែលបានឆ្អែតគ្រប់គ្រាន់ទេ បានឆ្អែតគ្រប់គ្រាន់ទេ បើខ្ញុំនិយាយពីនៅសម័យខ្មែរក្រហមមានឋានៈត្រឹមជាសេដ្ឋកិច្ចកងមួយហ្នឹងវា ស្ទើ សឹងតែថា ពាក្យឥលូវ វាស្ទើនឹងចៅហ្វាយខេត្តទៅហើយ

ភារិទ្ធៈ អូ

រ៉ាឌីៈ ព្រោះគេមានលទ្ធភាពគ្រប់គ្រាន់នៅក្នុងការហូបចុក ឯដូចខ្ញុំហ្នឹង អ្នកពលកម្មផ្ទាល់ហ្នឹង គេមកដល់ គេវាស់បបរ ទឹកៗអោយហូបហ្នឹង មួយប្រចូចៗៗប៉ុណ្ណឹង ឆ្អែតក៏ប៉ុណ្ណឹង មិនឆ្អែតក៏ប៉ុណ្ណឹង អញ្ចឹង ពលកម្មធ្វើកាន់តែកើនខ្លាំងហើយការហូបចុកអី វាតិច អញ្ចឹងយើងឆ្ងៀតអាការធ្វើការហ្នឹង មើលក្ដាមមើលខ្យងអី ដែលនៅសងខាងផ្លូវ មិនមានលទ្ធភាពដើររកទេ វេទនាណាស់ មិនមានលទ្ធភាព ដើរទៅជួនគ្នាអញ្ចឹងទៅ វា ដូចឃើញរូបភាពខ្លះ វាការពិតអាំ ហើយខ្ញុំជឿថាមានអ្នកដែលឆ្លងកាត់ ជាងខ្ញុំច្រើនទៀត ខ្ញុំស្គាល់ឆ្អែត

ភារិទ្ធៈ ការងារអីខ្លះដែលគេអោយបង?

រ៉ាឌីៈ ការងារដែលគេធ្វើ ដូចជាខែនេះ គេអោយដើរបោចស្ទូងស្រូវ អាហ្នឹងពេលដែលខែហ្នឹង

បានធូរបន្តិច តែបើខែច្រូត ច្រូត ខែច្រូតហើយលើកបន្ទាយ ខែដើមឆ្នាំ ដែលភ្លៀងធ្លាក់មក គឺវាអោយលើកដីដំបូកចាក់ស្រែ ហើយគេដើរក្រុមហ្នឹង គឺចល័ត មានតែនៅក្នុងឃុំញ៉ែងញ៉ង ហ្នឹងទេ ទៅលាយបូរ ទៅ ចំការសៀង លើងព្រៃ លើងភ្នំ ដែលគេរៀបធ្វើចំការ អញ្ចឹងការងាររបស់ខ្ញុំគឺពេញកំលាំងតែម្តង មនុស្សគេហៅពេញកំលាំងពេញទំហឹង

ភារិទ្ធៈ ហើយចុះបងមានដែលបានជួបម្តាយ ជួបអីដែរ?

រ៉ាឌីៈ ខ្ញុំបានជួបក្រោយពេលដែលបានលឺថាមានខ្មែរ១៧ មេសា អាជ័យជំនះរបស់គេនោះ អាហ្នឹងគេអោយមក ពេលហ្នឹង

ភារិទ្ធៈ ធ្វើខ្លួបធ្វើអីហ្នឹង

រ៉ាឌីៈ រហូត ដល់ បង្ហើបពីជីវិតខ្ញុំបន្តិច ខ្ញុំនៅចំការសៀង ចាញ់ ដល់តែចាញ់ទៅគ្រាន ម្តាយខ្ញុំនៅក្បាលពោធិ៍កាលពីកើតណោះ ខែហ្នឹងគេអោយទៅ អេ មូលស្មោ ដើម្បីធ្វើស្រែប្រាំង សំរាប់ស្រែប្រាំង អញ្ចឹងគ្រានខ្ញុំមកដេកនៅផ្ទះនេះ សុំគេបានមកនៅផ្ទះ ហើយម្តាយមិនដឹងជានៅឯណាទេ ហើយការដែលទំនាក់ទំនង ខាង ពត៌មានវិទ្យាហ្នឹង គឺយើតគេមានតិចណាស់កាលហ្នឹង ផ្តាំអ្នកដែលគេដឹកអង្ករដឹកអី ខាងសេដ្ឋកិច្ចហ្នឹង ជួនក៏គេនឹកឃើញ គេប្រាប់ទៅ ជួនក៏គេអាណិតគេប្រាប់ ពិសេសដូចជាក្រុមគ្រួសារខ្ញុំ គេមិនសូវចាប់អារម្មណ៍នៃការផ្តាំប៉ុន្មានទេ ព្រោះថា វា ឪពុកត្រូវគេសម្លាប់ ប្តីក៏គេយកទៅសម្លាប់ក្បត់អង្គការគេ អញ្ចឹងខ្ញុំនៅដេកចាំម្តាយហ្នឹង រហូតដល់តែ ហើយចុះកាលណោះថ្នាំសង្កូវយើងមិនមាន ឬសឈើ ឬសជ័រអីហ្នឹង ចេះលើក ចេះតែដឹកអីទៅ ចាស់ៗ អី គេរកអីអោយដឹកអីអញ្ចឹង ហើយបានជាអីមកវិញអញ្ចឹង ហើយម្តាយក៏មិនបានមក នេះគ្រាន់ងារញ៉ាក់ ស្តមប៉ិនហ្នឹងដែរ ហូបចំណីអី កាលហ្នឹង មិនមែនដូចបច្ចុប្បន្ន ឧទាហរណ៍កូនឈឺ យើងពឹងគ្រូពេទ្យយ៉ាងម៉េច បើ ជ្រែកមែក ជ្រែកដីមកដល់ បើមិនបានអី ក៏យើងដឹងតាមរយៈពត៌មាន តាមអីហ្នឹងទៅ អាហ្នឹងបើសិនជាដឹង ក៏មិនងាយសុំគេបានដែរ បាទ ឈឺគឺមានពេល អញ្ចឹងគេអត់មើលទេ មិនបាច់យើងទៅមើលទេ ហើយពាក្យនេះគឺប៉ុល ពតគេប្រាប់ ជំនាន់នោះ គឺគេប្រើអញ្ចឹង បើកូនឈឺ ដល់តែកូនមានពេទ្យហើយ ហើយថាមិនបាច់ទៅមើលទេ មិនមែនពេទ្យទេ អាហ្នឹងបើនិយាយពីការកាត់ផ្តាច់

មនោសញ្ចេតនា កាត់ផ្តាច់មនោសញ្ចេតនាគឺមានតែអញ្ចឹង

ភារិទ្ធៈ ហើយចុះដូចបងដែលមានឪពុកស្លាប់ អីដែលគេចោទថាក្បត់អីអញ្ចឹងអាំ ដូចធ្វើការជាមួយគេអីយ៉ាងម៉េចដែរ

ភ៉ឌីៈ បានដល់ពេលទៅធ្វើការជាមួយគេ គេបង្គាប់ គេថាអោយអញ្ចឹងដែរអ៊ីដែល យើងទៅយូរៗទៅ វាគ្មានសិទ្ធ សេរីភាព នៅក្នុងការនិយាយត វាគ្មានហេតុផលអីអាំ ដូចយើងអត់មានហ្នឹង ដូចរស់នៅហ្នឹង ដូចក្រៀមក្រំនៅក្នុងចិត្តសូម្បីតែបើមូលដ្ឋានក្មេងប៉ុនហ្នឹងក៏ត្រូវតែខ្លាច ក៏ត្រូវតែគោរពគេដែរ ជៀសវាងគេដឹងដូចថា បើសិនជាអាចលាក់បានប្រវត្តិឪពុកកាលពីរបបប៉ុល ពតហ្នឹងលាក់ទៀតមិនអោយក្មេងក្រោយវាដឹងទេ បើក្មេងណាវាមិនដឹងអាអាំ តែបើក្មេងណាវាដឹង ក៏យើងនិយាយអីក៏បាន ជាមតិគំនិតរបស់យើង និយាយទៅដូចថាធ្វើអញ្ចេះទៅវាល្អគេមិនទទួលស្គាល់ទេ អានេះបើនិយាយរួម

ភារិទ្ធៈ ហើយចុះគេមានបែងចែកអាអ្នកដែលមានឪពុកស្លាប់ អោយធ្វើការផ្សេង?

ភ៉ឌីៈ កាលជំនាន់នោះដូចមិនមានទេ អោយធ្វើការជាមួយគេ បានចូលរួមជាមួយគេ ហើយការធ្វើការងារហ្នឹងដូចខ្ញុំជំរាបហើយថាដូចមនុស្សយើងមានអ្នកខ្លះ ពូកែហើយអ្នកខ្លះមិនពូកែ ខ្លះក៏ចំណាប់ ហើយខ្លះក៏មិនចំណាប់ អញ្ចឹងអាក្រុមដែលមិនសូវចំណាប់ហ្នឹង គេដាក់អោយមួយក្រុមមិនសូវចំណាប់អញ្ចឹងទៅ ហើយក្រុមចំណាប់ហ្នឹង គេលើកដៃលើកជើងពិសេស គេកងគេអីអញ្ចឹងទៅ ប៉ុន្តែអាការដែលហូបចុកដូចគ្នាទេ ប៉ុនតែដូចថារបៀបបញ្ចោរអាំ បាទអាក្រុមចំណាប់ឯងធ្វើបានជោគជ័យគេមានទង់ជាតិគេមួយ គេអោយកាន់

<u>Side B:</u>

ភ៉ឌីៈ ហើយអាអន់ជាងគេ គ្នាដើរទៅ គ្នាអន់ជាងគេរហូតអាំ

ភារិទ្ធៈ បាទ

ភ៉ឌីៈ ហើយបើយើងវាបន់អី

ភារិទ្ធៈ ហើយចុះបងជំនាន់ប៉ុល ពតហ្នឹង អំពើ ហើយសកម្មភាពអីខ្លះដែលខ្មែរក្រហមចាត់ទុកថាជាកំហុស ហើយបងធ្លាប់ខុសអីទេ?

ភ៉ឌីៈ ចំពោះបញ្ហាកំហុសរបស់មនុស្សនៅក្នុងរបបប៉ុល ពតនេះ វាដូចជាមិនធ្ងន់ធ្ងរទេ ហើយ

កំហុសដែលភាគច្រើនដែលកំហុសនៅក្នុងរបប ប៉ុល ពត មិនមានកំហុសដោយសារកាប់សម្លាប់ រឺកំហុសដោយសារការគុំគួនទេ ភាគច្រើនគឺកំហុសទៅលើការរៀនជីវភាពហ្នឹង ឯងដែលចាប់បង្ខំអោយមនុស្សបេះលួច បេះលាក់បេះលៀមហ្នឹង គឺបញ្ហាទៅលើក្រពះ អ៊ីដែលហូបមិនគ្រប់គ្រាន់គឺបេះតែមានគំនិតថា ត្រូវកែច្នៃយ៉ាងម៉េចអោយបានហូបឆ្អែត អោយបានគ្រប់បំពេញក្រពះ អញ្ចឹងវាច្នៃរហូតដល់ផ្លែអំពិលខ្ចីរបស់យើងដែលខ្ញុំនិយាយប្រវត្តិបន្តិចៗដែលខ្ញុំរស់នៅជាកងអាំ អំពិលខ្ចីជាមួយម្ទេសយើងនេះ បួនសាកមើល អត់ហិលទេ ដាក់អំពិលមួយម៉ាត់ ម្ទេសមួយកំណាត់អោះ បើហិល អត់ហិលទេ ឆ្ងាញ់ ហើយផ្អែមទៀត អញ្ចឹងវាយើងយប់ឡើងគឺមានតែអាហ្នឹង ដែលយើងអាចបេះបានដោយគេមិនយកទោសពៃរ៍ ផ្សៀតបេះអាហ្នឹងបានដោយគេមិនយកទោសពៃរ៍ ដូចជាអំពិលហ្នឹង ដូចថាវានៅគ្រប់ទីសាធារណៈហ្នឹង គឺយើងអាចបេះបានហើយ យើងយប់ឡើង ឡើងមួយថ្នក់អីអញ្ចឹងទៅ មួយការ៉ង់ ហ្នឹង បន្តិចនាំគ្នាដុតចង្កៀងហូបអញ្ចឹងទៅ ដើម្បីបំពេញក្រពះ ក្រោយពេលដែលធ្វើការងារ ហើយចុះបបរយើងប៉ុណ្ណេះៗ យើងគិតថាម៉េចធ្វើទៅរួចមួយអាហ្នឹងទៅ ទំរាំដេកទៅលក់ទៅ រៀបភ្លឺបានឡើងទៅ

ភារិទ្ធៈ ហើយអញ្ចឹងបងអត់មានដែលខុសអីទេ?

រ៉ាឌីៈ ខ្ញុំបើនិយាយពីកំហុសអាការនេះវាមិនធ្ងន់ធ្ងរ ដូចខ្ញុំហ្នឹង ខ្ញុំមានអារម្មណ៍ មានរឿងដែលឪពុកត្រូវគេសម្លាប់ទៅហើយ ហើយអញ្ចឹងខ្ញុំមិនត្រូវធ្វើអីដែលខ្ញុំទ្រាំបាន ខ្ញុំទ្រាំ មិនធ្វើអី អោយខុសតទៅទៀតទេ វាខ្លាចវាគំនុំកាន់តែធ្ងន់មកលើហ្នឹង អញ្ចឹងខ្ញុំទប់តែសភាពការណ៍ តែគេនិយាយប៉ុនហ្នឹង ខ្ញុំមិនចង់ជាប់ហើយ ឃើញកំហុសមួយដងដែរ បើគេយកទៅ គឺលួចដំឡូង ទៅលួចដំឡូងគេ ដែលគេហៅទៅណែនាំ រយៈពេលជាពីរម៉ោងដែរ

ភារិទ្ធៈ ប្រធានកងគេ?

រ៉ាឌីៈ បាទ ប្រធានកង ហើយខ្ញុំក៏ព្យាយាម ទោះបីម៉េចខ្ញុំខំព្យាយាមអត់ធ្មត់ទ្រាំហើយ ព្រោះគេមាននិន្នាការអញ្ចឹងទៅហើយ មួយទៀតគឺជាមុខសញ្ញាដែលគេចាប់អារម្មណ៍ទ្រាំរស់អញ្ចឹងទៅ

ភារិទ្ធៈ ហើយបងហ្នឹងឈ្មោះអី? ហើយគេជាអ្នកមូលដ្ឋានអេក៏?

រ៉ាឌីៈ បាទ គេជាអ្នកមូលដ្ឋាន ប្រធានកងខ្ញុំនេះ វាមិនមែនជាមួយជាពីរ ជាបីពិតប្រាកដទេ

វាមានច្រើន

ភារិទ្ធៈ អូ

វ៉ាឌីៈ គឺវាមានច្រើន ពីកងមួយទៅកងមួយ ហើយជួនកាលគេដូរប្រធានមួយទៀតទៅ ហើយពេលខ្លះដូចថាក្រុមខ្ញុំហ្នឹង នៅក្នុងកងយុវជន បើនិយាយពីកងយុវជន មានប្រធានមួយ ប្រធានអីឈ្មោះម៉ុន ប៉ុន្តែម្នាក់ហ្នឹងដូចគេឆ្នាំ៧៩ វៀតណាមចូល រត់ទៅលើទៅ បាត់របូតទៅ អាហ្នឹងគេមានកង ប្រធានកងយុវជនឃុំគេមួយទៅ ហើយមានអា អា អាប្រចាំក្រុមនេះ អានេះដូចយើងគិតថា ដូចប្រធានប្រចាំក្រុមនេះ មានមួយកងៗទៀតទៅ ប៉ុនដូចជាអ្នកអស់ហ្នឹងបាត់មិនដែលឃើញមុខ ដូចជាទៅឯណាមកណាបាត់អស់ទៅ

ភារិទ្ធៈ ហើយចុះបងខ្ញុំចង់ដឹងថាពេលដែលវៀតណាមវាយចូល៧៩ហ្នឹង បងមានភៀសខ្លួនរឺក៏ទៅនៅឯណាទេ?

វ៉ាឌីៈ ខ្ញុំនៅឆ្នាំ១៩៧៩ មុនថ្ងៃ៧ មករា ហ្នឹង គឺខ្ញុំនៅភូមិញៀងញៀងហ្នឹងឯង បាទ ហើយថ្ងៃ៧ មករានេះ គឺខ្ញុំកំពុងតែច្រូតស្រូវ គឺច្រូតនៅវាលបឹងខាងកើត ដែលគេហៅថា វាលបឹង វាលបឹងៗ ខាងកើតថ្នល់ អញ្ចឹងបានដល់ម៉ោងប្រហែលជា៩ ប្រជាជនយើងមួយចំនួន ចេះតែមុជពីក្រោមឡើងមក គេថាយួនវាយឡើង វាយឡើងហើយ ហើយយើងក៏ក្តាប់ពត៏មានមិនបានច្បាស់ អ្នកដែលឡើងមក ចេះតែឡើងទៅ បើគេមិនបានយកទៅសាកសួរ យើងនៅតែច្រូតអញ្ចឹង បន្តការច្រូត របូតដល់ខាង ឃើញរថយន្តដាក្សួនដផ្អែរបស់វៀតណាមមកដល់ មកដល់បាននាំគ្នារត់ បានចាប់ផ្តើមរត់អាំ បើចំពោះខ្ញុំ ខ្ញុំរត់ប្រណាំង បាទ ខ្ញុំរត់ខាងកើតថ្នល់ ខ្ញុំរត់ប្រណាំង អារថក្រោះហ្នឹង ឡានហ្នឹងដើម្បីអោយបាន មាននៅពីមុខ ច្រកខាងលិច ដល់តែរត់អត់រួច មកជាប់ខាងមុខ កងហ្នឹងជាប់ប៉ុល ពតប្រហែលជាបន្តិចបន្តួចដែរទេណា ប៉ុនតែក្សួននៅហែររត់អត់រួច នៅឆ្លងកាត់ហ្នឹង កាត់ក្សួនហ្នឹងទៅ ប៉ុនតែនៅក្នុងនោះ វា កាន់ហ្នឹងដៃ ខោអាវដែលថាកម្មសិទ្ធមានខោមានភួយ ដូចគេ ចោលទាំងអស់ អត់មានបានយកមកទេ មកតែខ្លួន ប្រះមករកម្តាយដល់ជួប មកដល់ភូមិនេះ គាត់ទៅផ្ទះ ម្តាយគាត់ឡើងមកលើបាត់ទៀតហើយ ហើយមកជួបនៅកោះក្អែកនេះ ចេះតែសាកសួរ អញ្ចឹង មកកោះក្អែក ប៉ុនតែខ្ញុំមិនបានទៅឆ្ងាយទេ ខ្ញុំក្រវិលក្រវោះៗ មកវិលទៅវិញ ដូចខ្ញុំមិនបានទៅឡើងភ្នំអីណា ទៅលះបង់ លះអី

ទេ ព្រោះកាលដែលគេឃោសនា គឺ ជួបមួយសំលាប់ ជួបពីរសំលាប់ពីរអីអញ្ចឹងអា៎ ប៉ុន ដល់តែពេលអញ្ចឹង ទៅក្បួនហ្នឹង គេអត់ធ្វើអីខ្ញុំផង គេមកហែ ថាអឺ ដូចមិនសំលាប់ទេ ដឹង បាទរៀបហ្នឹងគិតអា៎ ហើយម្ដាយខ្ញុំអីគាត់ ហើយបើទឹកឃើញដើងខ្លី គ្មានរទេះ គ្មាន គោ ដឹកអង្ករអីហ្នឹងគេ ក៏កាបុលកាប៉ុប រែកពេញទៅ ទិញអង្ករលើនេះទៅ

ភារិទ្ធៈ ហើយចុះបានជួបជុំគ្នាប៉ុន្មាននាក់ដែរ?

រ៉ាឌីៈ កាលហ្នឹងខ្ញុំបានជួបជុំគ្នាតែបីនាក់ទេ គឺម្ដាយខ្ញុំ ប្អូនខ្ញុំ ហើយនិងខ្ញុំ

ភារិទ្ធៈ ហើយចុះអ្នកដែលបាត់ក្រោយបងមានដែលស៊ើបសួរតាម?

រ៉ាឌីៈ អ្នកដែលបើកក្រោយនេះហ្នឹងមក វាអ្នកខ្លះក៏វាចូលទៅដល់ឡើងជាមួយកងទ័ពគេហ្នឹង ខ្លះ ក៏ចូលធ្វើទ័ពរបស់ខ្មែរក្រហមហ្នឹងទៅ ខ្លះក៏វិលត្រឡប់មកវិញ ប៉ុនតែពេលវិលត្រឡប់មក វិញ គឺថាស្រុកទេសឯណាគឺលីដំណើងវិញ ព្រោះអាថ្ងៃក្រោយថ្ងៃ១៧ មេសាហ្នឹង គឺ គេជម្លៀសមក មិនមែនតែថាតែស្រុកគេទេ ខ្ញុំវាហាក់ដូចជាមានសំណាងជាងគេបន្តិច ដោយថាខ្ញុំមកដល់ស្រុកទេ តែប្រជាជនដទៃទៀតដែលចេញពីភ្នំពេញចេញពីទីរួមខេត្ត តាកែវហ្នឹង មិនបានមកស្រុកទេសទេ គឺគេកៀងថា ឥលូវមកដល់ផ្លូវនេះ ត្រូវតែទៅ ផ្លូវហ្នឹង បើមិនទៅផ្លូវហ្នឹង គឺគេសម្លាប់ អឺ គេថាទៅចុះ ខ្ញុំទៅណោះថា អត់ ទេ ដល់ ទៅ ទៅត្រឹមប៉ុន្មានឈប់ត្រឹមហ្នឹងទៅ នៅត្រឹមហ្នឹងទៅ ដល់តែ៧៩ហ្នឹង អញ្ចឹងគេ អញ្ចោះ ស្រុកទេសគេនៅឯណាគេទៅហ្នឹងវិញទៅ ដោយឡែកខ្ញុំស្រុកទេសនៅតែនេះទេ ដល់តែស្រុកទៅ ក៏ក៏វិលមកហ្នឹងវិញមក មិនអាចវិលទៅណាវិញទេ

ភារិទ្ធៈ ហើយចុះក្រោយពី៧៩ បានមកជួបជុំនៅ ជាមួយគ្នាអ្នកដែលបានមកជុំគ្នាហើយដូចថា អ្នកដែលបាត់ហ្នឹង បងមានដែលស៊ើបសួររកដូចថាឪពុកដែលបាត់?

រ៉ាឌីៈ ខ្ញុំស៊ើបសួរដែរ ប៉ុន្តែដូចថាវាមិនបានលទ្ធផលអា៎ គឺគេនៅវិភាគច្រើន ៩៩ភាគរយគឺគេ និយាយថាគាត់ស្លាប់ ហើយមួយភាគរយដែលថាគាត់មិនទាន់ស្លាប់ហ្នឹង គឺរូបខ្ញុំហ្នឹងហើយ ដែលបាត់ហាក់ដូចជារបស់មួយដែលបាត់ បាត់ដែលមិនដឹងមូលហេតុអា៎

ភារិទ្ធៈ ហើយចុះឥលូវនៅតែចេះស៊ើបសួរដេញដាល?

រ៉ាឌីៈ ខ្ញុំរហូតដល់នេះ ខ្ញុំនៅតែស៊ើបសួរ ខស្សរាហ៍សួរនាំប៉ុន្តែខ្ញុំដឹង ខ្ញុំមានជំនឿថាគេសម្លាប់គាត់ ហើយព្រោះរយៈពេល៧៩មកដល់ពេលឥលូវនេះ វាជាង២០ឆ្នាំ បើសិនជាគាត់នៅរស់

វាត្រូវគាត់ស្រាវជ្រាវពីប្រពន្ធកូន អញ្ចឹងការស្លាប់របស់គាត់ គឺពិត

ភារិទ្ធៈ បងថាស៊ើបសួរ គឺស៊ើបសួរយ៉ាងម៉េច?

រ៉ាឌីៈ ខ្ញុំស៊ើបសួរ បើចង់ដឹងសំខាន់បំផុត គឺចង់ដឹងថា តើគេយកគាត់ទៅសំលាប់នៅកន្លែងណា ហ្នឹងឯង អាហ្នឹងគឺជាគំនិតផ្តើមរបស់ខ្ញុំ គឺសួរតែប៉ុណ្ណឹង សួរដឹងថា ដែលលឺគេថា ខ្ញុំជឿថាគាត់ស្លាប់មែនទែនហើយ អ្នកឯងរត់រួចទេ

ភារិទ្ធៈ អញ្ចឹងបងអើ ទាក់ទងប្រវត្តិបងអំបាញ់មិញហួរហែអំបាញ់មិញខ្ញុំសួរចប់ហើយ ប៉ុន្តែខ្ញុំគ្រាន់តែចង់ដឹងហេតុការណ៍អើ វន្ទត់អីផ្សេងទៀត ក្រែងលំ បងធ្លាប់ជួបប្រទះដោយផ្ទាល់ខ្លួនរឺក៏ធ្លាប់បានឃើញ ហើយក៏ធ្លាប់លឺគេនិយាយអាំ

រ៉ាឌីៈ បាទ

ភារិទ្ធៈ ហើយទី១ខ្ញុំចង់សួរថាកាលពីជំនាន់ប៉ុល ពតហ្នឹង ខ្លួនបងផ្ទាល់មានអើ ជួបប្រទះការខ្វះខាតម្ហូបម្ហា?

រ៉ាឌីៈ ខ្វះ

ភារិទ្ធៈ ហើយចុះអ្នកដទៃបងឃើញគេខ្វះខាតអញ្ចឹងដែរទេ?

រ៉ាឌីៈ បងនិយាយពីនៅក្រុមកងជាមួយគ្នា កាលនោះយើងពត៏មានមិនបានទាក់ទងវែងឆ្ងាយទេ ប៉ុន្តែអ្នកដទៃក៏ដូចខ្ញុំអញ្ចឹងដែរ

ភារិទ្ធៈ ហើយចុះមានដែលលឺអ្នកផ្សេងនិយាយថា ខ្វះខាតហូបចុកអញ្ចោះមួយៗមានធ្លាប់លឺ?

រ៉ាឌីៈ លឺដូចជា បើសិនជាអ្នកដែលហូបគ្រប់គ្រាន់មានតែអ្នកចុងភៅ សេដ្ឋកិច្ចគេហ្នឹងឯង

ភារិទ្ធៈ ហើយចុះមានធ្លាប់លឺថាគេនិយាយថា ហូបមិនឆ្អែតអីមួយ អញ្ចោះមួយធ្លាប់លឺទេ?

រ៉ាឌីៈ មាន ប៉ុនតែនេះមិនហ៊ាននិយាយលឺទេ

ភារិទ្ធៈ អូ

រ៉ាឌីៈ និយាយបានតែអ្នកដែលយើងស្គាល់គ្នា ទុកចិត្តគ្នា បើជាមួយបើគេសួរថាឆ្អែតឥលូវ ត្រូវតែឆ្អែតហើយ ឆ្ងាញ់ទេ ថាឆ្ងាញ់ បាទសម្ល

ភារិទ្ធៈ មានអ្នកណាដែលថាមិនឆ្អែតហើយគេធ្វើអីទេ?

រ៉ាឌីៈ ដូចជាមិនមាន ប៉ុនតែមានកងនៅកងយុវជនជាមួយខ្ញុំហ្នឹងគ្រាន់តែមានរឿងរ៉ាវខ្លះ ដូចថាម្នាក់ហ្នឹង កាលខ្ញុំនៅចាំបានគាត់លុន ណុល គាត់រៀននៅបរិញ្ញា ហើយដល់តែគាត់ចេញ

មកហ្នឹង គាត់ស្តាយយកចេញមកទេ ដូចថាអ៊ីដែលធ្វើទៅ វា ធម្មតាគេអ្នកបេះ គេបេះ តែមានគំនិត ហើយគាត់ដែលជាអ្នកចិត្តធូត់ឃើញគេថាអញ្ចឹង ឃើញអីថាហ្នឹង មនុស្ស យើងច្រើនតែមានចរិកអាំ ឃើញអីថាហ្នឹង

ភារិទ្ធៈ អូ

រ៉ាឌីៈ ហើយដូចគាត់ហ៊ាននិយាយហ៊ានថា ក្រោយពេលបាននេះទៅ ឃើញគេយកទៅសម្លាប់ ដែរ ហើយចុះការដឹកនាំអ្នកលួង់ជំនាន់ប៉ុល ពត ដូចខ្ញុំជំរាបពីដើមអញ្ចឹងថាភាគច្រើន គេ យកតែអ្នកលួង់ អ្នកក្រពីសម័យនោះ ដូចថាវាមិនដឹងជារកស៊ីស្អី ខ្ជិលហើយក្រល្ហែម ល្ហាម នោះដល់តែពេលកងរំដោះបានគេយកអ្នកហ្នឹង អាហ្នឹងគេថា អ្នកហ្នឹងប្រវត្តិ ស្អាត ស្អំអីអញ្ចឹងអាំ មកធ្វើថ្នាក់ដឹកនាំ អញ្ចឹងបានមានសុភាសិតខ្មែរមួយពោលថា ភ្លៅ ភ្លេច អំបែងអណ្តែតអីអញ្ចឹងអាំ ជំនាន់នោះ គេមាន

ភារិទ្ធៈ ហើយចុះបងខ្ញុំចង់ដឹងជំនាន់ប៉ុល ពតហ្នឹង បងមានដែលឈឺស្កាត់ អើ គ្មានថ្នាំព្យាបាល ទេ?

រ៉ាឌីៈ ខ្ញុំដូច ខ្ញុំជំរាបអញ្ចឹង ខ្ញុំឈឺគ្រុនហ្នឹង

ភារិទ្ធៈ អូ

រ៉ាឌីៈ គ្រុនហ្នឹង ហើយនិងដំបៅ ដំបៅហ្នឹងអាំ ដំបៅយួនរបស់ខ្ញុំមានស្លាកស្នាមនៅជើងទាំងសង ខាង គឺខ្ញុំជាទៅលើ ថ្នាំសម្លាប់សត្វល្អិត ដល់តែយើងគ្មានថ្នាំអីព្យាបាលទេ អញ្ចឹងថ្ងៃមួយ ដែលខ្ញុំយកអោយទៅរែកដីមុនដំបូង វាឃើញហាក់ដូចជា ប៉ឹក១១ គេលាបសំរាប់បាញ់ អើ ស្បែកទ្រើង បាទអាដឹទទេ ថ្នាំសំលាប់សត្វល្អិតនេះ ហើយខ្ញុំទៅដល់លូកចូលទៅ អាដែង ថ្នុកយក ក្រឡាស់ដូងខ្ទះទៅបៀកទៅលើអាដំបៅយួនហ្នឹង ទទេហ្នឹង ដល់តែពី បៀកហើយនិយាយពីវាក្តៅ ក្តៅ ដល់តែក្តៅ ជាប់ប្រហែលជាបីម៉ោង សាច់ដំបៅគេ ឡើងរលួយ បាទ ឡើងរលួយ បាទ ខ្ញុំនិយាយអញ្ចឹង ជាការពិតវាឡើងរលួយហ្មង ដល់ តែរលួយ ខ្ញុំចាប់ផ្តើមខ្ទះអាសាច់រលួយហ្នឹងចេញ

ភារិទ្ធៈ បាទ

រ៉ាឌីៈ ដល់តែខ្ទះអាសាច់រលួយហ្នឹងចេញ វាដុះសាច់ថ្មីមកវិញ បាទវាឃើញថា ដូចជាទេវតា តាមជួយដែរ ក៏ថាដែរ បាទ អត់ដែលមានថ្នាំពេទ្យ ដាក់អីទេ ហើយជំនាន់នោះ ទើស

អីបន្តិចក្ដាយទៅជាដំបៅយូនហើយ អាដំបៅធំ ៗ ស្នាកស្នាមអីដល់បច្ចុប្បន្ន

ជាតិៈ ដំបៅយួន?

រ៉ាឌីៈ បាទ ខ្ញុំចេះតែច្រើននិយាយលេងថា អូបើដំបៅនៅហ្នឹងជើង មានអីជាងអីទ បើរឿងពិត របស់ខ្ញុំគឺអញ្ចឹងមែន អានេះដាក់ទៅវាឆ្អិនហូង បាទ វាឆ្អិន រលួយឆ្អិន

ភារិទ្ធៈ ហើយចុះអ្នកដទៃបងមានឃើញគេឈឺស្កាត់ដោយគ្មានថ្នាំព្យាបាលទេ?

រ៉ាឌីៈ បាទ មាន មានមន្ទីរពេទ្យគេនៅវត្តតាតៃនេះហ្នឹងឯង ប៉ុនតែការព្យាបាល ខ្ញុំធ្លាប់ដេក ទៀតនៅវត្តតាតៃ ហ្នឹងដែរ អាដំបៅយួនហ្នឹង ដេកមិនជា វាហាក់ដូចជាគ្មានថ្នាំអីព្យាបាល អោយពិតប្រាកដក្រៅពីយើងលាងទឹកអំពៅ ស្លឹកអំពិលអីនៅខ្លួនយើងហ្នឹង ហើយថ្នាំ ក្រហម ថ្នាំអីលាបហ្នឹង តែប៉ុណ្ណឹង ប៉ុនតែវា បើយើងបានដេកពេទ្យ បាយយើងហូប មិនឆ្អែត តែវាធូរបន្តិចវាមិនបានបញ្ចេញពលកម្ម ហើយកាលណោះនិយាយអោយត្រង់ ទៅ វាសតិអារម្មណ៍ក៏ថាបានដែរ វាខ្ជិលច្រអូសក៏ថាបានដែរ តែពលកម្មវាហួស

ភារិទ្ធៈ វាធ្វើហត់ពេកអេ?

រ៉ាឌីៈ បាទ ហត់ពេក បាទ បើមិនសំរាក ក៏ឈឺ ខ្លះដែរ បើគេតាមដានអីមិនស្រួលជួនគេបង្អត់ ដែរ ខ្ញុំខស្សាហ៍មានកំហុសឆ្គង ខំអត់ងងុយ អស់កំលាំងពេកទៅ វាត្រឹមតែរៀបភ្លឺ ថា បន្តិចឡើងរួច កុហកគេថាចុកពោះអីអញ្ចឹងទៅ មកវិញគេថា អឺ បើចុកពោះបាយមួយ ពេលទៅបានហើយ អញ្ចឹងមួយថ្ងៃហ្នឹងបាយមួយពេលទៅ ហើយចេះតែសង្ងំដេកអញ្ចឹង ទៅ បបរមួយពេល បន្តិចៗអញ្ចឹងទៅ ហើយបើយើងឈឺដើរមិនបាននៅដេកកន្លែង ហ្នឹងទៅ ធ្វើរបៀបយើងអ្នកឈឺអា៎ នេះគំនិតបើថាទ្រាំលែងបានអា៎

ភារិទ្ធៈ អញ្ចឹងបងទាក់ទងនឹងការឈឺចាប់ដោយគ្មានថ្នាំព្យាបាល ក្រៅពីធ្លាប់ជួបប្រទះខ្លួនឯង រឺ ឃើញអ្នកដទៃ មានដែលឮគេនិយាយថា អ្នកខ្លះនៅកងផ្សេងពេលគេឈឺខ្លះខាតអីខ្លះ ឮគេនិយាយពីការឈឺស្កាត់ គ្មានថ្នាំ

រ៉ាឌីៈ ខ្ញុំសូមនិយាយពីបញ្ហានេះ វាលំបាកនៅក្នុងការសាកសួរគ្នា ណាស់ជំនាន់នោះ គឺកងរស់ នៅជាក្រុមៗ ដោយឡែកព្រលឹមឡើងចេញជាក្រុមជាកងរបស់ខ្លួន បាទ យើងថាអត់ បានទំនាក់ទំនងគ្នា ស្គាល់អ្នកនេះទៅអ្នកនេះឯងសួរអាម៉េចកងឯងរស់នៅយ៉ាងម៉េចអី យ៉ាងម៉េចទេ វាអត់មានបាន

ភារិទ្ធៈ ហើយចុះនៅក្នុងកងដូចគ្នាអត់មានដែលលឺគេនិយាយទេ?

រ៉ាឌីៈ បាទ អាកងដូចគ្នាគឺអញ្ចឹង គឺអត់ខ្វះខាតតាំងពីតូចដូចគ្នា បាទ សំខាន់គឺនៅក្នុងកងដូចគ្នា គេបានពត៏មានតែនៅក្នុងកងដូចគ្នាហ្នឹង

ភារិទ្ធៈ ហើយចុះការស្នាក់នៅអី ជំរកស្នាក់នៅ

រ៉ាឌីៈ ការស្នាក់នៅ គឺនៅជាជំរំ ជាក្រុម បាទ ជាកង ជាជំរំ ដូចថាតលូវផ្ទះចាស់មួយអញ្ចឹង ផ្ទះគាត់ហ្នឹង ក៏ធ្លាប់ដាក់កងកុមារនៅហ្នឹង ដែរ ហើយគាត់គេជម្លៀសចេញអញ្ចឹងនៅផ្ទះ ដល់តែនៅបោសនៅហ្នឹង ស្នាក់នៅហ្នឹងទៅ ព្រលឹមឡើងចេញទៅធ្វើការនៅជិតៗហ្នឹងទៅ លែងត្រីៗលែងអីទៅ

ភារិទ្ធៈ ហើយចុះអ្នកដទៃ បងឃើញគេខ្វះខាត ដូចគ្នាអញ្ចឹងដែរ?

រ៉ាឌីៈ បាទ ឃើញគេខ្វះខាតដូចគ្នា ហេវ ឃ្លានដូចគ្នាអញ្ចឹង ដូចខ្ញុំជំរាបថា ករណីតែចុងភៅដែលគេដែដល់គឺឆ្អែត

ភារិទ្ធៈ អូ

រ៉ាឌីៈ បាទ សេដ្ឋកិច្ចអ្នកដែលគេរកម្ហូបរកបន្លែហ្នឹង ក៏គេស្គាល់ទំនាក់ទំនងជាមួយចុងភៅ គឺឆ្អែត បើខុសតែពីហ្នឹងអ្នកពលកម្មដូចគ្នា គឺ មិនបានគ្រប់គ្រាន់ទេ ដោយឡែកមេកងនេះជារឿងមួយដែលគេហូបផ្សេងទៀត បើឆ្អែតអេមិនឆ្អែត យើងមិនបានដឹងទេ ប៉ុនតែគេមិនបានហូបចុកវង់ជាមួយយើងអីទេ បបរមួយកូនខ្ទាំប៉ុនហ្នឹង គ្នា ៦នាក់ អេក៏បួននាក់អីហ្នឹង គឺ មានតែប៉ុនហ្នឹង គឺបួននាក់ក្រុមយើងហ្នឹងមក ហើយដូចខ្ញុំ ដូចថាខ្ញុំជំរាបមក ដូចថាគ្រាន់តែហូបចុក ឪពុកដែលគេយកទៅសម្លាប់ក៏គេមិនសួរអោយចូលក្រុមគេអាអ្នកមូលដ្ឋានអ្នកអីដែលគេ មិនពាក់ព័ន្ធអីអញ្ចឹងអា៎ ហើយអោយឯងអីទៅសម្លាប់ ក៏ក្រុមផ្សេងដែរ ក្រុមដែលអន់ ក្រុមដែលគេថាធឹបអាពួកនេះអញ្ចឹងទៅណា ថាឈឺចាប់នៅចាំអាសំដីទាំងអស់ហ្នឹង

ភារិទ្ធៈ ហើយចុះបងអត់មានដែលគេចាប់ឃុំឃាំងទេ?

រ៉ាឌីៈ បាទខ្ញុំអត់ដែលទេ

ភារិទ្ធៈ មានឃើញ អ្នកដទៃគេចាប់ឃុំឃាំងទេ?

រ៉ាឌីៈ ធ្លាប់ឃើញគេចាប់យកបណ្តើរចេញទៅអញ្ចឹងដែរ ប៉ុន្តែមិនដឹងគេឃុំយកទៅដាក់នៅកន្លែង

ណាអីកន្លែងណា គេយកទៅបាត់ទៅ ទៅបាត់ទៅ យើងមិនបាន

ភារិទ្ធៈ ប៉ុន្តែឃើញគេឃុំ នៅកន្លែងគេឃុំ ?

រ៉ាឌីៈ បាទ ខ្ញុំអត់ដែល អត់ដែលទេ អត់ដែលឃើញគេឃុំ

ភារិទ្ធៈ ធ្លាប់លឺអាគេនិយាយឃុំឃាំងមនុស្សទេ?

រ៉ាឌីៈ អេ ជំនាន់នោះដូចជាមិនបាន ចាប់អារម្មណ៍ និយាយអោយរួមខ្ញុំអត់ដែលបានឃើញគុក ប៉ុល ពតហ្នឹងអីយ៉ាងម៉េចទេ

ភារិទ្ធៈ ប៉ុន្តែធ្លាប់លឺដែរ?

រ៉ាឌីៈ បាទ ធ្លាប់លឺថាទៅយកដាក់ មានគេឃុំមានគេអី អត់ដែលទេ អញ្ចឹងបានទទួលស្វែងអី ខ្ញុំមើលឃើញខ្មោះ ឃើញឃ្មាង អី ខ្ញុំភ្ញាក់ អឺ ប៉ុល ពតធ្វើដល់ថ្នាក់ហ្នឹង អឺ កាលហ្នឹង គេចងយកទៅ បាត់ បាត់ មិនដឹងគេយកដាក់គុកនៅឯណាអីណា មិនដឹង

ភារិទ្ធៈ ហើយចុះបងមានដែលរងរបួសរឺក៏គ្រោះថ្នាក់អីធ្ងន់ធ្ងរទេ?

រ៉ាឌីៈ ខ្ញុំធ្លាប់រងរបួសបន្តិចដែរ គឺការដែលលើកប្រឡាញអាំ លើកប្រឡាញហ្នឹង វាកាប់ត្រូវគ្នាទេ ជួនកាលវាធ្វែសប្រហែល វាដូចជាមិនចាំបាច់

ភារិទ្ធៈ ខ្លួនបងផ្ទាល់អាំ?

រ៉ាឌីៈ បាទ ខ្លួនខ្ញុំផ្ទាល់ហ្នឹង

ភារិទ្ធៈ ហើយចុះអ្នកដទៃ ដែលឃើញត្រូវរបួស អីទេ?

រ៉ាឌីៈ ធ្លាប់ឃើញដែរ លំ កាប់ប៉ះគ្នាអីអញ្ចឹងទៅ វាថាគ្រោះថ្នាក់ដោយចៃដន្យអាំ

ភារិទ្ធៈ ក្រៅពីធ្លាប់ជួបប្រទះផ្ទាល់ខ្លួនអញ្ចឹង ដែលឃើញអញ្ចឹងមានដែលធ្លាប់លឺទេ?

រ៉ាឌីៈ លឺ លឺ លឺ ធ្លាប់លឺបាទ វារឿងចៃដន្យកើតឡើងដោយគ្រោះថ្នាក់ អាហ្នឹងយើងប្រហែស ហ្នឹងការងារទេ អាហ្នឹង វាដូចជាមិនចាំបាច់អី ដល់តែ

ភារិទ្ធៈ ហើយចុះអាការប្រយុទ្ធតទល់នៅក្នុងសមរភូមិអីអញ្ចឹងធ្លាប់?

រ៉ាឌីៈ ខ្ញុំមិនដែលទេ

ភារិទ្ធៈ ហើយចុះធ្លាប់ឃើញ

រ៉ាឌីៈ ខ្ញុំធ្លាប់មកប្រយុទ្ធតែនៅក្នុងសមរភូមិតែសម័យនេះឯង ប៉ុល ពតមកជួបខ្ញុំ សម័យនេះ គឺការដែលខ្មែរក្រហមមិនទាន់ចូល ខ្ញុំនៅទូកមាសហ្នឹងធ្លាប់វាយគ្នា មួយប្រាវ

ភារិទ្ធៈ ហើយចុះដែលធ្លាប់លឺពីរឿងការប្រយុទ្ធតទល់គ្នាដែរ កាលពីជំនាន់បីឆ្នាំ?

រ៉ាឌីៈ ជំនាន់បីឆ្នាំអត់ដែល អត់ដែលលឺទេ លឺតែពីព្រំដែន ព្រំអី ដែលគេនិយាយនេះទេ

ភារិទ្ធៈ អូ ធ្លាប់លឺដែរ?

រ៉ាឌីៈ បាទ ធ្លាប់លឺគេនិយាយថា វៀតណាមវាយឡើង វាយអីអញ្ចឹងទៅ ថាវៀតណាម វាយចុះទទេ អាហ្នឹងយើងមិនបានដឹងពត៌មានអី កាលហ្នឹងវាដាច់ថាលឺ កាំភ្លើង លឺអីអញ្ចឹងទៅណា ខ្ញុំគ្រាន់តែលឺពាក្យមួយ ថាអញ្ចេះ ជំនាន់នោះខ្ញុំនៅចាំបានសំដីមួយមាត់ដែលចាស់ចាស់ទេ គាត់និយាយ ប៉ុន្តែគាត់ ប្រហែលជាអ្នកចេះដឹងដែរហើយ នៅពេលដែលលំបាកខ្លាំងពេក លឺតែផ្គរលាន់ ពេលដែលលឺកាំភ្លើងនៅព្រំដែនអាំ ថាលឺតែផ្គរលាន់អាំអោយតែភ្លៀងមក ហ្នឹងអាលវាយអោយធំៗ មួយដង សំដី ប៉ុនៗហ្នឹង គេយកទៅសម្លាប់បាត់ហើយ បាទ ដឹងអោយគេ កាលខ្ញុំនៅ ខ្ញុំអត់ចាប់អារម្មណ៍ទេ នៅពេលហ្នឹង ប៉ុន្តែក្រោយពេលហ្នឹង ចេះតែនឹកឃើញនៅចាំសំដីហ្នឹង ខ្ញុំយកមកវិភាគឥលូវ ថាផ្លែផ្កាអោយគេទាំងស្រុងតែម្តង ហើយគាមពិតទៅ ខ្ញុំឈឺចាប់ដល់ហើយណា បាទ លឺតែផ្គរលាន់ កាំភ្លើងធំ គ្រុងៗអញ្ចឹងអាំ ហើយអ្នកហ្នឹងហៅជាអ្នកចេះដឹងដែរ

ភារិទ្ធៈ ហើយចុះបងកាលជំនាន់ប៉ុល ពតហ្នឹងមានដែលគេណែនាំអោយផ្លាស់ប្តូរគំនិតទេ ខ្លួនបងផ្ទាល់

រ៉ាឌីៈ បាទ អាហ្នឹង ណែនាំជារួម ការណែនាំ ដូចខ្ញុំជំរាបអញ្ចឹង ថា ក្រោយពេលដែលវិលមកហូបបាយល្ងាចហើយ ប្រហែលជាម៉ោង៦ យប់ ម៉ោង៧ អីហើយ គឺគេទៅប្រជុំហើយ បើកងយុវជនហ្នឹង គឺគេប្រជុំរៀងរាល់ថ្ងៃអញ្ចឹង ប្រជុំគេណែនាំ អ្នកណាធ្វើនេះអញ្ចេះ ធ្វើទៅ ធម្មតាមនុស្សយើងទៅធ្វើរាប់រយអ្នក អ្នកខ្លះធ្លាប់មានកំហុសអញ្ចឹងលើកកំហុសហ្នឹង មួយៗៗមកនិយាយហើយ និយាយដល់ម៉ោង១០ ម៉ោងអីអីអញ្ចឹងទៅ ហើយអ្នកដែលនិយាយហ្នឹង ក៏អ្នកគេមេកង មិនមែនអ្នកចេះដឹងទេ អ្នកមុខ ក្រោយៗ មុខ មុខ ស្តាប់បានខ្លះមិនបានខ្លះចេះតែអង្គុយទៅ ប៉ុន្តែមានយុវជនមានដូចខ្ញុំជំរាបអញ្ចឹង ថាបងមួយនោះគាត់បរិញ្ញាតាំងពីលុន ណុលដែរ អញ្ចឹងគាត់យ៉ាងម៉េចគាត់ចេះតែទ្រាំ គាត់ទ្រាំដល់ចុងក្រោយទ្រាំមិនបានផុតទេ ថាឃើញភាពល្ងង់ខ្លៅ និយាយអោយអ្នកចេះអង្គុយស្តាប់អ្នកល្ងង់ វាពិបាកអាំ ថាទ្រាំ ចុងនោះ ដូចជា

ឆ្នាំ ៧៨ ៧០ អីនោះដែរហើយ ចង់ឆ្ងងផុតដែរហើយ

ភារិទ្ធៈ ហើយចុះបងអាការអប់រំណែនាំអោយផ្លាស់ប្តូរគំនិតហ្នឹង ក្រៅពីធ្លាប់ជួបខ្លួនឯងធ្លាប់ឃើញអ្នកដទៃគេណែនាំ មានធ្លាប់លឺគេនៅកងផ្សេង រឺក៏លឺនរណាម្នាក់គេនិយាយពីរឿង ការណែនាំអីអញ្ចឹងទេ?

រ៉ាឌីៈ ខ្ញុំ ថាដូចជាប្រហាក់ប្រហែលគ្នា នៅកងផ្សេងដូចជាប្រហាក់ប្រហែលគ្នាទេ អាការណែនាំព្រោះជារឿងរាល់ថ្ងៃ ពេលព្រឹក រឺក៏ពេលល្ងាចរសៀលហ្នឹង គឺមេកង១ៗនៅតាមកងនីមួយៗ មានកង នារី កងមេម៉ាយ កងយុវជន កងមេភូមិអីហ្នឹង គេតែងតែមកទទួលទិសនៅសាលាឃុំ ក្រោយពេលបានទិសហ្នឹងហើយគេទៅណែនាំ គេ ទៅ អនុវត្ត គេហៅទៅប្រជុំអីទៅ អញ្ចឹងដែនការរបស់ខ្មែរក្រហមហ្នឹងគឺមានភ្ជាប់តែម្តង អញ្ចឹងកងហ្នឹងត្រូវជូនរើ រើទាំងយប់ ក្រោយពេលទទួលទិសបានពីសាលា ឃុំ ដែលថ្នាក់ឃុំគេគ្រប់គ្រង ថ្នាក់ឃុំគេដាក់ទិសទៅហើយ អញ្ចឹងកងនេះដែលចាត់ចែងកំលាំង ទៅរើ ដល់កន្លែងមេកងរៀបចំឥវ៉ាន់ ផ្លាស់កន្លែងទៅទៀត ទៅទាំងយប់ហ្នឹង

ភារិទ្ធៈ អញ្ចឹងបងកាលជំនាន់ហ្នឹងមានដែលលឺ រឺក៏ឃើញពីករណីឈ្លបខ្មែរក្រហម រឺខ្មែរក្រហមចាប់រំលោភនារីភេទទេ?

រ៉ាឌីៈ ដូចមិនដែល

ភារិទ្ធៈ អត់ដែលលឺអត់ដែលឃើញទេ?

រ៉ាឌីៈ បើសិនជាមានក៏គេលាក់មិនអោយយើងឃើញដែរ ហើយនិយាយរួមជំនាន់ប៉ុល ពតបើសិនជាមិនដឹងរឿងល្អ ស្ងាត់អាណាអីណា ក៏ដោយចុះ ពេលរាល់ថ្ងៃហ្នឹង ក្នុងពេលមានអានំ អាទស្សនៈថារឿងគេ យើងកុំខ្វល់អា៎

ភារិទ្ធៈ បាទ

រ៉ាឌីៈ បាទ ជួនកាលដឹងអារឿងគេហ្នឹង អាធ្វើអីធ្វើទៅ អាណានិយាយស្តី ក៏មិនចង់ស្តាប់ចង់លឺដែរ ដើម្បីអោយសុខខ្លួនអា៎ រហូតដល់រាល់ថ្ងៃ ឃើញចោរប្លន់ម៉ូតូអី ក៏នាំគ្នាមិនរវល់ដែរហ្នឹងអា៎ មកពីមានអាគំនិតគេសល់ពីហ្នឹងមកហើយ ហើយបើសិនជាស្រុះគ្នា ក៏ចោរមិនងាយធ្វើដែរ ខ្ញុំជឿថាវាមិនងាយធ្វើទេ បើកណ្តាលភ្នំពេញវិញ វាភ្ជង់យកមុខៗយើងអត់ធ្វើអី អាហ្នឹងមកពីវា ដូចថាមានមនសិកាថាជួយគ្នាអា៎ អារឿងគេ ឋីទៅ កាលហ្នឹង

ចង់ដឹងថា បើសិនជាយើងដឹងរឿងគេច្រើន ដូចខ្ញុំថា វាខ្លាចតើ បាត់ខ្លួនអង្គការស្មើរ និយាយពីអង្គការស្មើរអាំ

ភារិទ្ធៈ បាទ

រ៉ាឌីៈ ហើយតែស្មើរហើយ អង្គការស្មើរទៅហើយ មិនដែលឃើញសង់វិញអស់ហើយ

ភារិទ្ធៈ ហើយចុះបងអាការដែលគេអោយធ្វើការតាមកងអីហ្នឹង គេបន្ទុំយើងរឺអត់?

រ៉ាឌីៈ បាទគេបន្ទុំ គេចែកមុខសញ្ញាអោយយើងធ្វើ ចែកជា បើថាលើកប្រឡាយ ជីកប្រឡាយ អញ្ចឹង គេវាស់ម៉ែត្រអោយយើងធ្វើ យើងធ្វើយ៉ាងម៉េចអោយហើយដូចគ្នា ដំណាលគេ

ភារិទ្ធៈ អត់ទេ ខ្ញុំសួរអោយការបែកពីគ្រួសារហ្នឹង

រ៉ាឌីៈ បាទ បន្ទុំ ត្រូវតែបន្ទុំ អ្នកឯងត្រូវតែទៅ នៅកន្លែងនេះ មិនទៅ មិនបាន មិនទៅ នៅទីនេះមិនបាន ត្រូវតែបន្ទុំចាប់អូសទៅ បាទ

ភារិទ្ធៈ អញ្ចឹងអ្នកដទៃក៏ដូចគ្នាអញ្ចឹងដែរ?

រ៉ាឌីៈ ក៏ដូចគ្នាអញ្ចឹងដែរ

ភារិទ្ធៈ ហើយចុះធ្លាប់លឺគេទៀតដែលចាប់បន្ទុំដូចគ្នាហ្នឹង?

រ៉ាឌីៈ មានរហូតទៅដល់អ្នកខ្លះ ដូចថាបែកពីម្តាយអីនៅក្មេងៗហ្នឹង វាអត់ព្រមទៅ គេចមកៗ ដល់សហករណ៍ទៅជាមួយម្តាយគេអត់អោយបាយហូបទេ អត់អោយបាយហូបជូនគ្នា កំពុងតែហូបបាយ ដកចានបាយហ្នឹងចេញទៅ ម្តាយហ្នឹង នៅសហករណ៍ ត្រូវចាប់រំលែក អោយកូនអញ្ចឹងទៅ បើកូនមិនមក អត់មានរបបកូន ព្រោះរបបវានៅកង ហើយបើ ភូមិហើយក្រុមគេឃើញ គេដកចានបាយចេញពីមាត់ ដកចានបាយហ្នឹងចេញមក អញ្ចឹង ម្តាយបើថាត្រូវមកនេះ ក៏ចាប់បន្ទុំខុប់ រហូតដល់តែបាយបបរទឹក ចាក់ដាក់មួយគោមក ផ្ញើរកូននៅនឹងផ្ទះ លួងកូន អង្វរកូនអោយទៅកង បើមិនទៅគេធ្វើបាប គេចាប់បន្ទុំយើង មិនមែនស្ម័គ្រចិត្តទេណា

ភារិទ្ធៈ អញ្ចឹងក៏ធ្លាប់លឺដែរអេពីបញ្ហាហ្នឹង?

រ៉ាឌីៈ បាទធ្លាប់លឺ

ភារិទ្ធៈ ហើយចុះបងផ្ទាល់មានដែលជួបហេតុការណ៍ណាមួយដែលបិះនឹងស្លាប់ខ្លួនទេ

រ៉ាឌីៈ អត់ដែលទេ ខ្ញុំអត់ដែលទេ

ភារិទ្ធៈ ហើយចុះអ្នកដទៃ អ្នកដទៃ ក៏ វាពិសេសគឺ អ្នកដែលប៉ះពាល់ដោយអាយុជីវិតគឺសំដី សំដៅ បាទ សំដីសំដៅហ្នឹងឯង មានដែលដឹងថាអ្នកទោសអី ត្រូវធ្វើអី ត្រូវនិយាយអី មួយ រឺក៏ធ្វើអី មួយ ខុស បិះនឹងគេយកទៅសម្លាប់មានទេ

ភ៉ាឌីៈ មាន មានទេ គ្រាន់តែលួច ដូចថាគ្នាលួចរបបស្ករអីអញ្ចឹងអាំ ដូចថាគេចែកស្ករដែនអី អញ្ចឹងអាំ ម្នាក់ៗមួយដែន មួយដែនហ្នឹង អ្នកខ្លះអត់ហ៊ានហូបទេ ហូបបន្តិចៗហ្នឹង វាទុកហូបបាន នេះ អាណាដែលវាឃ្លានហ្នឹង ទៅលួចគ្នាតនៅក្នុងកងហ្នឹង គេចាប់បាន គេវាយ ឯង ចិញ្ចាំដែរ រហូតដល់តែគេលើក គេប្រជុំជាមួយក្រុមគេ អាបក្ស បក្សជនក្រុមគេហ្នឹង ពេលខ្លះហ្នឹងក៏បាត់ខ្លួនទៅ ពេលខ្លះក៏ឃើញថា អោយគេលើកលែងទោសអោយតែសារភាពអីទៅណាមាន

ភារិទ្ធៈ ហើយចុះធ្លាប់លឺដែរ ដែលអ្នកណាម្នាក់ ដែលជួបហេតុការណ៍បិះនឹងស្លាប់ខ្លួន ធ្លាប់លឺគេនិយាយទេ?

ភ៉ាឌីៈ បាទ ធ្លាប់លឺ

ភារិទ្ធៈ ហើយចុះបងមានដែលអើ គេបង្ខំអោយនៅដាច់ដោយឡែកពីអ្នកដទៃ ទេ ?

ភ៉ាឌីៈ អត់ដែលទេ

ភារិទ្ធៈ អត់ទេ

ភ៉ាឌីៈ បាទ

ភារិទ្ធៈ ហើយចុះធ្លាប់ឃើញនរណាគេម្នាក់ទេ?

ភ៉ាឌីៈ ធ្លាប់ឃើញ ធ្លាប់ឃើញថានៅកងយុវជនជាមួយគ្នា គេអោយក្រុម មួយក្រុមទៀត ប្រហែលជាគ្នា១២នាក់ បានខ្ញុំដឹងចំនួនហ្នឹងច្បាស់ ហើយខ្ញុំស្គាល់អ្នកហ្នឹងច្បាស់គឺខ្ញុំខស្សរាហ៍ទៅលេងអ្នកហ្នឹង អ្នកហ្នឹងគេមានលទ្ធភាពជាងពួកខ្ញុំត្រង់ថា គេធ្វើការងារនៅក្នុងម្ជប់ ការងារគេអោយធ្វើដាច់ដោយឡែកពីគេ ដោយគេរៀបចំក្រុមហ្នឹងមួយ គេហៅថាក្រុមកៅប្រម៉េះ ក្រុមស្វាយប្រម៉េះដែល ជំនាន់លុន លុន អ្នកលេង ស្រីអីហ្នឹងអាំ ប៉ុន្តែវាមិនមែនជាការពិតទេ ប៉ុន្តែខ្ញុំយល់ថាអ្នកទាំងអស់ហ្នឹងឆ្លាត ឆ្លាតត្រង់ថា ដាក់ខ្លួនទៅបិទ សូម្បីតែកត្តិយស គេចោទតែអ្នក កើតប្រមេះ កើត ស្វាយអីហ្នឹង ពេលបាយ

ទឹកអីហ្នឹង គេមិនអោយចូលហ្នឹងគេដែរ គេអោយលើក ទៅស៊ីដោយឡែក ប៉ុនតែ អាហ្នឹងល្អ បើនិយាយពីការហូបចុក ហើយនិងការផារគឺល្អវិញ វាធ្វើបានតិច

ភារិទ្ធៈ បាទ

រ៉ាឌីៈ ហើយវា ហូបចុកអីអាចផ្ញើតរកក្រៅបាន ឃើញថារស់នៅដោយឡែកក្រុមគេហ្នឹង

ភារិទ្ធៈ បាទ ហើយចុះក្រៅពីឃើញអញ្ចឹងមានធ្លាប់លឺអីផ្សេងទៀតទេអារឿងគេអោយនៅ?

រ៉ាឌីៈ អត់ អត់ដែលលឺអីទេ

ភារិទ្ធៈ ហើយចុះជំនាន់ប៉ុល ពតហ្នឹង មានដែលលឺ ដែលឃើញ ដែលគេបង្ខំអោយគេសម្លាប់ ដូចថាសាច់ញាតិសម្លាប់សាច់ញាតិឯង ដូចថាកូនសម្លាប់ឪពុក បងសម្លាប់ប្អូនអី មាន ធ្លាប់ដែល លឺ ធ្លាប់ឃើញអីទេ?

រ៉ាឌីៈ ខ្ញុំអត់ដែលបានលឺបានឃើញអីទេ ដូចខ្ញុំជំរាបថាអារឿងទាំងអស់នេះ បើអ្នកមូលដ្ឋានក្រែង លំគេអាចបានដឹងច្រើន បើអ្នកថ្មីនេះ គឺ មិនអាចនៅរង់ចាំស្តាប់ រឺសាកសួរពត៌មានដេញ ដាលពីគេទេ ប៉ុនតែឃើញសកម្មភាពភាគច្រើនគឺ ដូចខ្ញុំជំរាបថា ប្រធានភូមិដែលយកខ្ញុំ ទៅសម្លាប់ហ្នឹងគឺ ហាក់ដូចជាគេចង់បង្ហាញទឹកចិត្តរបស់គេថា គេមិនដែលចាត់ទុកថាអ្នក ដែលមានគុណ អ្នកដែលជួយគេចិញ្ចឹមគេហ្នឹង អ្នកមានគុណគេទេ គឺគេហ៊ានសម្លាប់ ហ៊ាន ធ្វើ បាទ ចិត្តគេមុះមុត ស្មោះត្រង់នឹងបក្សណាស់ ស្មោះត្រង់នឹងអង្គការណាស់ អង្គការ អញ្ចឹងបានគេជ្រើសរើសឪពុកហ្នឹង គឺគេយកទៅសម្លាប់ដែលថាក្បត់ ហ្នឹង

ភារិទ្ធៈ ហើយចុះបងមានដែលអើ ឃើញ រឺក៏មានដែលលឺពីការសម្លាប់ដែលជាអ្នកសាច់ញាតិ រឺក៏មិត្តភ័ក្ត របស់បង ដែលបងយល់ថាវាការស្លាប់ហ្នឹង វាជាការមួយដែលចម្លែករបស់ បងមានដែលលឺទេ មានដែលលឺទេ មានធ្លាប់ឃើញទេ?

រ៉ាឌីៈ ខ្ញុំដូចជាមិនបានចាប់អារម្មណ៍ដល់ប៉ុនហ្នឹងទេ ព្រោះអាការសម្លាប់ហ្នឹងវាតែងតែថា វាមាន កំហុស បើមានកំហុសគេចេះតែជូនគេទៅ

ភារិទ្ធៈ អើ នៅក្នុងករណីស្លាប់ អ្នកនេះស្លាប់ រឺក៏ស្លាប់រំលាយអាក វះពោះអី មានដែលធ្លាប់ ឃើញទេ?

រ៉ាឌីៈ បាទ ការដែលស្លាប់ហ្នឹងមាន

ភារិទ្ធៈ មានធ្លាប់លឺដែរ រឺក៏អត់ទេ?

រ៉ាឌីៈ ធ្លាប់ លឺធ្លាប់ឃើញ ហើយបើគ្នាវាអស់រលីងពីក្នុងខ្លួនពេកទៅ ធ្លាក់ជំងឺរ៉ាំរ៉ៃ រ៉ាំរ៉ៃ យូរៗទៅ អាថ្នាំសង្កូវភ្លាម ហើយអា ជាតិវីតាមីនអីហូបចុកគ្រប់គ្រាន់ គឺវាស្លាប់ ស្គមវាស្លាប់ ជំនាន់ហ្នឹង ស្លាប់ដោយសារជំងឺរ៉ាំរ៉ៃ ស្លាប់ដោយសារការអាហារមិនគ្រប់គ្រាន់

ភារិទ្ធៈ ហើយចុះបងមានដែលធ្លាប់ឃើញការសម្លាប់នរណាម្នាក់ដែលបងអស់ស្គាល់ថាអ្នកហ្នឹងជាអ្នកណាអាំ មាន រឺក៏អត់មានធ្លាប់លឺពីរឿងការសម្លាប់នរណាម្នាក់ហ្នឹង?

រ៉ាឌីៈ ខ្ញុំអត់ដែលធ្លាប់ទេ អត់ដែលធ្លាប់ទេ

ភារិទ្ធៈ លឺក៏អត់ដែរ?

រ៉ាឌីៈ បាទ លឺ លឺតែគេសម្លាប់ ប៉ុន្តែវាមិនបានឃើញ ដោយសារ ការសម្លាប់របស់គេហ្នឹង គឺគេលាក់ការណ៍របស់គេ បាទ

ភារិទ្ធៈ ហើយចុះបងមានដែលវង្វេងរឺក៏ ឃើញនរណាម្នាក់វង្វេង រឺក៏ធ្លាប់ឃើញនរណាម្នាក់ការដែលគេវង្វេង ពីកន្លែងមួយទៅកន្លែងមួយ រឺក៏អ្នកហ្នឹងដែលគេចាប់ទៅ គេយកទៅដាក់ទៅកន្លែងណាមួយ ដែលគេអត់ដឹងថា កន្លែងហ្នឹងជាកន្លែងស្អី?

រ៉ាឌីៈ ខ្ញុំ ធ្លាប់ឃើញ ប៉ុន្តែ កាលនោះ ខ្ញុំគិតថា ជាការពិតខ្លះ មិនមែនជាការពិតខ្លះ ព្រោះការច្នៃប្រឌិតនឹងល្បិចកល ដើម្បីរស់អោយបានស្រួល អោយបានស្រណុក វាត្រូវមានពេលខ្លះធ្វើវង្វេង ធ្វើអត់ដឹងអីអញ្ចឹងទេ ប៉ុន្តែបើស៊ើបមនុស្សហ្នឹងអោយច្បាស់ទៅ មិនមែនជាមនុស្សធម្មតាទេ

ភារិទ្ធៈ អូ

រ៉ាឌីៈ គេ អ្នកចេះដឹង គេគ្រាន់បើដែរ

ភារិទ្ធៈ ហើយចុះទាក់ទងការវង្វេងការអីហ្នឹង ក្រៅពីវង្វេងពីអីហ្នឹងមានដែលលឺ គេនិយាយទេ អញ្ចឹងបងអត់មានដែលគេធ្វើទារុណកម្មវាយដំអីទេ?

រ៉ាឌីៈ បាទ ខ្ញុំអត់ដែលទេ

ភារិទ្ធៈ ហើយចុះអ្នកដទៃមានធ្លាប់ឃើញគេវាយទេ?

រ៉ាឌីៈ បាទ គេមានវាយ វាយ មានគេវាយជាដងរែក វាយជាខ្សែបន្ទីអី

ភារិទ្ធៈ អាហ្នឹងឃើញផ្ទាល់ភ្នែក?

រ៉ាឌីៈ បាទ ឃើញផ្ទាល់ភ្នែក ដែលជាមេក្រុម មេកងគេនិមួយៗដែលគេធ្វើហ្នឹងអាំ អាហ្នឹង

ដោយសារ វាមិនបានឃើញស្លាប់នៅកន្លែងទេ គ្រាន់តែថាគ្នាត្រូវទទួលការ រងគ្រោះ ជាទំនន់អីអញ្ចឹង ហើយយើងចេះតែបន្តធ្វើការទៀតទៅ ហើយបើសិនជាអ្នកហ្នឹង ត្រូវរងគ្រោះដោយសារគេវាយ ចោទប្រកាន់ជាក្បត់ ក៏វាធ្វើ អីមិនសមរម្យហើយ គឺយើងមិនហ៊ានសាកសួរទេ

ភារិទ្ធៈ ហើយចុះបង អាទាក់ទងការធ្វើទារុណកម្ម ខ្ញុំចង់ដឹងថាក្រៅពីបងថាធ្លាប់ឃើញគេវាយម្តងទៅ ហើយគេវាយនឹងខ្សែគោអីអញ្ចឹងអា៎ មានដែលលឺអាគេនិយាយពីការធ្វើទារុណកម្មអីផ្សេងទៀតទេ ធ្លាប់លឺទេ?

ភ៉ាឌីៈ អត់ដែលលឺទេ អញ្ចឹងបានខ្ញុំភ្ញាក់ខ្លួន ហើយភ្ញាក់នៅពេលដែលចូលទៅទួលស្លែង បានខ្ញុំឃើញការគៀបក្រចក ការចាប់ អា កអីហ្នឹង

ភារិទ្ធៈ ពីមុនមកអត់ដែលទេ?

ភ៉ាឌីៈ បាទ អត់ដែលទេ

ភារិទ្ធៈ ទើបតែលឺឥលូវ អីឃើញឥលូវ?

ភ៉ាឌីៈ បាទ ការធ្វើទារុណកម្មទៅលើមនុស្ស ដូចថាទៅធ្វើនៅតំបន់ណា ដែល ហើយដូចជានៅក្រាំងតាច័ន្ទនេះ ខ្ញុំគ្រាន់តែសួរអ្នកដែលនៅជិតៗខ្លះជំនាន់នោះ គេមិនដែលថា អោយយើងដើរជិតកន្លែងគេផង អញ្ចឹងយើងមិនអាចដឹង

ភារិទ្ធៈ ហើយចុះបងមានដែលជួបស្ថានការណ៍ណាមួយផ្សេងទៀត ក្រៅពីការធ្វើទារុណកម្មហើយដែលវាធ្វើអោយបងរន្ធត់អា៎? ហេតុការណ៍ទាំងអស់ហ្នឹងមានទេ?

ភ៉ាឌីៈ ខ្ញុំមានមួយដង ខ្ញុំកំពុងតែធ្វើប្រឡាយហើយគេដេញ ដេញចាប់មនុស្សយកទៅសម្លាប់ហ្នឹងតាំងពីខេត្តកំពតនេះទៅ អោះ មកដល់ប៉ះអេកន្លែងក្រុមដែលខ្ញុំកំពុងតែលើប្រឡាយ អីដល់តែពេលនោះមនុស្សវាច្រើនអា៎ អញ្ចឹងយើងក៏មិនហ៊ានទៅជួយគេដែរ អត់ហ៊ានទៅជួយគេទេ យើងគ្រាន់តែបានតែមួយឈរមើល ដល់តែហើយគេចាប់បាន ចាប់បានហើយគេ ចង់បណ្តើរទៅ បណ្តើរហ្នឹងមិនដឹងទៅណា តែខ្ញុំជឿថា ម្នាក់ហ្នឹងស្លាប់ហើយ

ភារិទ្ធៈ អូ

ភ៉ាឌីៈ ពិតជាស្លាប់ មិនអាចគេចរួចទេ

ភារិទ្ធៈ អាហ្នឹងធ្លាប់ឃើញតែមួយដងហ្នឹងទេ?

វ៉ាឌី: បាទ ឃើញមួយដែរ

ភារិទ្ធ: ហើយចុះមានដែលលឺគេនិយាយអីផ្សេងៗទៀតទាក់ទងនឹងហេតុការណ៍ផ្សេង?

វ៉ាឌី: អឺ អាហេតុការណ៍ហ្នឹង ខ្ញុំធ្លាប់តែលឺគេនិយាយដែរហ្នឹងអា៎ វាយនឹងត្បូងចប អាក ក អឺ ជំនាន់ហ្នឹង គេនាំគ្នាមកនិយាយសើច គេមេៗៗកងហ្នឹង ដែលយើងដើរជិតហ្នឹងអា៎ យើងលឺ ប៉ុន្តែអារឿង ពិត មិនពិត យើងអត់អាចដឹងបាន ព្រោះយើងធ្វើសុទ្ធតែលាក់ការណ៍របស់ក្រុមគេទាំងអស់ មានអ្នកខ្លះគេថា វាយពី ត្បូងចប ងើបមើលមុខ បើក ភ្នែក មើលគេមើលអីអញ្ចឹងទៅ អានេះវាជារឿងមួយឆាកកំប្លែង វាជារឿងមួយដែលគេនិយាយសើចលេងអីអញ្ចឹងអា៎ ខ្ញុំធ្លាប់លឺគេនិយាយ ប៉ុន្តែរឿងពិតមិនពិតយើងមិនបានដឹង ព្រោះយើងអត់បានឃើញទេ ព្រោះ គេមិនអាចអោយយើងទៅជិតកន្លែងគេផង

ភារិទ្ធ: ហើយចុះបង ខ្ញុំចង់ដឹងទាក់ទងនឹងហេតុការណ៍ទាំងអស់ដែលបងរៀបរាប់ខាងលើ ខ្ញុំចង់ដឹងថា បើនឹកទៅដល់រឿងប៉ុល ពតហ្នឹងអា៎ រឿងស្អី មួយដែលវាធ្វើអោយបងឈឺចាប់ជាងគេបំផុតអា៎ពេលដែលនឹកឃើញទៅអា៎?

វ៉ាឌី: ខ្ញុំមានរឿងច្រើនណាស់ដែលឈឺចាប់ចំពោះប៉ុល ពតហ្នឹង និយាយអោយចំទៅ រឿងក្រុមគ្រួសារនេះមួយ ហើយរឿងមនុស្សលោក មិនគួរ មិនគួរធ្វើដោយរបៀបហ្នឹង មិនគួរសោះ មិនគួរ ថាវាប្រើមនុស្សហួស ហួសការស្មាន អា៎ យើងគិតពីមុន ហើយមកពេលបច្ចុប្បន្ននេះ យើង គ្មានពេលឱកាសក្មេងដើរលេងអីទេ វាកាត់ផ្តាច់មនោសញ្ចេតនា អាកាត់ផ្តាច់ការសប្បាយការរស់នៅ កើតមកនៅក្នុងរបប ប៉ុល ពត ដែលចំនៅក្នុងរបបប៉ុល ពតនេះ មនុស្សទាំងអស់ហ្នឹង ដូច និយាយដូចថា និយាយ រកអីនិយាយមិនបានតែម្តងអា៎

ភារិទ្ធ: ហើយចុះនៅក្នុងចំណោមហេតុការណ៍ ពេលអំបាញ់មិញ ហេតុការណ៍មួយណាដែលឈឺចាប់ជាងគេ?

វ៉ាឌី: រឿងដែលឈឺចាប់ជាងគេ គឺរឿងដែលត្រូវបាត់ ឪពុក បាទ បាត់បងប្អូន ដែលត្រូវស្លាប់នៅក្នុងរបប ហើយនិងការស្លាប់ដោយគ្មានមូលហេតុ អីសោះ ហើយចុះបើថាស្លាប់ដោយសារជំងឺ យើង បានព្យាបាលបានមើលអីអស់ចិត្តអា៎ ស្លាប់ដោយរបៀបនេះ យើងមិនបានតបស្នងសងគុណគាត់ អី អោយវាអស់ចិត្ត ហើយវាមិនដឹងជា ខ្មោចរបស់គាត់ហ្នឹង

វាទៅជា វាក្លាចទៅជាស្អីៗ ហើយធាតុរបស់គាត់ហ្នឹងមិនដឹងក្លាយទៅជាស្អីៗ

ភារិទ្ធៈ ហើយចុះកាលហ្នឹងឆ្នាំណាបង ឆ្នាំណា?

រ៉ាឌីៈ ឪពុកខ្ញុំស្លាប់នៅឆ្នាំ១៩៧៥តែម្តង ក្រោយរំដោះ ពេលរំដោះ អង្គការគេរំដោះ

ភារិទ្ធៈ ហើយចុះប្អូនពីរនាក់ហ្នឹង ឆ្នាំអីដែរ?

រ៉ាឌីៈ ប្អូនពីរនាក់ហ្នឹង អាប្អូនពៅស្លាប់ហ្នឹង នៅក្នុងឆ្នាំ១៩៧៥ ដូចគ្នា ប៉ុនតែប្អូនស្រី រឺមួយ បន្ទាប់ខ្ញុំ ប្អូនទីពីររបស់ខ្ញុំហ្នឹង គឺស្លាប់ នៅក្នុង១៩៧៦ បានមួយឆ្នាំ

ភារិទ្ធៈ ហ្នឹងស្រី រឺប្រុស?

រ៉ាឌីៈ បាទ ស្រី

ភារិទ្ធៈ ថា ឪពុកនៅក្រាំងតាចាន់អញ្ចឹងអេ?

រ៉ាឌីៈ បាទ ពត៌មាននេះ យើងមិនទាន់បានដឹងថា ពិតរឺមិនពិតនៅឡើយទេ គ្រាន់តែដឹងថា អញ្ចឹង បាទ

<u>Cassette 2</u>
<u>Side A</u>

រ៉ាឌីៈ នៅ នៅ

ភារិទ្ធៈ នៅតែនឹកឃើញ

រ៉ាឌីៈ ចេះតែនឹកឃើញ

ភារិទ្ធៈ អារម្មណ៍ដែលចេះតែនឹកឃើញហ្នឹងមានច្រើន មានតិចតួច រឺក៏មាន?

រ៉ាឌីៈ អារម្មណ៍ដែលចេះតែនឹកឃើញ គឺភាគច្រើនកើតមាននៅពេលដែលខ្ញុំជួបហេតុការណ៍ បាទ និងជួបហេតុការណ៍រឿងរ៉ាវអីមួយអញ្ចឹងអាំ បើសិនជាទៅវិញប៉ះហេតុការណ៍ទាំងអស់ហ្នឹងវិញទៀតទៅ ខ្ញុំនឹកឃើញញឹកហើយ ហើយដូចប៉ះកន្លែងខ្លះដែលគេសប្បាយ ភ្លេចខ្លួន ដល់ពេលអញ្ចឹងនឹកឃើញថា អឺ អ្នកទាំងអស់នេះមិនបានឆ្លងកាត់ អា ដូចថា វាប៉ះក្រែងល់ទៅទង្វើអីមួយដែលវា វាបំពានលើវា កៀបសង្កត់ទៅលើគេអាំ ខ្ញុំចេះតែនឹកថា អ្នកទាំងអស់ហ្នឹងបើសិនជាប៉ុល ពត គេអត់ទុកអោយរស់ទេ

ភារិទ្ធៈ ហើយចុះអាការគិតអស់ហ្នឹងមានច្រើន?

រ៉ាឌីៈ បាទ ខ្ញុំមានច្រើន ហើយខ្ញុំចេះតែយករឿងហ្នឹងមកវិភាគហើយ វិភាគទៀត វិភាគ

អញ្ចឹង

ភារិទ្ធៈ ហើយចុះអាហេតុការណ៍ដែលបង ចេះតែនឹកឃើញហ្នឹង ពេលដែលនឹកឃើញទៅ វាមានអារម្មណ៍ដូចជាហេតុការណ៍ហ្នឹងទើបតែកើតមានថ្មីៗ?

រ៉ាឌី: បាទ ហាក់ដូចជាកើតមានថ្មីៗ

ភារិទ្ធៈ ហើយចុះអារម្មណ៍ដែលដូចថាកើតមានឡើងជាថ្មីៗហ្នឹង អារម្មណ៍អញ្ចឹងមានច្រើន តិចតួច រឺក៏ល្មម?

រ៉ាឌី: ខ្ញុំមានដូចជាមិនច្រើនប៉ុន្មានដែរទេ ដូចជាល្មមទេ ព្រោះវាខ្លះបច្ចុប្បន្នមានកន្លែងខ្លះអាចបំភ្លេចបានខ្លះដែរ បើថា យើងកំដរអារម្មណ៍តាមរយៈទូរទស្សន៍ តាមរយៈវីដេអូអី គឺភ្លេច ហើយ

ភារិទ្ធៈ ហើយចុះបងមានដែលយល់សប្តិអាក្រក់ទេ រាល់ថ្ងៃ?

រ៉ាឌី: ខ្ញុំយល់សប្តិអាក្រក់ញឹកអា៎ យល់សប្តិតាំងពីជំនាន់ប៉ុល ពតមកហ្នឹង កាលពីជំនាន់ប៉ុល ពតហ្នឹង យល់សប្តិអាក្រក់អា៎ ឃើញច្រើន

ភារិទ្ធៈ ហើយចុះរាល់ថ្ងៃហ្នឹងមានដែលមានអារម្មណ៍ ដូចជាមិនរវល់ រឺក៏ដូចជាមិនចង់ជួបអ្នកដទៃ ចង់នៅស្ងាត់តែឯងមានទេ?

រ៉ាឌី: ពេលខ្លះ ខ្ញុំគិតអញ្ចឹងដែរ

ភារិទ្ធៈ មានតិចតួចដែរ រឺក៏មានល្មមទេ?

រ៉ាឌី: បាទ តិចតួច តិចតួច ពេលខ្លះក៏គិតថា បើយើងរស់នៅម្នាក់ឯងក៏យើងមិនអាចដឹងពីទិដ្ឋភាព ខាងក្រៅយ៉ាងម៉េច ដូច្នេះរស់នៅជាមួយគេច្រើនអញ្ចឹងទៅ ពេលខ្លះក៏ធុញថប់

ភារិទ្ធៈ ចង់នៅតែឯងដែរ?

រ៉ាឌី: ចង់នៅតែឯងអញ្ចឹងដែរ

ភារិទ្ធៈ ហើយចុះមានដែលមានអារម្មណ៍ រាល់ថ្ងៃមានដែលមានអារម្មណ៍ថា ដូចជាអត់អារម្មណ៍សោះ សប្បាយក៏គ្មានអារម្មណ៍សប្បាយ?

រ៉ាឌី: មាន

ភារិទ្ធៈ អារម្មណ៍អញ្ចឹងមានច្រើន អេមានតិចតួចដែរ?

រ៉ាឌី: បាទ មានច្រើន បាទ ចំពោះបញ្ហាហ្នឹង និយាយទៅ មានច្រើនអា៎ ដូចថាឃើញគេ

សប្បាយអី ច្រៀងរាំសប្បាយអី ខ្ញុំដូចគ្មានអារម្មណ៍ទេ បាទ អត់មានអារម្មណ៍ថាមិនដឹង ថាខ្លួនឯងសប្បាយយ៉ាងម៉េចកើតទេ តែប៉ុណ្ណឹង ដូចថាហូប ចុកអីជាមួយគេ សំខាន់ បំផុត គឺ គំនិតទីមួយគឺខ្ញុំនៅវាលតែម្នាក់ឯង ពេលដែលខ្ញុំមកដេក យើងមិនបានលក់ វា ចេះតែគិត ពីណេះពីនោះ អញ្ចឹងចេះតែហូបចុកស្រវឹងអីអញ្ចេះអញ្ចុះទៅ ឆាប់លក់ ដាក់ ទៅលក់ យើងមិនបាច់គិតអីច្រើនទេ ស្អែកចាំគិតទៀត

ភារិទ្ធ: ហើយចុះរាល់ថ្ងៃឆាប់ភ័យខ្លាច រឺក៏ឆាប់ភ្ញាក់ផ្អើលអីទេ?

រ៉ាឌី: ខ្ញុំឆាប់ភ័យ

ភារិទ្ធ: ហើយចុះអារម្មណ៍ឆាប់ភ័យអញ្ចឹងមានតិចតួច មានខ្លាំង រឺក៏មានល្មម?

រ៉ាឌី: ខ្ញុំបើមាន ដូចជាមិនតិចប៉ុន្មានដែរទេ វារឿងរ៉ាវដែលពាក់ព័ន្ធនឹងខ្លួន គឺឆាប់ភ័យអា៎ ពិសេស ខ្ញុំភ័យមិនចង់អោយមានកំហុសហ្នឹងហ្មង ទោះបីខ្ញុំធ្វើការងារអី មានអារម្មណ៍អី វាខុស ឆ្គង បន្តិចបន្តួច គឺឆាប់ភ័យហ្នឹងតែម្តង មិនដឹងជាយ៉ាងម៉េចអីយ៉ាងម៉េចទេ គំនិត ចេះតែបកស្រាយទៅ បកស្រាយបំភ្លឺ អីអញ្ចឹងទៅ បើគេស្តាប់បានពីអ្វីដែលយើងធ្វើ ព្រោះកាលណាដែលយើងធ្វើ គឺយើងមានបំណងហើយ ហើយយល់ពីបំណង យល់ពី បំណងយើងដែលខុសឆ្គង បន្តិចៗក៏គេអព្យាស្រ័យអត់អោនអីអញ្ចឹងដែរ រឿងហ្នឹងវាប៉ះ ពាល់អី យើងត្រូវ កែប្រែ បិទបាំងអីយ៉ាងម៉េចៗ ហ្នឹង វាជារឿង

ភារិទ្ធ: ហើយចុះបងមានដែលមានអារម្មណ៍ថារាល់ថ្ងៃហ្នឹងមានដែលលំបាក នៅក្នុងការគិត រឺក៏ ផ្តោតគំនិតទៅលើអ្វីមួយទេ គិតអីអត់មូលអា៎ មានអារម្មណ៍អញ្ចឹងទេ?

រ៉ាឌី: បាទ ខ្ញុំមាន មានពិសេស គឺខ្ញុំផ្តោតអារម្មណ៍ទៅលើកូនតែម្តង សព្វថ្ងៃគឺខ្ញុំខំប្រឹងអោយវា រៀនវាសូត្រអី វាមិនប្រាថ្នាអោយវាធ្វើអីធំ តែអោយកាលណាវារៀនសូត្រចេះដឹង គឺវា មានគំនិតទូលំទូលាយ មានគំនិតទូលំទូលាយ ទោះបីវារស់នៅនៅក្នុងមជ្ឈដ្ឋានណា ក៏វាចេះ មានការទំនាក់ទំនង ចេះមានការយោគយល់គ្នា ដូចខ្ញុំរស់នៅស្រុកគេហ្នឹង មិនមែនខ្ញុំតាំង ខ្លួនខ្ញុំថាជាអ្នកចេះ ប៉ុន្តែខ្ញុំគ្រាន់តែថា ខ្ញុំយោគយល់គេ គេយោគយល់ខ្ញុំទៅ នៅកន្លែងណា ក៏គេស្រឡាញ់គេរាប់អានខ្ញុំដែរ

ភារិទ្ធ: អើ ខ្ញុំចង់សួរអញ្ចេះ ខ្ញុំចង់សួរ ថាបងដូចថា បងគិតស្អីមួយ បងអារម្មណ៍ហ្នឹង គិតមូល ទៅលើបញ្ហាហ្នឹង ដែរ រឺក៏បែកឆ្វេងបែកអី?

ភ៉ឌី: អឺ ដូចជាមិនមូលទេ បាទ អត់មូលទេ មួនទៅអញ្ចេះទៅ មួនមកអញ្ចេះមក មួនគិតទៅអញ្ចុះទៅ អារឿងហ្នឹងគិតមិនទាន់ចប់ គិតទៅរឿងមួយផ្សេងទៀតហើយ

ភារិទ្ធ: ហើយចុះអារម្មណ៍អញ្ចឹងវាមានច្រើន រឺក៏មានតិចតួចដែរ?

ភ៉ឌី: មាន មានច្រើន មានច្រើនតែម្តង

ភារិទ្ធ: ហើយចុះការទទួលទានដំណេកបងរាល់ថ្ងៃពិបាកដែរទេ?

ភ៉ឌី: មិនសូវពិបាក ទេ បើគ្រាន់តែ បើកាលខ្ញុំជំរាបថា លក់ធម្មតា បាទ លក់ធម្មតាដោយសារតែ អើ ខ្ញុំទៅ វាល បើមិនជាហួបអីបន្តិចបន្តួច វាមិនងាយដែរអានេះគ្រាន់តែយើងផ្តោតអារម្មណ៍ចាក់មើលកាសែ្សត មើលរឿងអីអញ្ចឹង ចេះតែ មើល មើល អារម្មណ៍របស់ខ្ញុំ ផ្តោតទៅមើល សាច់រឿង ហើយខ្ញុំក៏ចាប់ផ្តើមទន់ត្របក ភ្នែក ហើយក៏ខ្ញុំអត់បិទទេ ទុកអោយរឿង ក្រោយពេលដែលខ្ញុំបិទភ្នែក ត្រចៀកខ្ញុំនៅស្តាប់ទៀត អញ្ចឹងដល់តែពេលត្រចៀកខ្ញុំស្តាប់ដល់ពេលតែខ្ញុំលក់ ក៏លក់ទៅ អារឿងវ៉ាវដែលចាក់នៅឌីសនៅហ្នឹងចេះតែនៅទៅ ចប់ម៉ោងប៉ុន្មាន ក៏ចប់ទៅ បានលក់ទៅ ខ្ញុំមិនធ្វើអោយអារម្មណ៍ហ្នឹង ភ្ញាក់ផ្អើលឡើងវិញទៅ វាលំបាក

ភារិទ្ធ: ហើយចុះអាអារម្មណ៍ដែលពិបាកនៅក្នុងការទទួលទានដំណេកហ្នឹងមានតិចតួចដែរអេ?

ភ៉ឌី: បាទមាន មិនអត់ទេ មាន

ភារិទ្ធ: រាល់ថ្ងៃមានដែលចេះមានអារម្មណ៍ថាចេះតែប្រយ័ត្ន ចេះតែប្រុងប្រយ័ត្នខ្លួនខ្លាចអ្នកដទៃបៀតបៀន អញ្ចេះអី ចេះតែប្រយ័ត្នអញ្ចឹងអ៉ា មានដែលមានអារម្មណ៍អញ្ចឹងទេ?

ភ៉ឌី: មាន មាន មានអារម្មណ៍អញ្ចឹង

ភារិទ្ធ: មានតិចតួចអេ មានខ្លាំង?

ភ៉ឌី: បាទ មានតិចតួចទេ បាទ ខ្ញុំ គិតថា បាន ខ្ញុំគិត ចាត់ទុកថា អាហ្នឹងជារឿងតិចតួច ព្រោះវាអាស្រ័យទៅលើការយល់ដឹង ការគិតរបស់ខ្ញុំ ដែលខ្ញុំមើលទៅអ្នកដទៃ ហើយខ្ញុំអោយតំលៃទៅលើថ្នាក់ដឹកនាំទៀត ក្នុងការងារអី ហើយបើថាអ្នកដទៃថា គួរតែប៉ុណ្ណឹង ប៉ុន្តែខ្ញុំពិនិត្យទៅ ឃើញថា យើងគួរតែពិនិត្យទៅ គួរតែគេមកជំនួសកន្លែងហ្នឹងបាន បានខ្ញុំទទួលស្គាល់ ប៉ុនតែខ្ញុំមិនមែនជាលទ្ធភាព សមត្ថភាពទេ ហើយគួរមកបាន អឺ មានអារម្មណ៍ថាធ្វើនេះដូចជាអយុត្តិធម៌ណាស់ ដូចជាអ្នកដែលចាត់ការហ្នឹង មិនមានអាដែង

ឆន្ទៈ ហើយនិងមនសិកាជាតិទេ មិនគិតពីការរីកចំរើនទេ

ភារិទ្ធៈ ហើយចុះបងរាល់ថ្ងៃឆាប់ខឹង ហើយឆាប់ច្រឡោតអីដែរអត់ទេ?

រ៉ាឌីៈ ខ្ញុំឥលូវកាត់បន្ថយបញ្ហាហ្នឹងបានច្រើន ចំពោះបញ្ហាហ្នឹង

ភារិទ្ធៈ នៅមានតិចតួចដែរ?

រ៉ាឌីៈ បាទនៅមានតិចតួច ទេ ព្រោះខ្ញុំ គិតបានច្រើន ព្រោះចូលចិត្តធៀប រឿងណាដែលអត់ អោនអោយបាន អត់ទេ អត់អោយមួយចប់

ភារិទ្ធៈ ហើយចុះរាល់ថ្ងៃ បងចេះតែខស្សរាហ៍នឹកឃើញអញ្ចឹងអាំ មានអើ រឿងរ៉ាវឈឺចាប់កាល ពីអតីតកាលអញ្ចឹងមានដែលមានអារម្មណ៍ ដូចជាចង់ជៀសវាងមិនចង់អោយឃើញ សកម្មភាពណាមួយ ដែលធ្វើអោយយើងនឹកឃើញអារឿងហ្នឹង ដូចថា ពីមុនមក ឃើញ គេចាប់ចងអីគេ យើងចេះតែ យើងភ័យយើងខ្លាចហើយ ដល់តែពេលឃើញឥលូវ គេ ដូចជាមិនចង់ ចង់គេចវេសពីហេតុការណ៍ហ្នឹង

រ៉ាឌីៈ ចំពោះបញ្ហាហ្នឹង នៅក្នុងគំនិតខ្ញុំ គឺ ខ្ញុំមានគំនិត ដែរ ខ្ញុំចង់គេចវេស មិនចង់អោយមាន ឃើញពីបញ្ហាហ្នឹង ប៉ុន្តែខ្ញុំឃើញថា ឥលូវនេះ បើកាលណា គេចាប់ចង គឺ គួរណាមនុស្ស ហ្នឹងគេចាប់ចង បើពិតថា ហ្នឹងវាអាក្រក់ពេក ហើយបានគេចាប់យើងចង

ភារិទ្ធៈ ប៉ុនដូចថាទាក់ទងនឹងគ្រោះថ្នាក់ចរាចរអីមួយ យើងមិនចង់ទៅមើល ចេះតែ កាលណា យើងទៅមើលចេះតែនឹកឃើញ?

រ៉ាឌីៈ អត់ចង់ទេ បាទ ចេះតែនឹកឃើញ

ភារិទ្ធៈ ហើយចុះអារម្មណ៍ដែលចង់ជៀសវាងអញ្ចឹងមានច្រើនអេក៏មានតិចតួច?

រ៉ាឌីៈ មានច្រើន ខ្ញុំចង់អោយជួប មានច្រើន

ភារិទ្ធៈ គេចវេសពីអារឿង ហេតុការណ៍ហ្នឹងអាំ?

រ៉ាឌីៈ បាទ ហេតុការណ៍ហ្នឹង អត់ចង់អោយមានទេ

ភារិទ្ធៈ ហើយចុះរាល់ថ្ងៃបងនឹកឃើញបានល្អិតល្អន់ពីហេតុការណ៍ ឈឺចាប់ដែលបងបានជួបប្រទះ កាលពីជំនាន់ពាឆ្នាំហ្នឹងដែរ?

រ៉ាឌីៈ បាទ ខ្ញុំនឹកឃើញល្អិតល្អន់ណាស់ អ្វីដែលខ្ញុំនៅចាំហ្នឹង គឺខ្ញុំនៅចាំបានច្បាស់ច្រើនពីបញ្ហា ហ្នឹង

ភារិទ្ធៈ រាល់ថ្ងៃបងមានការចាប់អារម្មណ៍ពីសកម្មភាពការងារ រាល់ថ្ងៃរបស់គាត់ហ្នឹង រឺក៏មិនសូវចាប់អារម្មណ៍ ទេ?

រ៉ាឌីៈ ចំពោះការងារ សកម្មភាពការងារ គឺខ្ញុំចាប់អារម្មណ៍ អា៎ រាល់ថ្ងៃខ្ញុំចាប់អារម្មណ៍ការងារច្រើនជាងក្រុមគ្រួសារ ព្រោះថា ខ្ញុំមានពេលទៅជួបប្រពន្ធទៅជួបកូនហ្នឹង វាតិចជាងដែលខ្ញុំត្រូវគិតពីការងារ

ភារិទ្ធៈ អូ ហើយចុះមានដែលមានអារម្មណ៍គិតហាក់ដូចជាខ្លួនឯងគ្មានថ្ងៃអនាគតទៅមុខទេ?

រ៉ាឌីៈ ខ្ញុំដូចជាមានជំនឿមួយ នៅក្នុងចិត្ត ហាក់ដូចជាថាខ្ញុំមិនអស់សង្ឃឹមនៅក្នុងជីវិតទេ

ភារិទ្ធៈ អូ អញ្ចឹងអត់ដែលមានអារម្មណ៍អញ្ចឹងទេអេ?

រ៉ាឌីៈ បាទ អត់ដែលមានទេ អត់ដែលអស់សង្ឃឹមទេ ថ្វីត្បិតតែខ្ញុំក្រ គង់មានថ្ងៃណាមួយ ដែលពេលវេលាមកដល់ គឺខ្ញុំនៅតែដាក់ចិត្តថា ខ្ញុំមានសង្ឃឹម នៅក្នុងជីវិតរហូតទៅដល់ថ្ងៃស្លាប់

ភារិទ្ធៈ ហើយចុះមានដែលមានអារម្មណ៍ចង់ជៀសវាងមិនអោយគិតពីអារឿងអតីតកាលដូចថាចេះតែនឹកឃើញ ចេះតែអីមិនអោយ គិត?

រ៉ាឌីៈ ខ្ញុំអត់ចង់គិតទេ ចេះតែនឹកឃើញ

ភារិទ្ធៈ ហើយអារម្មណ៍ដែលមិនចង់អោយគិតហ្នឹងមានច្រើនអេមានតិចតួច?

រ៉ាឌីៈ មានច្រើនដែរ មិនចង់អោយគិត រឿងរ៉ាវ ប៉ុន្តែវាចេះតែនឹកឃើញ ដូចថាខ្ញុំជំរាបអញ្ចឹងថា បើឃើញគេដើរជាមួយឪពុកគេ គេហៅឪពុកគេ នៅក្នុងចិត្តនឹកឃើញថា អឺ ហេតុតែ ខ្ញុំ អត់មានឪពុក កំព្រាតាំងពីអាយុប៉ុណ្ណេះៗ បើសិនជាគាត់នៅ គាត់ចំណាស់ប៉ុណ្ណេះពេលណានេះ ខ្ញុំចាប់អារម្មណ៍នឹកឃើញពីរឿង

ភារិទ្ធៈ ហើយចុះបងនៅពេលដែលបងនឹកឃើញហេតុការណ៍ឈឺចាប់អីអញ្ចឹងនៅក្នុងខ្លួនបង រឺក៏នៅក្នុងអារម្មណ៍បង រឺក៏នៅក្នុងអារម្មណ៍បងមានប្រតិកម្មអីភ្លាមៗទេ ដូចថាពេលដែលនឹកឃើញទៅ ចេះតែឈឺក្បាល ញ័រទ្រូង

រ៉ាឌីៈ បាទ នឹកឃើញឈឺក្បាលហើយ ហប់

ភារិទ្ធៈ ភ្លាមៗហ្នឹងហ្មងអេ?

រ៉ាឌីៈ បាទ ភ្លាមៗតែម្តង

ភារិទ្ធៈ ឈឺក្បាលញ័រទ្រូង ញ័រដៃ ញ័រជើង?

រ៉ាឌីៈ បាទ

ភារិទ្ធៈ អារម្មណ៍បែបហ្នឹង មានតិចតួច មានខ្លាំងអេល្មម?

រ៉ាឌីៈ មានតិចតួច ខ្ញុំច្រើនតែឃើញ ប៉ះហេតុការណ៍ បាទខ្ញុំចេះតែស្តាប់ចាំនឹកឃើញរឿងហ្នឹង បានមានហេតុការណ៍អីពីមុខ បានខ្ញុំនឹកឃើញរឿងហ្នឹងហើយ ដូចថាខ្ញុំជួប ជួនកាលទៅវាលំបាកខ្លាំង ហើយវាធ្វើអីមួយ ដោះស្រាយនៅក្នុងក្រុមគ្រួសារ ខ្ញុំមិនចេញ ខ្ញុំជាមេគ្រួសារហ្នឹងគិតមិនចេញ អាំ ធ្វើម៉េច បើសិនជាពុកខ្ញុំនៅអត់ពិបាក ទេហើយការហ្នឹង ប្រហែលជាគាត់ ជួយគិតជួយដោះស្រាយហើយដែរអាហ្នឹងហើយអាហ្នឹងមានអាផងមានពីផងអាំ

ភារិទ្ធៈ បាទ

រ៉ាឌីៈ ហើយដែលវាអត់ហ្នឹង អាពេលណាឡើង វាចាប់ផ្តើមមានអារម្មណ៍គិត ពីអតីតកាលហ្នឹងច្រើន

ភារិទ្ធៈ ហើយចុះរាល់ថ្ងៃបងមានអារម្មណ៍ថាអ្នកដទៃទៀតយល់មិនច្បាស់លាស់អំពីរឿងរ៉ាងឈឺចាប់ ដូចថារាល់ថ្ងៃបងឈឺចាប់អាណា ប៉ុន្តែមានអារម្មណ៍ថាអ្នកដទៃមិនយល់ពីអារម្មណ៍ឈឺចាប់របស់បង

រ៉ាឌីៈ ខ្ញុំមានអារម្មណ៍គិតថា គិតថា ប្រហែលជាគេមិនបានឆ្លងកាត់ដូចខ្ញុំ ហើយក៏ខ្ញុំ មកគិតគ្នាដែរ ថា ប្រហែលជាខ្ញុំ យល់នេះមិនត្រឹមត្រូវ ហើយក៏មិនប្រាកដថា ខ្ញុំគិតនេះ ថាត្រូវ

ភារិទ្ធៈ ហើយចុះអារម្មណ៍ដែលថា បងមើលទៅ អ្នកដទៃមិនសូវយល់ ពីការឈឺចាប់របស់មានតិចតួច មានច្រើន រឺក៏ល្មម?

រ៉ាឌីៈ មាន មានតិចតួច ហើយខ្ញុំមិនសូវប្រើអារម្មណ៍ ទាំងអស់នេះ បើសិនជាអ្នកដទៃដែលមិនមែនជាញាតិ គឺ ខ្ញុំមិនសូវប្រើទេ ព្រោះខ្ញុំគិតថា វាមិនមែន ជារឿងគេទេ មានតែខ្លួនយើងទេ ដែលដឹងថាខ្លួនយើងឈឺចាប់

ភារិទ្ធៈ ហើយចុះរាល់ថ្ងៃបងមានការលំបាកនៅក្នុងការបំពេញមុខងារ អីផ្សេងៗអីផ្សេងៗទៀតទេ?

រ៉ាឌីៈ ខ្ញុំហាក់ដូចជាមានការលំបាកខ្លះ មិនលំបាកខ្លះ

ភារិទ្ធៈ បន្តិចបន្តួចទេអេ?

រ៉ាឌីៈ បាទ តិចតួចទេ ប៉ុន្តែ វា

ភារិទ្ធៈ ហើយចុះរាល់ថ្ងៃមានដែលបន្ទោសខ្លួនឯងចំពោះរឿងរ៉ាវ ដែលបានកើតមានកាលពីអតីតកាលហ្នឹងដែរ?

រ៉ាឌីៈ ខ្ញុំ ខ្ញុំមានច្រើន អញ្ចឹងបានថា អ៊ីដែលខ្ញុំ ធ្វើ ខ្ញុំតែងតែ គិតសំរាប់ថ្ងៃមុខ ខ្ញុំមិនចង់អោយមានវិប្បដិសារី កន្លែងខ្លះ ខ្ញុំគិតថា បើសិនជាខ្ញុំកុំធ្វើមិនមានរឿងហ្នឹង កើតឡើងទេ ណាស់ បើសិនជាខ្ញុំមិនធ្វើមិនមានរឿងហ្នឹងកើតឡើងទេ ខ្ញុំតែងតែគិតអញ្ចឹងៗ មុននឹងខ្ញុំធ្វើ ខ្ញុំគិតអា៎ បន្ទាអោយហើយ បើសិនជាធ្វើទៅ មានរឿងកើតឡើងថ្ងៃក្រោយយើងត្រូវជួបប្រទះយ៉ាងម៉េច បាត់បង់កិត្តិយសយ៉ាងម៉េច ខ្មាសអៀនយ៉ាងម៉េច បើសិនជាអញ្ចឹង យកល្អយើងគេចពីហ្នឹង កុំធ្វើមើល អាចផុតដែរ ខ្ញុំមានអារម្មណ៍ថា ការស្តាយក្រោយរបស់ខ្ញុំ វាមាន មិនមែនជារឿងអីធំដុំទេ អាតូចៗ ហ្នឹង ក៏វាស្តាយដែរ

ភារិទ្ធៈ ហើយចុះមានដែលមានអារម្មណ៍បន្ទោសខ្លួនឯង ដែលបានរស់នៅសព្វថ្ងៃហ្នឹង?

រ៉ាឌីៈ បន្ទោស គឺមានខ្លះដែរ បន្ទោសនៅត្រង់ថា ដែលយើងគិតខុសអា៎ គិតលើជំហ៊ាន មួយជំហ៊ានអីអញ្ចឹង ធ្វើអោយ វាផ្តេកខ្លាំងទៅលើអារម្មណ៍របស់ខ្លួនហ្នឹង គឺទៅលើជំនឿនិស្ស័យ ព្រំលិខិត

ភារិទ្ធៈ ហើយចុះរាល់ថ្ងៃមានការអស់សង្ឃឹមដែររឺអត់ទេ?

រ៉ាឌីៈ ពេលខ្លះដូចអស់សង្ឃឹមដែរ ប៉ុនតែខ្ញុំនៅតែមានជំនឿចេះតែ

ភារិទ្ធៈ មានតិចតួចដែរ?

រ៉ាឌីៈ បាទ តិចតួច

ភារិទ្ធៈ ហើយចុះមាននឹកឃើញខ្មាសខ្លួនឯងចំពោះហេតុការណ៍ដែលឈឺចាប់ រឺក៏ហេតុការណ៍អីផ្សេងៗ ដែលជួបប្រទះកាលពីជំនាន់បីឆ្នាំទេ មើលទៅ ខ្មាសអៀនខ្លួនឯងទេ?

រ៉ាឌីៈ បើនិយាយពីក្នុងរយៈពេលបីឆ្នាំ ដូចថាមានអារម្មណ៍ថាខ្មាសអៀនខ្លួនឯង ព្រោះកាលហ្នឹងគេចាប់បង្ខំហើយ យើងបន្ទោសលើខ្លួនឯងអត់បានទេ ដូចបច្ចុប្បន្នអី យើងបន្ទោសបានដូចថា អ៊ីដែលយើងធ្វើទៅខុស យើងចេះតែបន្ទោសខ្លួនយើងហើយ ព្រោះយើងមិនបានចាប់បង្ខំទេ យើងធ្វើដោយសុទ្ធចិត្តខ្លួនឯង នេះបានជំនាន់នោះ ខ្ញុំអត់មានថាស្តាយ

ខ្លួនឯងទេ

ភារិទ្ធៈ ហើយចុះបងមានដែលមានអារម្មណ៍ ចេះតែចំណាយពេលឆ្ងល់គិតឆ្ងល់ថា ហេតុអីបានជារឿងរ៉ាវ ឈឺចាប់កាលពីបីឆ្នាំ កើតមានចំពោះបង មានគិតទេ?

វ៉ាឌីៈ ខ្ញុំគិតច្រើន បើនិយាយពីបញ្ហានេះ គឺខ្ញុំបានគិតច្រើន ចេះតែគិតឆ្ងល់ ថា ហេតុអីបានគេអ្នកដឹកនាំមនុស្សដូចគ្នា គេសុទ្ធតែអ្នកចេះដឹងហើយ នាំមនុស្សទៅធ្វើដល់កន្លែងអស់នោះ រឺមួយក៏ខ្ញុំមាន អា គ្រាន់តែអត្ថយគិតយូរៗទៅ មិនទៅជាស្អីទេ ពេលខ្លះក៏ខ្ញុំមានវិញ្ញាណទី៦ មកដល់ ដែលវាកើតឡើងតែមួយភ្លែតៗ ខ្ញុំគិតឃើញដល់តែរហូតប្រហែលជាគេចង់យក ខ្មែរយើងនេះធ្វើជាវិសោធនកម្ម មួយ ដែលថាអោយការរស់នៅ ការ ចិញ្ចឹមជីវិតសរីរាង្គកាយ ត្រូវការចាយទៅលើវិតាមីនណាមួយប៉ុន្មានៗ រឺក៏អាចថាបាន ចេះគិតទៅ ដល់អាកន្លែងអាហ្នឹងដែរ ទៅជាអញ្ចឹងទៅវិញ អាហ្នឹងបានថា ត្រឹមតែដកស្ទូងលើកភ្លឺ ទប់ភ្លឺអី ឥលូវអាណានេះ អី គេធ្វើរបស់គេអស់ហើយ យើងកុំបន្ទុំអី គេធ្វើបានហើយ សួរទៅ យើងធ្វើបានទេ យើងហូបឆ្អែតទេ យើងហូបមិនឆ្អែតទៅទៀត ហើយចុះឥលូវគេធ្វើខំទេ គេមិនខំទេ ហើយគេហូបមិនអស់ ហើយខ្ញុំចេះតែគិតអញ្ចឹង ខ្ញុំចេះតែគិតអញ្ចឹង ហើយចុះម៉េចក៏ផ្ទុយគ្នាស្រឡះម៉េះ

ភារិទ្ធៈ ហើយចុះពេលដែលបងគិតច្រើនអីអញ្ចឹង មានដែលគិតថា គិតៗទៅ គិតច្រើនពេក មានអារម្មណ៍ហាក់ដូចជាខ្លួនឯងហ្នឹងចង់ឆ្កួតទេ?

វ៉ាឌីៈ បាទ មានអារម្មណ៍ថា ជួនកាលចង់ឡប់ ឡប់ទៅ

ភារិទ្ធៈ ហើយចុះអារម្មណ៍បែបហ្នឹងមានខ្លាំងអេក៏មានតិច?

វ៉ាឌីៈ មានតិច មានតិចបាទ មិនមានច្រើនទេ

ភារិទ្ធៈ ហើយចុះមានដែលមានអារម្មណ៍ អើ រាល់ថ្ងៃហ្នឹងមានដែលមានអារម្មណ៍ គិតថាមានតែបងម្នាក់ ដែលរងនូវការឈឺចាប់?

វ៉ាឌីៈ ខ្ញុំមានអារម្មណ៍ថាមិនមែនមានតែខ្ញុំម្នាក់ទេ គឺមានអារម្មណ៍ការឈឺចាប់ច្រើននាក់ណាស់ប្រជាជនខ្មែរយើងអាំ បើសិនជាមានតែម្នាក់ឯងរបៀបនេះ ប្រហែលជាមិនអាចទប់បានទេ បើមានទស្សនៈ បើយល់ឃើញថា គឺមានគេច្រើនធ្ងន់ធ្ងរជាងយើងច្រើនទៀត មានអារម្មណ៍ថា ទ្រាំរស់នៅនឹងគេបាន

ភារិទ្ធៈ ហើយចុះរាល់ថ្ងៃមានអារម្មណ៍ថា អ្នកដទៃ សុទ្ធតែជាសត្រូវនឹងខ្លួនឯងទេ?

រ៉ាឌីៈ មិនមាន អត់មានទេ អ្នកដទៃ ខ្ញុំមានអារម្មណ៍ថា ជាមិត្ត ហើយខ្ញុំមានអារម្មណ៍អញ្ចេះ មួយដែលខ្ញុំគិតថាព្រួយអាំ គឺ អារម្មណ៍ច្រណែនអ៎ អារម្មណ៍ច្រណែន គឺខ្ញុំគ្មាន

ភារិទ្ធៈ អូ

រ៉ាឌីៈ ខ្ញុំតាំងចិត្តថា ខ្ញុំមិនច្រណែនអ្នកដទៃទេ គេមានបានអាម៉េចគឺជួយអរគេ ខ្ញុំយល់ថា អញ្ចេះ ថ្ងៃនេះគេមានគេបាន បើសិនជាយើងទៅពឹងគេ គេអ្នកមាន ប្រហែលជាគេ អ្នកមាន ប្រហែលជាយើងជួយយើងទាន់ ប៉ុន្តែបើសិនជាគេក្រដែរ យើងមានអាសន្ន យើងទៅពឹងគេ ប្រហែលគ្នា គ្មានអីជួយអញ្ចឹង ខ្ញុំជួយអរគេណាស់ ខ្ញុំមិនច្រណែនគេទេ

ភារិទ្ធៈ និយាយអញ្ចឹងបងមានអារម្មណ៍ ដូចជា ហាក់ដូចជាគ្មាននរណាម្នាក់គួរអោយពឹងពាក់បានទេ?

រ៉ាឌីៈ មាន

ភារិទ្ធៈ មាន តិចតួច អេក៏មាន ខ្លាំងបង?

រ៉ាឌីៈ អារម្មណ៍របស់ខ្ញុំដែលគិតថា គ្មានអ្នកដែលពឹងពាក់បានហ្នឹងគឺមានច្រើន រាល់ថ្ងៃ ហាក់ដូចជាខ្ញុំ មួយជីវិតរបស់ខ្ញុំហាក់ដូចជាដើរនៅលើស្ពានអញ្ចឹង ដើរលើស្ពានហើយមិនដឹងជាស្ពានហ្នឹងដល់ត្រឹមណា ហើយមានគោក ទៅដល់ឆ្លងទៅហ្នឹង ហើយតែដើរឆ្លងផុតស្ពានហ្នឹង ផុត ឆ្លងទឹកគ្នា ក៏ថាបាន មានអារម្មណ៍អញ្ចឹង ហើយបើសិនជាខ្ញុំអស់ឪពុកអស់ម្តាយ គឺមានអារម្មណ៍មួយផ្សេង ហើយ កាលមុនមានម្តាយ មិនមានថាចង់អោយគាត់ជួយលុយ មាសប្រាក់អីទេ គឺថា មានជំរមួយថាមានអាង ហើយអញ្ចឹងបានខ្ញុំថា អារម្មណ៍ខ្ញុំមួយគិតញឹកញាប់ គិតពីបញ្ហាហ្នឹង គេគ្រាន់តែហៅឪពុកគេមួយម៉ាត់ ថាអឺប៉ា ខ្ញុំនៅទីនេះ ថាអាយុប៉ុណ្ណេះ ខ្ញុំនឹកឃើញថា បើសិនជារូបគាត់មិនមានអីអោយខ្ញុំ អោយតែគាត់នៅជាជំហ អោយហៅខ្ញុំអប់រំ ខ្ញុំអីយ៉ាងម៉េចៗ ដល់តែឪពុកខ្ញុំអត់អញ្ចឹង គឺ ដល់តែខ្ញុំអត់អញ្ចឹងគឺយ៉ាប់ ព្រោះអីដែលខ្ញុំគិត មិនប្រាកដ ថាគិតត្រូវទេ គិតថាប្រហែលជាមានការខ្វះ គិតខុសទៀត ហើយបើសិនជាខ្ញុំគិតហើយ ឪពុកខ្ញុំមួយទៀតនៅពីក្រោយខ្នង គាត់អោយយោបល់ទៅ ខ្ញុំដឹងថាត្រូវ ហើយមានអ្នកលើកសរសើរ ពេលដែលខ្ញុំគិតត្រូវហើយ អឺ មានតែគេទេ គិតអញ្ចឹង ត្រូវ ចង់បានអាហ្នឹងដែរ ចង់បាន

អាហ្នឹង

ភារិទ្ធៈ ហើយចុះបងកន្លងមកថ្មីៗ ហ្នឹង ខ្ញុំចង់សួរបង ដែលមានធ្លាប់អើ ទៅធ្វើអីមួយ ស្រាប់តែគេ ប្រាប់ រឺក៏អ្នកដទៃប្រាប់ អញ្ចឹង ប៉ុន្តែការពិតយើងទៅធ្វើមែនអាំ ប៉ុន្តែដល់តែគេប្រាប់ទៅ រកនឹកមិនឃើញសោះមានទេ មានធ្លាប់អញ្ចឹងទេ មានអារម្មណ៍អញ្ចឹងទេ?

រ៉ាឌីៈ ខ្ញុំក្រែងលំ នៅពេលដែលខ្ញុំ ហូបចុកអីទេ អេ បើថាមិន ជា ហូបចុកអីទេ គឺអារម្មណ៍ខ្ញុំនៅចាំបានច្បាស់ណាស់ នៅចាំបានច្បាស់ណាស់

ភារិទ្ធៈ ហើយចុះដូចមានដែលមានអារម្មណ៍ថាដូចជា មានមនុស្សពីរនាក់នៅក្នុងខ្លួន ដូចថានៅក្នុងខ្លួនយើងជាមនុស្សម្នាក់ហើយណា

រ៉ាឌីៈ បាទ

ភារិទ្ធៈ ប៉ុន្តែមានអារម្មណ៍ដូចជាមនុស្សពីរនាក់ ធ្វើអី ចេះតែ ខុចខុស ដូចជាអ្នកទីមួយកំពុងតែធ្វើ តែអ្នកទីពីរកំពុងតែតាមដាន ដូចថាសង្ស័យលើខ្លួនឯងមានទេ?

រ៉ាឌីៈ អាហ្នឹងដូចជាមិនមាន

ភារិទ្ធៈ ហើយចុះមានដែលមានអារម្មណ៍ថានរណាម្នាក់ដែលបងទុកចិត្តហើយបែរជាក្បត់អីអញ្ចឹង?

រ៉ាឌីៈ មិនមាន

ភារិទ្ធៈ អញ្ចឹងសំនួរទាក់ទងប្រវត្តិបងកាលពីជំនាន់អើ ប៉ុល ពត ហើយនិងហេតុការណ៍រន្ធត់ផ្សេងៗដែលបងធ្លាប់បានជួបប្រទះ ធ្លាប់បាន ឃើញអើ ធ្លាប់បានលឺហ្នឹង ហើយនិងអារម្មណ៍ដែលបងមានសព្វថ្ងៃ ដែលអាចជាមានផលប៉ះទង្គិចពី ហេតុការណ៍ទាំងអស់ហ្នឹងចប់ហើយ ប៉ុន្តែ អើ ខ្ញុំចង់ដឹង ហើយសួរសំនួរខ្លះទៀត ពីការយល់ឃើញ របស់បងផ្ទាល់ ទាក់ទងពីរឿងរ៉ាវ ការកាត់ទោសខ្មែរក្រហមហើយនិងការដោះស្រាយបញ្ហាផ្លូវចិត្តដែលបងធ្លាប់ដោះស្រាយកន្លងមក ពេលដែលបងមានបញ្ហាផ្លូវចិត្ត បងដោះស្រាយយ៉ាងម៉េច

រ៉ាឌីៈ បាទ

ភារិទ្ធៈ ប៉ុន្តែ ខ្ញុំចង់សំរាកអោយបងពិសារទឹកពិសារអីសិន មុននឹងបន្តទៅទៀត

រ៉ាឌីៈ ខ្ញុំវា ធុញថប់នឹងការរស់នៅពេក ដូចថា ពេលខ្លះវាលំបាក វាទាល់ពេកទៅណា រស់សឹងតែបែកគ្នាទៅណា ថារស់ទៅទាំងអស់គ្នា អាណា នេះអត់ ទប់ទល់វាធុញថប់ មួយ

ដង មួយដងអាំ

ភារិទ្ធៈ បាទ

រ៉ាឌីៈ អញ្ចឹងបានខ្ញុំគិតពីជីវិតរបស់ខ្ញុំអាំ កើតមកដូចជាគ្មានជួបកន្លែងណាដែលសប្បាយ

ភារិទ្ធៈ បាទ

រ៉ាឌីៈ អត់មានសប្បាយទេ ពីតូចមកដល់អាយុ៧ឆ្នាំ ចាប់ផ្តើមដឹងក្តីចូលរៀនដឹងតែពីរៀន ចាប់ផ្តើមរៀន ហើយបានបីបួនឆ្នាំនៅតូចហ្នឹង ជាមួយឪពុកម្តាយ ហើយក្រោយពីហ្នឹង មានសង្គ្រាមកើតឡើងហើយ បាទ ចប់ លុន ណុលហើយប៉ុល ពត ចេញពីប៉ុល ពតមក បាទ ពេញហ្នឹងរហូត ហើយ៧៩នេះ ថ្ងៃ១ ខសភា សាលា១ ខសភា គឺជាថ្ងៃដែលខ្ញុំចូលរៀនដំបូង ម្តាយមេម៉ាយ ប្អូនស្រីនៅផ្ទះ ជាមួយម្តាយហើយឪពុក អញ្ចឹងខ្ញុំគ្មានអីទេ ប៉ុន្តែខ្ញុំឆ្លៀតទៅរៀន ទៅទៀត បាទ បាទ ខ្ញុំចូលរៀនតាំងពីឆ្នាំ៧៩ហ្នឹងរហូតរៀនមកជិតប្រលងបាក់ឌុប នៅឆ្នាំ១៩៨៦ ឆ្នាំហ្នឹង ចាប់ផ្តើមមកដល់ ចេញធ្វើការមកអស់ លទ្ធភាព ម្តាយឈឺផង អើ ដូចថាការវេទនារបស់គាត់ ដូចខ្ញុំ ការសរសេរប្រវត្តិរូប សរសេរអត់កើតឯណា សរសេរហើយដល់តែយកអោយគេអាន ដល់តែគេយំ ព្រោះថាវាកំសត់ពេកអាំ ថ្ងៃព្រហស្បត្តិថ្ងៃសុក្រអីអញ្ចឹងអាំ គេខ្ចីហ្នឹង គេចាប់ផ្តើមទូរស័ព្ទអី ដើម្បីបានលុយហ្នឹង ខ្ញុំទៅរៀន ជួនដើរ ឆ្លុះ ត្រីយប់អញ្ចឹង

ភារិទ្ធៈ ហើយចុះបងម្សិលមិញលឺបងនិយាយថា ធ្លាប់លឺឪពុកម្តាយនិយាយជុំគ្នា ពីរឿងការនេះហ្នឹងអាំ

រ៉ាឌីៈ ខ្ញុំលឺសំដី ដែលឪពុកខ្ញុំនិយាយជាមួយម្តាយ ក្រោយពេលជាមួយគាត់ គាត់ចូលទៅក្នុងវិញអាំ គាត់ថា យើងនៅទីនេះ ប្រហែល???អញ្ចឹងគួរយើងវិលទៅវិញ ហើយពេលដែលរដ្ឋទៅវិញហ្នឹង គឺមានចិត្ត ទៅ លាំងៗ ដូចពេល សភាពការណ៍កំពុងតែច្របូកច្របល់ អើ ទ័ពលុន ណុល ចេះតែវាយដើរ ចុះពេញទឹកពេញដីអីអញ្ចឹងយើងមានឱកាសហើយណា ខ្ញុំសរសេរទុកបានច្រើនអាំ ប្រវត្តិ ប៉ុនតែខ្ញុំទុកអោយកូន អោយអីមើលតែប៉ុនហ្នឹង មិនដែលថាបានចង់អោយអ្នកដទៃបានដឹងរឿងអញ្ចឹង

ភារិទ្ធៈ ហេតុអី?

រ៉ាឌីៈ ខ្ញុំមានគំនិតមួយទុកជា អនុសាខ្ពះ បើសិនជាកូនណាដែលវាចាប់អារម្មណ៍អីអញ្ចឹង ទាញ

មកមើលលេងទៅ អោយដឹងថាការឈឺចាប់ការតស៊ូរបស់ឪពុកយ៉ាងម៉េច អីយ៉ាងម៉េច អីអញ្ចឹង អាំ ហើយបើយើងជួបប្រទះរបៀបអាហ្នឹង កុំអោយវាតក់ស្លុតកុំអោយវាភ័យខ្លាច ជាអនុសាវរីយ៍កៃច្នៃ គំនិតហ្នឹងខ្លះទៅ បូកនឹងសកម្មភាពរបស់យើងខ្លះ រកច្រកមួយថ្មីសំរាប់ដោះស្រាយ បញ្ហាចំពោះមុខវា ព្រោះជីវិតរបស់យើងម្នាក់វាមិនប្រាកដថា សុខដុមរមនារហូតទេ

ភារិទ្ធ: បាទ ហើយចុះបើសិនជាបង សរសេរជារឿងទៅ បងមានជាឯកសារទុកផង បងផ្សព្វផ្សាយផង មិនវា

រ៉ាឌី: ខ្ញុំគិតថា បើសិនជាគេអ្នកចូលចិត្ត គេនឹងសប្បាយចិត្តអាន តែបើសិនជាគេមិនចូលចិត្តគេ ជាមនុស្សដែលមិនចង់អោយគេដឹង អាហ្នឹង ខ្ញុំមានទស្សនៈអញ្ចឹងអាំ

ភារិទ្ធ: អូ ធម្មតាទេ ធម្មតាយើងសរសេរអីមួយ យើងធ្វើអីមួយអាំ គេមិនមែនពេញចិត្តគ្រប់តែគ្នាទេ

រ៉ាឌី: បាទ គេមិនពេញចិត្តទេ

ភារិទ្ធ: យើងមិនអាចតំរូវបានមនុស្សគ្រប់តែគ្នា ទាំងអស់បានទេ អ្នកខ្លះគេចាប់អារម្មណ៍ការងារប្រភេទការងារប្រភេទហ្នឹងទៅ គេចូលចិត្តទៅ វាជារឿងធម្មតារបស់មនុស្សទេ អញ្ចឹងបានគណបក្សមួយ មួយ រឺក៏នេះមួយ មួយគេឃោសនាអីហ្នឹងក៏គេមាន ដូចថានរណាគេចូលចិត្តទាំងអស់ដែរ គេដឹងដែរ

រ៉ាឌី: សរសេរទៅ វាមានការខុស មានត្រូវ វាមានអាការខ្មាសអៀន សមត្ថភាពយើងមិនដឹងយ៉ាងម៉េច វាទុកអោយទុកអោយអីមើលទៅ វាកូនខ្លួនឯង វាខ្មាស វាខ្មាសតិចដែរ

ភារិទ្ធ: ហើយចុះអារម្មណ៍អញ្ចឹងៗ យើងអាចមានតាំងពីមុនមកដែរ រឺអត់ដោយសារតែពីមុនមកយើងចេះតែខ្លាចអ្នកដទៃគេ?

រ៉ាឌី: បាទ មានគេ គេ ដូចថាខ្ញុំថាអញ្ចឹង ចេះតែមានអារម្មណ៍ភ័យ ព្រួយខ្លាចតាំងពីជំនាន់ប៉ុល ពតហ្នឹងឯង ដូចថាវាធ្វើអីទៅ វាប៉ះពាល់ គេថាចោទឪពុកក្បត់នោះ ចោលដំណឹងទៅ ដល់តែអញ្ចឹងវាចេះតែធ្វើអីទៅ វាខ្លាច ខ្លាចគេ មិនពេញចិត្តអីអញ្ចឹងទៅ មានអារម្មណ៍ថាឃើញ វាអ្វីដែលយើងខំប្រឹងធ្វើបានអស់ហើយ គេយកទៅដល់បោះចោលវាមិនបានខាន បានអីមើល វា បើសិនជាយើងដឹងយើងតូចចិត្តអីអញ្ចឹងអាំ ហើយថា

កុំមិនបាច់

ភារិទ្ធៈ ហើយអញ្ចឹងបងខ្ញុំចង់សួរបងបន្ថែមទៀត ដើម្បីបញ្ចប់សំនួរតែម្តង

ភ៉ឌីៈ បាទ

ភារិទ្ធៈ ទាក់ទងនឹងរបបខ្មែរក្រហម មេដឹកនាំខ្មែរក្រហម បងធ្លាប់ស្គាល់រឺក៏ធ្លាប់លឺឈ្មោះមេណាដែរ មេដឹកនាំធំៗណាខ្លះដែរ ដែលបងធ្លាប់ប៉ុល ពត

ភ៉ឌីៈ នៅក្នុងរបបវាតែម្តង គឺខ្ញុំអត់បានដឹង ថា អ្នកណា ជាអ្នកដឹកនាំ អ្នកណា ជា ស្អី អត់បានដឹង ច្បាស់ ក្រោយពេលរំដោះទៅ បានដឹងតាមរយៈ ដូចជាការដេរគ្នាទៅវិញទៅមកអីអញ្ចឹងហ្នឹង បានដឹង ថាអូ អានេះ ដឹកនាំ អាជំនាន់នេះ បើនៅក្នុងរបបនេះតែម្តងគឺអត់បានដឹងទេ

ភារិទ្ធៈ ហើយចុះអត់មានគេប្រជុំជាកុមារជាកងអីមានថ្នាក់នេះ គេនិយាយពីមេធំៗ ?

ភ៉ឌីៈ បើនិយាយពីការប្រជុំ គឺគេនិយាយតែពីរឿងការងារដែលយើងត្រូវធ្វើនិងកំហុសឆ្គង ហើយបើយើងនិយាយដល់ថ្នាក់លើ គឺនិយាយពីអង្គការ ពីអង្គការហ្នឹង

ភារិទ្ធៈ អូ គេអត់មាននិយាយចំឈ្មោះ អ្នកណា

ភ៉ឌីៈ បាទ សព្វថ្ងៃ វាសម្តេច ហ៊ុន សែនអញ្ចេះ សម្តេចក្រុមព្រះលោកមានបន្ទូល អញ្ចុះ អត់មានទេ ជំនាន់នោះអត់មានទេ

ភារិទ្ធៈ អត់មានចេញឈ្មោះអញ្ចឹងទេ?

ភ៉ឌីៈ បាទ អ់តមានទេ អញ្ចឹងយើងអត់អាចដឹងឈ្មោះអ្នកដឹកនាំអីខ្លះ ជំនាន់នោះ តែឥលូវយើងអាចដឹងបាន

ភារិទ្ធៈ ហើយចុះឥលូវបងដឹងថាធ្លាប់ ដឹង ថាឥលូវហ្នឹងស្គាល់ រឺក៏លឺឈ្មោះណាខ្លះដែរ ឈ្មោះណាខ្លះដែរ?

ភ៉ឌីៈ ឈ្មោះដែលធ្លាប់លឺមានតែប៉ុល ពត អៀង សារី ខៀវ សំផន តាម៉ុក នេះ ទើបតែលឺឈ្មោះខ្លះ នៅពេលដែលយើងប្រកាសចរចា កាលមុន គ្រាន់តែវាជាលាយមេទ័ពមួយ មេទ័ពច្បាំងម្នាក់អីអញ្ចឹងដែរណា

ភារិទ្ធៈ បាទ

ភ៉ឌីៈ ដល់តែឥលូវទើបតែលឺស្ថានភាពឈ្មោះខ្លាំងនៅពេលដែលចរចារអីអញ្ចឹងទេ លឺតែប៉ុលពត

អៀង សារី ខៀវ សំផន តែប៉ុណ្ណឹង

ភារិទ្ធៈ មានដឹងថាអ្នកហ្នឹងពីមុនមកធ្វើអីដែរ?

រ៉ាឌីៈ អត់ដឹងថាធ្វើអី ប៉ុន្តែគ្រាន់តែដឹងថា ក្រោយពេលរំដោះហ្នឹងហើយហ្នឹង ជាអ្នកដឹកនាំនៅក្នុងរបប

ភារិទ្ធៈ គ្រាន់តែដឹងជាអ្នកដឹកនាំ?

រ៉ាឌីៈ បាទ

ភារិទ្ធៈ ប៉ុន្តែគ្រាន់តែតួនាទីពីមុនមកធ្វើអីអត់ដឹង?

រ៉ាឌីៈ បាទ អត់ដឹង

ភារិទ្ធៈ ហើយចុះមានដឹងថាពេលថ្ងៃមេដឹកនាំដែលបងស្គាល់ហ្នឹង រឺក៏លឺឈ្មោះហ្នឹងអ្នកណាខ្លះនៅរស់ អ្នកណាស្លាប់ មានដឹងទេ?

រ៉ាឌីៈ ខ្ញុំនៅដឹងបាន ទីមួយ ខៀវ សំផនចូលមកហើយ មាន
បាតុកម្មកើតឡើងអី វាយចោលទៅវិញអីហ្នឹង នៅឆ្នាំ១៩៩៣ ដូច១៩៩១អីហ្នឹង កាលពេល អ៊ុន គាត់ ឃើញខៀវ សំផន តាមរយៈទូរទស្សន៍ហ្នឹង ឃើញមេខ្មែរក្រហមមួយ ហើយក្រោយមកទៀត សូម្បីតែអៀង សារីនេះ អើ អាហ្នឹង អៀង សារី ដែលសរសេរនៅក្នុងសៀវភៅនេះដែរ វាប្រវត្តិរបស់គាត់ នៅប៉ៃលិន ពេលថ្ងៃ ខៀវ សំផនហ្នឹងឯងអាំ អ្នកសរសេរថាគាត់អត់បានដឹងអី រឿងរ៉ាវអី អត់ ខ្ញុំទិញអត្ថបទហ្នឹងមើល ដូចថា ខ្ញុំដូចថាមានការរិះគន់ច្រើន ដូចថាមិនគួរទទួលយកបានអាំ ហើយរឿងមួយ ខ្ញុំនៅរបបហ្នឹង ខ្ញុំមិនបានដឹង ថាគេជាអ្នកដឹកនាំអីបន្តិចអាំ អ្នកដឹកនាំអីដែរទេ ប៉ុន្តែគេថាគេមិនដឹងអាំ បើតាមចិត្តខ្ញុំមួយដែលថាមិនដឹង ក៏អ្នកដទៃដែលអ្នកដែលគេគ្រប់គ្រងការងារខ្លះគេដឹង អ្នកឯងធ្វើការនៅហ្នឹង មកសរសេរថាខ្លួនមិនដឹង រឿងមួយដែលមិនអាចទទួលយកបានអា

ភារិទ្ធៈ អាហ្នឹងដឹងថានៅរស់អេ ពីរនាក់អំបាញ់មិញហ្នឹងអេ ដូចអៀង សារី ហើយ ខៀវ សំផន ដឹងថានៅរស់?

រ៉ាឌីៈ បាទ ដឹងថាពីរនាក់ហ្នឹង ហើយចុះពីណាទៀតដែលនៅរស់ វាចេះនៅក្នុងរបបហ្នឹងដឹងនៅក្រោយពេលដែលរំដោះហើយទេ រំដោះហើយដឹង ថា អូ ដូចថាភ្នំវិល្លិ៍

នរណាគេ អ្នកកាន់កាប់ មានឈ្មោះណានេះអញ្ចឹងទៅ ស្គាល់តាមរយៈ អញ្ចឹងៗទៅ តាមរយៈប្រជុំជាមួយអង្គការ និយាយទៅ តែពីអង្គការនៅថ្នាក់លើ អញ្ចឹងអង្គការថ្នាក់លើហ្នឹង បើខ្ញុំគិតទៅ វាកើតទៅតាមត្រឹមឃុំទៅ ប្រជុំជាមួយយើង ជាកងប្រចាំឃុំ គឺចប់នៅត្រឹមមេឃុំហ្នឹងតែម្ដង គឺអង្គការនៅថ្នាក់លើគេ គឺគេទទួលបន្ដបន្ទាប់ៗ គឺខ្ញុំមិនដឹងអាណាមួយអ្នកចេញប្រកាស ថាត្រូវអោយអញ្ចោះ ធ្វើអញ្ចុះអត់ដែលលឺ

ភារិទ្ធៈ ហើយចុះបងមានស្គាល់អ្នកដឹកនាំ ភូមិឃុំស្រុកអីទេ កាលពីជំនាន់ហ្នឹងទេ ខេត្តអី?

រ៉ាឌីៈ មិនដឹង

ភារិទ្ធៈ អត់ដែលដឹងដែរ

រ៉ាឌីៈ បាទ តាម៉ុក លឺតែតាម៉ុកៗៗហ្នឹង ប៉ុន្តែមិនបានដឹងថាតាម៉ុកហ្នឹងទទួលបន្ទុកអីទេ លឺតែឈ្មោះ មិនដឹងតាម៉ុក ហ្នឹងទទួលបន្ទុកអីអត់ដឹងទេ

ភារិទ្ធៈ ហើយចុះបងឥលូវដោយសារបងនេះ ខ្ញុំចង់សួរបងថា បងចង់ដឹងរាល់ថ្ងៃមេធំៗ មេខ្មែរក្រហមណាខ្លះ ការដឹកនាំកាលពីជំនាន់ប៉ុល ពតហ្នឹងនៅរស់ អ្នកណា ណាស្លាប់ ហើយអ្នកណាខ្លះដែលនៅរស់ហើយ ដែលគេចាប់ឃុំឃាំង ហើយអ្នកណាខ្លះដែលនៅរស់ហើយគេ នៅមានសិទ្ធដើរហើរ ចង់ដឹងដែរ

រ៉ាឌីៈ ខ្ញុំចង់ដឹង ប៉ុនគ្រាន់តែថា វាហាក់ដូចជាមិនចាំបាច់ពេក ព្រោះខ្ញុំគិតថាវាហួសសមត្ថភាពដែលគិតអញ្ចឹងទៅ វាត្រូវដឹងអាំ គេថាអញ្ចឹង បើថាវាមានត្រឹមតែឯកសារ អីដែលថា ដឹងត្រឹមតែដឹងទៅ យើងមើលទៅវាមិនគួរអោយអស្ចារ្យប៉ុន្មានទេ

ភារិទ្ធៈ បាទ

រ៉ាឌីៈ អញ្ចឹងការដែលទុកអោយដើរ ការទៅឃុំឃាំង ការយកទៅកាត់ទោសវាជារឿងដែលគួរអោយដោះស្រាយអញ្ចឹងគាត់គិតថា គិតហើយរួចស្រេចហើយ គួរទុករឺមិនទុក គួរកាត់ទោស រឺមិនកាត់ទោស គាត់គិតដល់តែគ្រប់ជ្រុងជ្រោយ

ភារិទ្ធៈ ប៉ុន្តែខ្ញុំគ្រាន់តែ ដោយសារតែបងអត់ដឹងអាំ ខ្ញុំគ្រាន់តែចង់ដឹងថា ចង់ដឹងថាពីណាខ្លះដែលដឹកនាំហ្នឹង ហើយរាល់ថ្ងៃនៅរស់ប៉ុន្មាន ហើយស្លាប់ប៉ុន្មាន ហើយអ្នកដែលនៅរស់ហ្នឹងអ្នកណាខ្លះ?

<u>Cassette 2:</u>
<u>Side B:</u>

ភារិទ្ធៈ គ្រាន់តែរហូតមកដល់ឥលូវនៅរស់ហើយនិងអ្នកស្លាប់វីក៏អ្នកនៅរស់ទេ ដែលនៅឃុំខ្នួន តាមខ្ញុំដឹង មានអើ អ្នកដែលស្លាប់មានប៉ុល ពត ស្លាប់ហើយ កាល១៩៩៨ ហើយ សុនសេន ហើយនិងប្រពន្ធសុន សេន អើ ស្លាប់ដែរ ស្លាប់ប្រហែលជា១៩៩៦ ១៩៩៧ ស្លាប់ដោយសារតែខាងប៉ុល ពត បញ្ជារអោយទៅសំលាប់ទេ

រ៉ាឌី: បាទ

ភារិទ្ធៈ ដោយសារតែគេហ្នឹងមានខាងខ្មែរក្រហមគេបែកបាក់គ្នា មួយចង់ចូលជាមួយរដ្ឋាភិបាល មួយមិនចង់ចូលអីអញ្ចឹងទៅ ក៏ប៉ុល ពត សង្ស័យ សុន សេន ក៏ទៅសម្លាប់ទៅ ហើយ ប្រពន្ធប៉ុល ពត ខៀវប៉ុណ្ណារីហ្នឹង ក៏ស្លាប់ដែរ ស្លាប់នៅក្នុងឆ្នាំ ២០០០ នេះ គាត់ចាស់ ដែរ ហើយមួយ ទៀតមិនមែនជាមេធំប៉ុន្មានទេ ប៉ុន្តែគ្រាន់តែល្បីថាឃោរឃៅសម្លាប់ គេនៅភូមិភាគឧត្តរ ហ្នឹងដែរ អឺ ឧត្តរនៅកំពង់ចាមអា៎

រ៉ាឌី: បាទ បាទ

ភារិទ្ធៈ ព្រោះ កែ ពក

រ៉ាឌី: កែ ពក

ភារិទ្ធៈ ស្លាប់ឆ្នាំ ប៉ុន្មានដែរ ប៉ុន្តែស្លាប់ដោយសារជំងឺបេះដូងនៅថៃ ណោះ ហើយអើ រាល់ថ្ងៃ អ្នកនៅរស់មានខៀវ សំផន ហើយដូចបងនិយាយអំបាញ់មិញហ្នឹង គ្រាន់តែនៅរស់ ហើយខៀវ សំផនហ្នឹងពីមុនមកគាត់ជារបបប៉ុល ពតហ្នឹង គាត់ជាប្រមុខរដ្ឋ ហើយនួន ជា នួន ជាកាលពីជំនាន់កម្ពុជាប្រជាធិបតេយ្យហ្នឹង គាត់ជាសភាតំណាងប្រជាជន បើយើងនិយាយថាជាតំណាងរាស្ត្រអី សព្វថ្ងៃនេះអា៎ ហើយអើមានអើ អៀង សារី អតីតរដ្ឋមន្ត្រីក្រសួងការបរទេសសម័យកម្ពុជាប្រជាធិបតេយ្យ ហើយប្រពន្ធគាត់ឈ្មោះ អៀង ធារីទ្ធ ត្រូវជាប្អូនថ្លៃប៉ុល ពតហ្នឹង បិនតែរស់ដែរ បិនតែអៀង ធារីទ្ធគាត់ ជា រដ្ឋមន្ត្រីក្រសួងការអប់រំអីអញ្ចឹងអា៎ ជំនាន់ហ្នឹងអា៎

រ៉ាឌី: បាទ

ភារិទ្ធៈ ហើយយ៉ុន យ៉ាតដែលសុនសេន ដែលខ្ញុំថា ប្រពន្ធសុន សេនហ្នឹង ក៏ ខាងហ្នឹង ដែរ ស្រីៗខាងហ្នឹង គេនៅខាងកិច្ចការហ្នឹងទាំងអស់ គ្នា អា៎ អញ្ចឹងមេធំៗ ហើយដោយឡែក

អ្នកដែលនៅរស់ ហើយដែលត្រូវឃុំខ្លួនមានតែតាម៉ុក ហើយមួយទៀតអើ អើ តាម៉ុកហ្នឹងឃុំខ្លួន ដោយសារតែគាត់ អត់ព្រមចុះចូលជាមួយរដ្ឋាភិបាលហើយគាត់រឹងទទឹង អឺអញ្ចឹងទៅ ហើយម្យ៉ាងទៀត ពាក់ព័ន្ធនឹងការសម្លាប់មនុស្សនៅតំបន់ភូមិភាគនរតី នេះច្រើន ដែលគេថា អ្នកដែលធ្លាប់ឆ្លងកាត់ជំនាន់ខ្មែរក្រហម ប្រហែលជាដឹងថា តើខាងអ្នកនិរតីហ្នឹងយ៉ាងម៉េច ដឹងហើយ ព្រោះអី ខាងអីបើថាពួកនិរតីហ្នឹង ទៅ ស្វាយរៀង ពួកហ្នឹងគេសម្លប់គ្រប់គ្នាអីអញ្ចឹង អាំ

រ៉ាឌី: បាទ គេសម្លប់

ភារិទ្ធ: អាហ្នឹងដោយសារតែពួកហ្នឹងសាហាវ អីអញ្ចឹងអាណា អាហ្នឹងវាមានពាក់ព័ន្ធអញ្ចឹង ហើយអញ្ចឹងបានគេចាប់ខ្លួនគាត់ ហើយមួយទៀតឌុច ឌុចហ្នឹង ឈ្មោះ គាត់ កាំង ហ្កេចអៀវ ទេ ប៉ុន្តែគាត់ជាអ្នកអតីតកាន់គុក ស ២១ ហ្នឹង គុក ទួលស្លែងអាំ គាត់នៅរស់ដែរ ប៉ុន្តែគេនៅឃុំខ្លួនគាត់ គាត់មិនមែនជាមេធំអីដូចតាម៉ុកហ្នឹងទេ ប៉ុន្តែគាត់គ្រាន់តែថាពាក់ព័ន្ធនឹងការឃុំឃាំងកាប់សម្លាប់មនុស្សនៅទួលស្លែងហ្នឹង ហើយដូចថាមេដឹកនាំដែលខ្ញុំរៀបរាប់ប្រាប់បងអំបាញ់មិញហ្នឹងតើ ខ្ញុំចង់ដឹងថា បងមានដែលលឺពីរឿងគេប្រុងនាំយកមេដឹកនាំដែលនៅរស់ហ្នឹង យកមកកាត់ទោស

រ៉ាឌី: ធ្លាប់លឺ

ភារិទ្ធ: ធ្លាប់លឺដែរ?

រ៉ាឌី: លឺតាំងពីពេលណាមកដែរ ខ្ញុំលឺតាំងពី កាល នៅ ដូចតាំងពីឆ្នាំ៩៣មក ក្រោយពីពេលដែលយើងបានបោះឆ្នោតហើយ គេនិយាយពីបញ្ហាហ្នឹង គួរតែនាំខ្មែរក្រហមមកកាត់ទោសកាត់អី ហើយអាការផ្តើងទៅតុលាការ ខ្មែរក្រហម ខ្មែរអី ណា ខ្មែរក្រហមអីកាលពីរដ្ឋកម្ពុជានេះ

ភារិទ្ធ: ដូចខ្ញុំជំរាបនៅក្នុងសៀវភៅនេះ តុលាការហ្នឹងគេធ្វើដំបូង ពេលដែលរដ្ឋាភិបាលយើងស្នើទៅខាងអង្គការសហប្រជាជាតិ ដំបូងអាំ ពេលដែលបោះឆ្នោតហើយ ៩៣ មិនមានរដ្ឋាភិបាល អើ នាយករដ្ឋមន្ត្រីពីរ

រ៉ាឌី: បាទ នាយករដ្ឋមន្ត្រីពីរ

ភារិទ្ធ: បាទ ដល់តែពេលឆ្នាំ១៩៩៧ហ្នឹង រដ្ឋាភិបាលយើងបានស្នើរទៅអង្គការសហប្រជាជាតិ

ដើម្បីសុំជំនួយនៅក្នុងការ កាត់ទោស ដែលថា តុលាការយើងមិនមានលទ្ធភាពគ្រប់គ្រាន់ ដែលថាប្រព័ន្ធច្បាប់យើងខ្សោយអីអញ្ចឹង ចង់កាត់ទោស ជាបទល្មើសជាអន្តរជាតិ អី អញ្ចឹង ដល់តែមានការចូលរួមពីអ្នកច្បាប់អន្តរជាតិ គេចូលរួមមក ហើយការចរចាហ្នឹង ដំបូងឡើងថា ធ្វើតុលាការអន្តរជាតិ ធ្វើនៅ ឡាអេ ធ្វើនៅអីអាំ នៅក្រៅស្រុកទេណា ប៉ុន្តែដល់ពេលចរចារ បើថាយើងចង់ធ្វើនៅក្នុងស្រុក វិញ ក៏បានធ្វើនៅក្នុងស្រុក ក៏គេ ទារ លក្ខខណ្ឌអារឿងតុលាការចំរុះអីអញ្ចឹង អាដូចខ្ញុំរៀបរាប់នេះប្រាប់ហើយ ហើយខ្ញុំ គ្រាន់តែចង់ដឹងថា បងយល់ថា តុលាការហ្នឹង វាចាំបាច់ដែររឺអត់ រឺក៏ការកាត់ទោសហ្នឹង ខ្ញុំយល់ថាការកាត់ទោសហ្នឹងវាចាំបាច់ណាស់ រឿងតុលាការ វាចាំបាច់បានមានការ កាត់ទោសអីមួយ ហើយខ្ញុំគ្រាន់តែគិតថា ការកាត់ទោស ដូចខ្ញុំនិយាយពីម្សិលអីអញ្ចឹង ការកាត់ទោស យើងគួរតែកាត់ទោស តែត្រឹមប៉ុន្មាននាក់អីអញ្ចឹងទៅ ពេលហ្នឹង ហាក់ ដូចជាធ្វើមិនពេញលេញ

រ៉ាឌី: បាទ

ភារិទ្ធ: ព្រោះអ្នកចូលរួមច្រើន ហើយបើយើងអោយកាត់ទោសទាំងអស់គ្នា ចូលរួម ទាំងអ្នក ចូលរួមច្រើនទៅ ក៏វា ពេក អានេះបើទស្សនៈខ្ញុំយល់អាំ

រ៉ាឌី: បាទ

ភារិទ្ធ: ហ្នឹងហើយច្បាប់អាការចរចារវែងឆ្ងាយយូរអង្វែងហ្នឹងក៏ដោយសារតែពាក់ព័ន្ធថា តើ នរណាខ្លះ ដែលត្រូវនាំមកកាត់ទោស ហើយដល់តែពេលចុងក្រោយមក បានអើច្បាប់ហ្នឹង គេសំរេចថាកាត់តែមេដឹកនាំ ជាន់ខ្ពស់ដែល ទទួលខុសត្រូវខ្ពស់បំផុត ហើយនិងជនទាំង ឡាយណាដែលប្រព្រឹត្តបទល្មើស ដូចថាសាហាវឃោឃៅអមនុស្សធម៌អីអញ្ចឹងអាំណា ហើយនៅក្នុងច្បាប់មាត្រាមួយនៅក្នុងច្បាប់នេះហ្នឹងគេនិយាយអញ្ចឹង អញ្ចឹងហើយបាន គេចរចាគ្នា ហ្នឹង

រ៉ាឌី: ហើយខ្ញុំគិតថាការកាត់ទោសវាចេះតែពន្យា ពន្យា ដោះស្រាយមិនទាន់ចេញរួច អ្នកអស់ ហ្នឹង ចាស់ៗបន្តិចអស់ហើយ យូរបំផុតបើសិនជាមិនត្រូវ បើគិតពី១០ឆ្នាំទៀត ដូចជា មិនបាច់កាត់ទោសអីទេ បើវាចប់អស់ហើយ អ្នកទាំងអស់គ្នា វាគ្មានអីហួសពីទោស ទេ ជាប់គុកមួយជីវិត ហើយមួយជីវិតអី បើទាំងអស់សុទ្ធតែ ៧០ ហើយ៨០ហើយ ហើយ

ប៉ុន្មាន ដូចមិនដល់១០ផង តែមិនស្រួលគ្រាន់តែកាត់ទោស អ្នកទោសស្លាប់អស់ទៅ អា អ្នកនេះ ស្លាប់បាត់ហើយ ហើយអាហ្នឹងគឺ ជា

ភារិទ្ធៈ អត់អ្នកស្លាប់គេអត់កាត់ទោសទេ កាត់ធ្វើអី បើស្លាប់ហើយ អោយទោសយ៉ាងម៉េចទៀត បើស្លាប់អស់ហើយ

រ៉ាឌីៈ អើ ដូចជាយូរពេកអេ ដូចតាម៉ុកអី ធ្លាប់លឺថា គ្រាន់ ឈឺក្បាល ផ្ដាយសាយអី ទូតគេ ខំភ័យខ្លាច ខំមកមើលទាំងយប់អាធ្រាត្រអី អីក៏ចាប់អារម្មណ៍អ្នកទាំងអស់ហ្នឹងម៉េះ ហើយ ខ្ញុំគិតថា អ្នកទាំងអស់ហ្នឹង សំណាង សំណាងជាងខ្ញុំជាអ្នករងគ្រោះទៅទៀត ខ្ញុំឈឺស្អាត់ យប់ព្រលប់ គ្មាននរណាមកមើលខ្ញុំទេ ហើយចុះក៏គេអីក៏ភ័យខ្លាចម៉េះ ហើយតាម៉ុកហ្នឹង ដេកស្រួល ហើយ លំបាកទេ ខ្ញុំជឿថាឆ្ងាញ់ហើយ ដេកស្រួលទៀត ឈឺល្មមៗគេផ្ដើល នាំគ្នាមកមើលអាដែង ឈូរឆ គ្រប់គ្នា ហើយយើងអ្នករងគ្រោះ នៅតែ

ភារិទ្ធៈ អើ លំបាក ឈឺស្អាត់អីគ្មាននរណាយកចិត្តទុកដាក់ទេ

រ៉ាឌីៈ អឺ ព្រហ្មលិខិតរបស់គេដែលបង្កើតមក វាសំណាងរបស់គេ វាត្រូវតែអញ្ចឹងរហូតអញ្ចឹង ទៅ

ភារិទ្ធៈ មាន អើ ខ្ញុំ ធ្លាប់លឺគេនិយាយ ពីរឿងដូចថា ទាក់ទងនឹងការកាត់ទោសហ្នឹងអា៎ គេថា អើ កាត់ទោសអី បើអ្នកហ្នឹង គេខ្លាចទៅ ថា អ្នកហ្នឹងស្លាប់ទៅ អត់បានការកាត់ទោស ហើយចុះគេមិនខ្លាចផងដែលជនរងគ្រោះដែលចាស់ទៅ ស្លាប់ ហើយអត់បានឃើញ ការ កាត់ទោសនោះ គេមិនខ្លាចអាហ្នឹងផង រឿងអីខ្លាចតែអ្នកស្លាប់ហើយមិនបានកាត់ទោស ហើយប្រជាជនរងគ្រោះចាស់ៗ ដែលគាត់ ចាស់ៗហើយ គាត់ចង់ ឃើញថា ដែលគាត់ មានប្តីមានកូនស្លាប់ច្រើន ហើយគាត់ចង់ឃើញថា អាតុលាការហ្នឹង គេកាត់ម៉េចមុននឹង គាត់ស្លាប់ អោយគាត់អស់ចិត្ត មិនភ័យផង មាននិយាយអញ្ចឹងដែរ ដូចបងនិយាយ អំបាញ់មិញអញ្ចឹងៗ ហើយចុះបង បើសិនជាតុលាការ ដែលខ្ញុំនិយាយអំបាញ់មិញ ហ្នឹង តុលាការដែលអន្តរការសហប្រជាជាតិហើយនិងរដ្ឋាភិបាលហ្នឹង កើតមានឡើង បង យល់ថា តុលាការហ្នឹង អាចធ្វើអោយ អើ អារម្មណ៍បង ថាមានយុត្តិធម៌សំរាប់បង រឺ ក៏សំរាប់ជនរងគ្រោះ អើខ្មែរទូទៅទេ?

រ៉ាឌីៈ ខ្ញុំគិតថាបើសិនជាមានការកាត់ទោស ខ្មែរក្រហម គឺ អារម្មណ៍របស់ខ្ញុំ ក៏មានគិតថា ក៏

មានថា ចំពោះរូបខ្ញុំ គឺ វាផ្តល់យុត្តិធម៌ខ្វះហើយ គឺខ្ញុំផ្តោតទៅលើប្រជាជនខ្មែរទាំងមូល ជៀសវាងថាមានបងប្អូន ឪពុកម្តាយស្លាប់ដូចជារូបខ្ញុំហ្នឹង អោយបានទទួលភាពយុត្តិធម៌ខ្វះ ភាពយុត្តិធម៌ខ្វះ កុំអោយវា ថាវា ដូចទទេ ៗអាំ ទៅជាពាក្យ ដូចខ្ញុំជំរាបពីម្សិលអញ្ចឹង គ្រោះមហន្តរាយអីអាំ គឺវា ធ្វើទៅ

ភារិទ្ធៈ វាអត់ចេះ

រ៉ាឌីៈ ធ្វើទៅកើតបានបន្តិចហើយបាត់ទៅវិញ មហន្តរាយ យើងជួបនៅក្នុងរបប គ្រោះមហន្តរាយ

ភារិទ្ធៈ មើលទៅបងរហូតមកដល់អញ្ចឹង លឺពត៌មានអញ្ចឹង ហើយតុលាការវិញមិនទាន់ជាចេញជារូបរាងអីច្បាស់លាស់អញ្ចឹង បងយល់ថាតុលាការហ្នឹង អាចកើតមានទេ?

រ៉ាឌីៈ អាចកើត ហើយនៅមិនកើតធ្វើដល់តែបាន តុលាការហ្នឹង ព្រោះជឿជាក់ទៅលើអ្នកដឹកនាំរបស់រដ្ឋាភិបាលយើង

ភារិទ្ធៈ ហើយចុះបើសិនជាគ្មានតុលាការហើយថៃដន្យអីតុលាការហ្នឹងមិនអាចកើតមាន តើបងយល់ឃើញយ៉ាំងម៉េចថា តុលាការហ្នឹងគួរតែធ្វើយ៉ាំងម៉េចចំពោះមេដឹកនាំហ្នឹង ដូចដឹកនាំសំលាប់មនុស្សអីអញ្ចឹង?

រ៉ាឌីៈ ដូច ចំពោះដល់កន្លែងនេះ ខ្ញុំដូចជាហួសសមត្ថភាពនឹងគិត បាទ គឺ ថ្នាក់ដឹកនាំធំៗ គិតហើយពីបញ្ហានេះ ខ្ញុំចង់បានបើធ្វើអញ្ចេះ ធ្វើអញ្ចេះ ក៏ខ្ញុំយើងមិនអាច ហើយបើបណ្តោយមកថាឥលូវអ្នកឯងអោយសួរខ្ញុំថា ឥលូវអ្នកឯងសំរេចអោយយ៉ាំងម៉េច ថាអេ ត្រូវតែដាក់ឡានដឹកហើយ ប្រាប់អោយប្រជាជនកាត់ទោស អាហ្នឹងអោយក្មេងចោលដុំថ្មងាប់ទៅលើឡាន អាហ្នឹងចិត្តវាខឹង អាំ ចិត្តមនុស្ស វា គិតថា ចិត្តមនុស្សអីអញ្ចឹង អាំ អំពើនេះ មិនត្រូវយកចិត្តមនុស្សត្រូវនិយាយជាមួយវាទេ  អ្នកខាងខ្មែរក្រហម ព្រោះអ្នកទាំងអស់ហ្នឹង អត់ដែលបានគិតពីសិទ្ធអ្នកដទៃរាប់លាននាក់នោះទេ គិតតែពីសិទ្ធរបស់ខ្លួនឯង ហើយដល់តែពេលឥលូវ មនុស្សរាប់លាននាក់ អោយគិតសិទ្ធខ្លួនឯងទៀត

ភារិទ្ធៈ បាទ

រ៉ាឌីៈ ហើយចុះថា អ្នកហ្នឹងអីក៏មានអទិភាពម៉េះ វាសំណាងរបស់គេ ហើយចុះដូចអៀង សារី

អីវ៉ាន់ ខៀវ សំផនអី មិនមែនគាត់នៅអត់ឃ្លាន មានហូបដូចខ្ញុំ អីវ៉ាន់ទេ គេនៅដេក ស្រួល ស៊ីឆ្អាញ់ ឈឺតែផ្តាសសាយ ក៏ឈឺក្បាល ធ្លាយថៃ ធ្លាយបាងកក ធ្លាយបរទេស បាត់ហើយ ទៅមើលជំងឺ

ភារិទ្ធៈ បាទ

រ៉ាឌីៈ លទ្ធភាពគេគ្រប់គ្រាន់ អញ្ចឹងគេនៅតែសំណាងជាងគេរហូត អាហ្នឹងនិស្ស័យបុណ្យគេ នោះ គិតទៅ ថាមេបុណ្យគេអញ្ចឹង

ភារិទ្ធៈ ហើយចុះសំរាប់បង ពាក្យថាយុត្តិធម៌បងយល់ឃើញថាយ៉ាងម៉េចដែរ?

រ៉ាឌីៈ យុត្តិធម៌ខ្ញុំយល់ថា អ៊ីទង្វើដែលគេធ្វើហើយ ត្រូវទទួលផលបានទៅវិញ បើទៅមើលថា វាអាក្រក់ ទៅធ្វើទង្វើរបស់ខ្លួនអាក្រក់ គឺយើងទទួលផលអាក្រក់ហ្នឹងបានមកវិញហើយ បើយើងធ្វើល្អយើងទទួលបានល្អមកវិញ បំពានទៅលើគេអញ្ចឹង ដូចគេគ្មានកំហុសឆ្គង អញ្ចឹង គេនឹងបំពានមកលើយើងវិញដោយ ទង្វើទៅលើគេវិញ

ភារិទ្ធៈ ហើយចុះ ការដែលនាំយកមេដឹកនាំខ្មែរក្រហមមកកាត់ទោសហ្នឹង បងយល់ថាជាការ សងសឹក រឺក៏ជាកម្ម ចងកម្មចងពៀរអីដែររឺអត់?

រ៉ាឌីៈ ខ្ញុំគិតថាមិនមែនជាការសងសឹកទេ សំខាន់ បំផុតដែលគេយកមេដឹកនាំខ្មែរក្រហមមកដឹក នាំនេះ វាជា ប្រវត្តិមួយដ៏ល្អសំរាប់ប្រជាជនខ្មែរអា ចង់អោយខ្មែរ ក៏មានពូជសាសន៍ មាន ច្បាប់មានទំលាប់ អីអោយត្រឹមត្រូវ ជៀសវាង អាដែងថាសញ្ញាតិមួយដែរ គឺ ថាត្រូវតែមាន បើអ្នកឯងធ្វើអាក្រក់ គឺត្រូវតែទទួលទោស គឺមានច្បាប់ទំលាប់គិតថា អញ្ចឹងដែរ ត្រូវតែទទួលទោស មិនមែនជាការសងសឹក បើការសងសឹក អ្នកទាំងអស់នោះ ប្រហែលមិនមែនជាអ្នកបាតដៃប្រឡាក់ឈាមទេ មិនមែនជាអ្នកដៃដល់ទេ ព្រោះអ្នកដែល ដៃ ដល់អ្នកកាប់សម្លាប់ ប្រជាជនហ្នឹង គឺអ្នកក្រទាំងអស់ អាហ្នឹងមិនបានសម្លាប់ទេ គឺខ្ញុំជឿថា មិនបានសម្លាប់ទេ មិនបានសម្លាប់ផ្ទាល់ដៃទេ

ភារិទ្ធៈ ហើយចុះអាការដែលកាត់ទោស មេដឹកនាំខ្មែរក្រហម នាំ មេខ្មែរក្រហមទៅកាត់ទោស អញ្ចឹងវាអាចធ្វើអោយ ប្រទេសជាតិយើងមានការប៉ះពាល់នឹង ការបែកបាក់ នឹងការ ផ្សះផ្សារជាតិទេ?

រ៉ាឌីៈ ខ្ញុំគិតចំណុចនេះ បើទស្សនៈរបស់ខ្ញុំ បើសិនជាការកាត់ទោសខ្មែរក្រហមហើយសភាព

ការណ៍ សុខសប្បាយធម្មតា សំរាប់តែប៉ុន្មាននាក់ តែពួកលើធំៗគួរធ្វើ ប៉ុន្តែបើសិនជាកាត់ទោសហើយមានរឿងរ៉ាវ សង្គ្រាមអីកើតមាន គួរតែរកវិធីណាដោះស្រាយយ៉ាងម៉េច កុំអោយវាមានបញ្ហាហ្នឹងកើតឡើង នៅលើប្រទេសជាតិ ព្រោះថាអាសូរ អាណិតកូនក្មេងយើងក្រោយនេះ មិនចង់អោយជួបសង្គ្រាមទេ លោកអើយ មិនចង់ទេ អ៊ីដែលខ្ញុំឆ្លងកាត់សង្គ្រាមប៉ុន្មានជំនាន់មកនេះ វារស់ដល់ថ្ងៃនេះ វាគ្រប់គ្រាន់ទៅហើយ ថា មិនចង់អោយកូនចៅ ហើយកូនខ្មែរយើងជួបប្រទះអញ្ចឹងតទៅទៀត ហើយគួរអោយខ្មាសជនជាតិគេ យើង មិនចង់អោយខ្មាស យើងជាសញ្ជាតិមួយដែរ មិនចង់អោយខ្មាសគេ គេនាំគ្នា រកស៊ីមានបាន រកស៊ីតែកសាងអភិវឌ្ឍន៍ប្រទេស យើងនាំគ្នាតែចំបាំងគ្នាក៏មិនល្អមើលដែរ

ភារិទ្ធៈ ហើយចុះបងយល់យ៉ាងម៉េចដែរចំពោះការផ្សះផ្សារជាមួយអតីតខ្មែរក្រហមដែលធ្លាប់ធ្វើទុក្ខបុកម្នេញ ដឹកនាំអោយមានការសម្លាប់អីអញ្ចឹង?

រ៉ាឌី: ការផ្សះផ្សារអញ្ចឹង

ភារិទ្ធៈ ខ្ញុំចង់សួរថាបើយើងផ្សះផ្សារជាមួយខ្មែរក្រហមវិញអា៎ ដូចថានាំអ្នកអតីតខ្មែរក្រហមដែលរស់នៅក្នុងស្រុក នៅក្នុងភូមិ ដែលពីមុនមកអ្នកហ្នឹងធ្វើទុក្ខធ្វើទោសយើងអញ្ចឹង បងមានអារម្មណ៍ថាយ៉ាងម៉េចដែរ?

រ៉ាឌីៈ ខ្ញុំចំពោះអ្នកដែលនៅតូចទាប មានអ្នកខ្លះដែលជាអ្នកដឹកនាំនៅក្នុងមូលដ្ឋានអញ្ចឹង រស់នៅសព្វថ្ងៃហ្នឹងអញ្ចឹង ខ្ញុំដូចជាមិនមានទស្សនៈអី ព្រោះខ្ញុំយល់ឃើញថា គាត់ធ្វើ គឺធ្វើតាមគេ ដើម្បីសុខរបស់គាត់ដែរ ប៉ុន្តែអ្នកខ្លះក៏វាឃោរឃៅហួស ពេកដែរអញ្ចឹង ហើយខ្ញុំមានទស្សនៈមួយថា អ្នកដែលគ្នាធ្វើនេះ មកពីគ្នាអវិជ្ជា អវិជ្ជាហើយ ទស្សនៈរបស់ខ្លួនគំនិតរបស់ខ្លួនមិនទូលំទូលាយទេ ហើយនៅក្នុងការដឹកនាំហ្នឹង ខ្ញុំជឿថានៅក្នុងរបបខ្មែរក្រហមមិនមែនជាឃោរឃៅទាំងអស់គ្នាទេ មានមេកងខ្លះ ក៏គេចិត្តធម៌ដែរ កូនក្រុម កូនកងរបស់គេមិនអោយបាត់មួយ ក៏មានដែរ ប៉ុន្តែអ្នកខ្លះបាត់ ពន្យល់ហើយ នេះកំហុស កងទ័ពទាំងអស់គ្នា អញ្ចឹង បានថាមនុស្សយើងមិនមាន៨ជ្រុងទាំងអស់ទេ អាខ្លះវាមាន៦ មាន៥ អីអញ្ចឹងទៅ វាមិនជាទូទៅអា៎

ភារិទ្ធៈ ហើយចុះបងយល់ថាសាសនាអាចមានតួនាទីជួយអោយស្រុក ទេសយើងថ្ងៃក្រោយមាន

ការផ្សះផ្សារទេ?

រ៉ាឌី: ខ្ញុំយល់ សាសនាក៏ជា ចំនែកមួយរួមអោយយើងទាំងអស់គ្នា រួមគំនិត រួម សុខរួមទុក មិនអាចអោយមានថា ដូចថាការកាត់សម្លាប់គ្នាហ្នឹងដែរ

ភារិទ្ធ: ជួយបានម៉េចខ្លះ?

រ៉ាឌី: សាសនាបើនិយាយពីទ្រឹស្តី ខ្ញុំគិតថាខ្ញុំមិនមែនជាអ្នកបួសរៀនចេះដឹងអីពីពុទ្ធចក្រហ្នឹងទេ ប៉ុន្តែគ្រាន់តែខ្ញុំឃើញថា ចំណុចខ្លះ ឃើញថាសាសនា អោយមនុស្សចេះសាមគ្គី

ភារិទ្ធ: បាទ

រ៉ាឌី: ចេះអោយមនុស្សជួយគ្នា ចេះអោយមនុស្សអត់អោនគ្នា ចេះអោយមនុស្សអធ្យាស្រ័យគ្នា អញ្ចឹងវាហាក់ដូចជាពុទ្ធចក្រ អើ ដូចយើងខំបង្រៀននៅសាលាអីយើងអញ្ចឹងដែរថា គេមិនដែលបង្រៀនក្មេង ថា អេ បើអានេះខុស មិនបាច់ប្រាប់វា ត្រូវវាយវា ត្រូវគក់វា ត្រូវកៀបសង្កត់វា ត្រូវថាអោយវាអញ្ចឹង មិនមានថា នេះ ជួយអប់រំ បំភ្លឺផ្លូវគ្នា ខ្ញុំគិតថា ទិសដៅសាសនា ក៏ត្រូវរួមចំណែកមួយ នៅក្នុងបញ្ហា ជួយអប់រំ ហើយនិងជួយ ហើយប្រមូលកំលាំង ហើយយើងចង់អភិវឌ្ឍន៍អីមួយ ចង់ធ្វើអីមួយ អាចតាមរយៈសាសនាក៏ថាបាន បាទ ដូចថាឥលូវផ្លូវលំមួយអញ្ចឹង មេឃុំៗគាត់គិតអត់បានដល់ លោកជដែកអីហ្នឹង ចេះតែនាំគ្នាធ្វើ ធ្វើ បាន ធ្វើកើត ហើយក៏រួមចំណែកមួយអោយមនុស្សចេះសាមគ្គីគ្នាដែរ ហើយមនុស្សបើកាលណាជួបគ្នាជាញឹក ជាញាប់ហើយទៅ ក៏ចេះតែមានភាពសិទ្ធស្នាលគ្នា អាចជួយគ្នាបាន

ភារិទ្ធ: ហើយចុះបងឧបមាថាថ្ងៃក្រោយទៅ បងដឹងថាអ្នកដែលសម្លាប់ឪពុកបងនៅរស់នៅអីបង?

រ៉ាឌី: ខ្ញុំដូចជាមិនមានគំនិតសងសឹកអីទេ ខ្ញុំគ្រាន់តែថា បើសិនជាខ្ញុំដឹងច្បាស់ ខ្ញុំគ្រាន់តែសួរថា តើអ្នកឯងធ្វើនោះ តើគំនិតរបស់ខ្លួនយល់ថាម៉េច ហើយខ្ញុំជឿថា គេថា គេនឹងជឿថា ការក្បត់បញ្ជារអង្គការអស់ហើយ បើខ្ញុំមិនធ្វើក៏គេសម្លាប់ខ្ញុំដែរ ខ្ញុំជឿថាគេឆ្លើយភាសាហ្នឹងហើយ ប៉ុនតែខ្ញុំគិតថាមិនបានដេញដល់ក៏វា ក៏វាល្អម្យ៉ាងដែរ មិនចង់អោយរំលឹកអារឿងចាស់ហ្នឹងផង ជាការសងសឹកអីគ្មានទេ

ភារិទ្ធ: ហើយចុះបងយល់ថាយ៉ាងម៉េចដែរ ចំពោះការដែលខាងខ្ញុំចុះ មកសួរនាំអាពីអារឿងរ៉ាវ

អតីតកាលហើយនិងអារម្មណ៍ផ្លូវចិត្តរបស់បងហ្នឹង

ភ៉ាឌី: ខ្ញុំមានអារម្មណ៍ថា វាជាការមួយល្អដែរ ពិសេសគឺបញ្ហាមួយដែលរំលឹកដែលបញ្ចូលពីកម្មវិធីសិក្សានៅក្នុងសាលា នៅក្នុងក្រសួងអប់រំ តាំងពី របបប៉ុល ពតហ្នឹងអាំ ខ្ញុំគិតថាកន្លែងហ្នឹង ល្អណាស់ ល្អមែនទែនតែម្តង គួរលើកពីប្រវត្តិខ្លះ ខ្ញុំឃើញរៀនប្រវត្តិសាស្ត្រប្រវត្តិវិជ្ជាខ្លះនៅសាលារាល់ថ្ងៃ ពីប្រទេសនេះវាអញ្ចេះវាអញ្ចុះ ចេះនាំគ្នាបញ្ចូលកម្មវិធីបាន ហើយចុះអាពីប្រទេសខ្លួនឯង ហាក់ដូចជាមិនទាន់អោយឃើញមាន អោយវាស៊ីជំរៅនៅឡើយ

ភារិទ្ធ: បាទ

ភ៉ាឌី: អាប្រវត្តិសាស្ត្រ បើនិយាយពីប្រវត្តិសាស្ត្រនិយាយពី ស្តេចនេះ ស្តេចនោះ ដល់តែពេលចុះមករាស្ត្រនេះ ស្រាប់តែមកលេងឃើញនិយាយ កសាងអង្គរយ៉ាងម៉េច អាដែងអើកសាងកន្លែង ប៉ាំងអាម៉េច ដណ្តើមដីអាម៉េច ដណ្តើមអីយ៉ាងម៉េចទៅជាមាន អាកន្លែងនេះដែលថាវានេះ មិនទាន់ឃើញ បើសិនជាហ្នឹង អាចនឹងចូលបានបើសិនជាទស្សនៈរបស់ខ្ញុំ គួរថា មានការសិក្សា រឺមួយក៏គេខ្លាចនៅពេលមានកម្មវិធី ចូលឡើង រំលឹកអាចាស់ឡើង មានកំហឹងមានការកាប់សម្លាប់សងសឹកគ្នាទៅវិញទៅ មកទៀត ក៏អាច ថាបាន

ភារិទ្ធ: បាទ

ភ៉ាឌី: ក្រែងលំ គេយល់អញ្ចឹង បើតាមទស្សនៈយល់អាំ បើគេមិនព្រម ដាក់បញ្ចូលព្រោះថាបើសិនជាមកគិតដល់ថ្ងៃនេះ បើសិនជាអាការសងសឹកការគុំគួនហ្នឹង ដូចជា

ភារិទ្ធ: លែងមាន

ភ៉ាឌី: លះបង់ ដូចជាលះបង់ ដូចជាលែងមានដែរហើយតាមមើល ហើយអ្នកដែល ប្រព្រឹត្តអំពើកាលណោះ ក៏កាន់តែចាស់ទារុណទាវអស់ ហើយ ឥលូវ ក៏ទៅ អ្នកខ្លះក៏ស្លាប់ទៅអស់ហើយ ទៅតាមដំណើរអញ្ចឹងទៅ វាគួរតែអាសូរដល់ក្មេងៗក្រោយ ចង់អោយវាដឹងអាំប្រវត្តិហ្នឹង ខ្លះ

ភារិទ្ធ: ហើយចុះអារឿងរ៉ាវអតីតកាលដែលបងធ្លាប់ជួបប្រទះហ្នឹង រំខាននៅក្នុងអារម្មណ៍បងរៀងរាល់ថ្ងៃ ញឹកញាប់ ដែររឺអត់ទេ ?

រ៉ាឌី:	ខ្ញុំមានការនឹកឃើញជាញឹកញាប់ ដែរ ពីបញ្ហាហ្នឹង

ភារិទ្ធ:	ហើយចុះដល់ពេលដែលបងមានអារម្មណ៍តឹងតែងនៅពេលដែលនឹកឃើញអញ្ចឹង បងធ្លាប់ដោះស្រាយយ៉ាងម៉េចដែរ ដើម្បី អោយអារម្មណ៍បានធូរស្បើយ

រ៉ាឌី:	ភាគច្រើន ខ្ញុំច្រើនតែផ្តោតអារម្មណ៍មួយរឿងផ្សេងទៅទៀត ទៅធ្វើអីផ្សេងដែរនាំអោយអោយការសប្បាយៗ កុំគិត អោយបំភ្លេចអានេះ ខ្ញុំមានទស្សនៈ មួយ ដូចថាមិនសូវ បណ្តែបណ្តោយអារម្មណ៍អោយទៅអន្លង់អន្ទោច រឺក៏រឿងដែលវាស្មុគស្មាញខ្លាំងដែរដែលរឿងច្រើនពេកទេ ព្រោះបើថាកាលណាដែលជ្រៅពេកទៅ ខ្ញុំខ្លាចថាខួរក្បាលខ្ញុំមានប្រតិកម្មអីមួយផ្សេងទៅ ព្រោះខ្ញុំឆ្លងកាត់អាល្បិច អាការផរហ្នឹង វាច្រើន ពេកទៅអាសភាពការណ៍អស់ហ្នឹង ខ្ញុំមិនចង់អោយ វាជ្រៅអាអ៊ីដែលលំបាកហ្នឹង ក៏មានអារម្មណ៍ច្រើននៅក្នុងខួរក្បាល

ភារិទ្ធ:	អើ ខ្ញុំចង់ដឹង ថាមនុស្សយើង បើសិនជា មានបញ្ហាតានតឹងនៅក្នុងចិត្ត រឺក៏មាន បញ្ហាផ្លូវចិត្តអាំ ហើយបងយល់ថា សាសនាអាចជួយអ្នកហ្នឹងអោយមានអារម្មណ៍ធូរស្បើយ រឺក៏ ជួយព្យាបាលបញ្ហាហ្នឹងបាន

រ៉ាឌី:	មាន សាសនា មានអារម្មណ៍ជួយព្យាបាលបញ្ហាច្រើន ខ្ញុំជឿថាមានច្រើន ជួយបានយ៉ាងម៉េច ត្រង់ថា បើពេលមានអារម្មណ៍តានតឹងគិតអីមួយមិនចេញធ្វើអីមួយមិនកើត មើលទៅគេហ្នឹង វាដូចជា មិនជួបការលំបាកដូចយើង មិនជួបស្មុគស្មាញដូចយើងទេ មានតែយើងជឿទៅលើព្រះពុទ្ធព្រះធម៌ព្រះសង្ឃ ទៅលើសាសនាហ្នឹងឯង ដូចថាជានិស្ស័យរបស់យើង ព្រហ្មលិខិត កំណត់មកថា ដល់តែជីវិត ហ្នឹង ម៉ោងហ្នឹង ខែហ្នឹងថ្ងៃហ្នឹង គឺត្រូវតែជួបនៅកន្លែងហ្នឹង

ភារិទ្ធ:	បាទ

រ៉ាឌី:	ខ្ញុំដូចថា ខ្ញុំចេះតែផ្តេកខ្លួនទៅលើសាសនា ហើយដូចថា វា វានិស្ស័យរបស់យើងបានត្រឹមប៉ុណ្ណឹង សម្តាយយើងបានត្រឹមប៉ុណ្ណឹង រឿងរ៉ាវហ្នឹង វាត្រូវជួបពេលហ្នឹង ម៉ោងហ្នឹង ហើយបើសិនជាយើងធុញថប់អី ស្តាយណាស់ គឺ ថាមួយវិនាទី សោះ គួរអោយថ្វោះថ្នោយ យើងនៅតែគិតពីរឿងហ្នឹង យើងមាន នៅតែមានអារម្មណ៍តានតឹង ចំពោះអ៊ីដែលថា យើងគិតហ្នឹង គឺវាកន្លងផុតទៅហើយ ដល់តែកន្លងផុតទៅហើយ គឺយើង នៅ

តែគិត ក៏វាមិនអាចវិល ថយក្រោយវិញបានដែរ អញ្ចឹងបានផ្ដែកទៅលើសាសនា

ភារិទ្ធៈ ហើយចុះបងផ្ទាល់មានដែលដូចជាស្ដាប់ លោកទេសនា រឺលោកសូត្រធម៌សូត្រអីទៅ មាន អារម្មណ៍ ធូរដែរ?

ភ៉ីឌីៈ ធូរ ធូរ ប៉ុនតែវាមានកន្លែងធូរខ្លះដូចថា សាសនា លោកទេសនា ដូចថាយើងត្រូវផ្ដោត អារម្មណ៍ទៅលើការអប់រំច្រើនដែរ រឿងរ៉ាវខ្លះដែលលើកនៅក្នុង លោកទេសនានេះ ក៏ រឿងរ៉ាវ សំរាប់អោយមនុស្សចេះវិភាគចេះពិចារណាទៅ ថ្លឹងថ្លែង

ភារិទ្ធៈ អើ និយាយអញ្ចឹង បងមានដែលធ្លាប់និយាយ រឿងរ៉ាវ ប្រាប់ ពីរឿងអតីតកាលហ្នឹង ប្រាប់ ក្មេង ប្រាប់កូនចៅបងអោយបានដឹងលឺទេ?

ភ៉ីឌីៈ ខ្ញុំគិតថា រឿងទាំងអស់នោះ ខ្ញុំខស្សាហ៍និយាយច្រើនដែរ ប៉ុន្តែ បើសិនជាបញ្ហាកូនខ្ញុំតែ ម្ដង ដើម្បីអោយវាមានបទពិសោធន៍ខ្លះ មានអនុសាស្ត្រខ្លះ សំរាប់វាមានការកែច្នៃជីវិត របស់វា អញ្ចឹងបានខ្ញុំដំរាបពីប្រវត្តិអញ្ចឹង វាអត់ជឿ អត់ជឿទេ ហើយថា បើសិនជា នៅសាលាគេមិនបានទទួលកម្មវិធីនេះ ក្មេងទាំងអស់នេះ ត្រឹមតែឪពុកម្នាក់ ម្ដាយម្នាក់ និយាយថា បើសិន ជាវា គ្មានចាប់ផ្ដោត ចាប់អារម្មណ៍ កត់នៅក្នុងខួរក្បាលវា បន្តិច ទេ គ្មានទេ បើអ្វីដែលយើងនិយាយទៅដល់សាលា វារៀននោះទៅ ឃើញអញ្ចឹង មែន ដូចអ្វីដែលយើងនិយាយ ខ្ញុំជឿថាវាចាប់ផ្ដើមមានជំនឿ ចាប់ផ្ដើមជឿហើយ ហើយបើ សិនជា ខ្ញុំម្នាក់ រឺក៏ឪពុកម្ដាយម្នាក់នៅក្នុងសង្គមគ្រួសារមិនបានសង្គមជាតិជួយទៀតហ្នឹង គឺ

ភារិទ្ធៈ មិនអាច

ភ៉ីឌីៈ មិនអាចហ្មង វាទៅជារឿងមួយចេះតែត្អូញត្អែ បង្អែក ត្អូញ ពិបាកអញ្ចោះ ពិបាក អញ្ចុះ ថាអញ្ចោះ ថាអញ្ចុះ រឿងវា មិនពិតអីណា  វាអាចមកលើយើង ទំលាក់កំហុស មកលើយើងវិញ

ភារិទ្ធៈ ហើយចុងក្រោយខ្ញុំចង់សួរសំនួរ បង តើបងយល់យ៉ាងម៉េចដែរ នៅ ពេលដែលអើ ដើម្បីអោយប្រទេសយើង ថ្ងៃក្រោយមានយុត្តិធម៌មានការផ្សះផ្សារ ហើយមានសន្តិ ភាព អីពិតប្រាកដនៅក្នុង អាគំនិតបង បងយល់ទេ មានគំនិតយល់ថាម៉េចដែរ?

ភ៉ីឌីៈ ខ្ញុំឃើញថាការរៀបចំរបស់រាជរដ្ឋាភិបាល សព្វថ្ងៃនេះ ប្រហែលជាទស្សនៈរបស់ខ្ញុំទេ គឺ

ថាគាត់ធ្វើហ្នឹង ធ្វើដើម្បីការស្រុះស្រួល និងការសម្របសម្រួលទៅវិញទៅមកដែរ យើងឃើញថា បើនិយាយពី ជួរថ្នាក់ដឹកនាំខ្ពស់ៗនៅក្នុងរាជរដ្ឋាភិបាលហ្នឹង វាជាង៣០០នាក់ជាង ជាឯកត្តកម្មលេខមួយលើពិភពលោក បើយើងប្រៀបធៀបជាមួយនឹងប្រជាជន

ភារិទ្ធ: បាទ

រ៉ាឌី: នៅប្រទេសបារាំងអីគេមិនដែលដល់អញ្ចឹងពេកទេ ហើយខ្ញុំជឿថាធ្វើនេះ អ្នកខ្លះក៏យល់ថាដណ្តើមអំណាច ចង់បានអំណាច ចែករំលែកអំណាចគ្នា ខ្ញុំគិតថា អ្នកយល់អញ្ចឹងក៏ថាត្រូវម្យ៉ាងដែរ ហើយក៏ខ្ញុំយល់ឃើញម្យ៉ាងទៀតថា ធ្វើនេះដើម្បី ជៀសវាងកុំអោយមាន សង្គ្រាមរឺក៏មានទំនាស់កើតឡើង បាទ បើវាមើលមកយើង ថារួមគ្នាធ្វើ គឺមាន តិចមានច្រើន ថាមានច្រើននាំគ្នាហូបច្រើនអញ្ចឹងទៅ ប៉ុន្តែអោយបានសុខ ទាំងអស់គ្នាទៅដើម្បីសុខ កុំអោយវាមានអាការវិវាទគ្នាហ្នឹង ខ្ញុំគិតថា ប្រហែលជាយល់អញ្ចឹង ក៏ម្យ៉ាងវាដែរ អញ្ចឹងគំនិតរបស់ខ្ញុំគឺថាមិនចង់ អោយមានអ៊ីដែលថាសង្គ្រាមអ៊ីដែលបាក់បែកគ្នាឡើងវិញទេ ថ្មីត្បិតតែយើងត្រូវគ្នា យើងប្រទេសយើងក្រមែនតែយើងត្រូវគ្នា ក៏វាគ្រាន់បើជាងយើងប្រទេសក្រ យើងមិនត្រូវគ្នាទៀត នៅក្នុងគ្រួសារមួយ បើវាបែកបាក់គ្នា អ្នកដទៃ គេគ្មានបានផលអីពីយើងហ្នឹងទេ ក៏គេចាប់ផ្តើមប្រមាទមើលងាយយើងដែរតាមរយៈអីមួយដែរ ហើយបើយើងត្រូវគ្នា យើងក្រ យើងត្រូវគ្នា យើងស្រឡាញ់គ្នាគេក៏មិនហ៊ាន បើយើងមិនត្រូវគ្នា នៅក្នុងគ្រួសាររបស់យើង បើយើងប្រពន្ធយើងទៅជួបអ្នកដទៃ ហើយអ្នកដទៃគេនិយាយអញ្ចោះ ហើយប្តីជួបអ្នកដទៃ អ្នកដទៃនិយាយអញ្ចោះ និយាយដើមយើងទៅមក ហើយប្រពន្ធយើងនិយាយអញ្ចោះ អានោះលឺទៅមកនិយាយប្រាប់យើងអញ្ចោះៗ លឺមិនអស់មិនហើយទេ បើសិនជាយើងត្រូវគ្នាអាំគេអត់ហ៊ានទេ គេអត់ហ៊ាននិយាយពីក្រុមគ្រួសារយើងទេ

ភារិទ្ធ: អូ

រ៉ាឌី: ទោះបីយើងក្រ ក៏គេថា អូឯងក្រ អាំ កុំមកផ្ទះអញ ក៏គេអត់ហ៊ានថាដែរ បើថាវាមិនត្រូវគ្នាទៅ ប្តីឯងម៉េចហើយ ប្រពន្ធឯងម៉េចហើយ វាអត់មានចាប់ផ្តើម វាចាប់ផ្តើមសួរយើងមុនគេ បើជួបមុខយើងគេសួរពីបញ្ហាហ្នឹង មុនគេហើយ

ភារិទ្ធ: បាទ

រ៉ាឌី៖ ខ្ញុំថាអញ្ចឹង បើសិន ជាយើងសាមគ្គីហើយ ហើយធ្វើរបៀបនេះ ធ្វើឯកត្តកម្មគ្នាលេខមួយនៅលើពិភពលោក ខ្ញុំថា ឯកត្តចុះ ដើម្បីបាន ថា សុខ ហើយយើង ថា បានស្ងប់ បាត់ៗយូរៗទៅហ្នឹង វាគង់តែគេរៀបចំ អា ជាបណ្តើរៗតទៅទៀតទេ ហើយនិយាយពីការរីកចំរើនមកដល់សព្វថ្ងៃ ខ្ញុំឃើញសរសើរច្រើនណាស់ហើយ សរសើរថាមានភាពរីកចំរើនជាងកាល បើប្រៀបជាមួយប៉ុល ពត គឺខុសគ្នាស្រឡះហើយ ហើយការងើបពីប៉ុល ពត រឺក៏អ្នកមកពីបរទេស ប្រហែលជាល៉ក់គាត់ដឹងថា ប៉ុល ពតបន្សល់ទុកយ៉ាងម៉េច សំរាប់អ្នកដែលនៅក្រោយនេះយ៉ាងម៉េច ប្រហែលជាគាត់ដឹងតិចដែរតាមមើល ហើយបើដឹងពិតទៅ គឺ សូម្បីតែយកផ្ទះហ្នឹង ដែលចូលមក៧៩ ហ្នឹង មិនហ៊ានដេកទេ ថ្ងៃយកផ្ទះ យកសម្បែងហ្នឹងមក យប់ឡើង ដឹងតែប្រមូលគ្នា ផ្តុំគ្នាដេក មនុស្សវា តិច ខ្លាច ថា ឥលូវយើងនេះអី ដើរសប្បាយអី មុននឹងខ្មែរក្រហម ចូលធ្វើសមាហរណកម្មមកនេះ ខ្ញុំ មក នៅនោះ ប្រពន្ធកូនខ្ញុំ ខ្ញុំមកលេងផ្ទះយប់ឡើង ខ្ញុំអត់ហ៊ានដេកទេ ហើយមកលេងធម្មតាជាមួយឪពុកម្តាយអញ្ចឹងទៅ ល្ងាចឡើងវិលទៅវិញ ព្រលឹមឡើងមកទៀត សំណាក់គេកើតៗ ដាក់ឆ្ងាយពីគ្នា អញ្ចឹងវា

ភារិទ្ធ៖ អានេះព្រំប្រទល់ចំ អានែ?

រ៉ាឌី៖ បាទ និយាយទៅ ចំហើយ ធ្លាប់ចូលមកលុកផ្ទះខ្ញុំហ្នឹង ប្រពន្ធកូន លុញកាត់ស្រែ កាត់ភក់អីអញ្ចឹងទៅ

ភារិទ្ធ៖ អានេះសឹងតែគ្រប់កន្លែង សូម្បី ខ្ញុំនៅ កំពង់ស្ពឺនៅណោះ ក៏ធ្លាប់មកវាយផ្ទះ

រ៉ាឌី៖ បាទ មកវាយ

ភារិទ្ធ៖ មិនហ៊ានដេកផ្ទះដែរហ្នឹងអា៎

រ៉ាឌី៖ យកកាំភ្លើងមួយដើមលើហ្នឹង កាលហ្នឹង វាពិបាកច្រើនអា៎ កាលហ្នឹង ប៉ុន្តែមកដល់ឥលូវ ឃើញស្ងប់ សប្បាយ អ៎ា មោ៉ង ៩ ១០ បន្តិចបា៉ខ្ញុំទៅលេងវត្តនេះ ថា អើ ទៅ ទៅ នាំគ្នាទៅ មើលទៅ ដូចថាគ្មានអារម្មណ៍ព្រួយអា៎ បើមុនគ្រាន់តែបុណ្យក៏មិនហ៊ានដែរ អឺ អានោះបោកគ្រាប់បែកគ្រឹងទៅ ប៉ះអាម៉េចអាណាអី

ភារិទ្ធ៖ មានតើកាលប៉ុល ពតហ្នឹង ខ្មែរប្រហមបោកគ្រាប់បែករត់ព្រាត

រ៉ាឌី៖ បាទ ឥលូវវាជារឿងធម្មតាដែលបានសប្បាយអញ្ចឹង ខ្ញុំ នាំគ្នា បន្តនិរន្តភាពអញ្ចឹងតគ្នា

តទៅទៀតទៅ

ភារិទ្ធៈ ចុងក្រោយខ្ញុំអរគុណបងច្រើនមែនទែនដែលបានចំណាយពេលវេលាបងដ៏មានតំលៃហើយ ដែលផ្តល់នូវការសម្ភាស ដែលខ្ញុំយល់ថា វាជាពត៌មានសំខាន់ សំរាប់នៅក្នុងការ ដែលបងជួយចែករំលែក បទពិសោធន៍របស់បងនៅក្នុងការចងក្រង ប្រវត្តិសាស្ត្ររបស់បង នៅក្នុងការ ដែលបងជួយចែករំលែក បទពិសោធន៍របស់បងនៅក្នុងការចងក្រងប្រវត្តិសាស្ត្រអោយក្មេងជំនាន់ក្រោយបានដឹង បានលឺដើម្បីទប់ស្កាត់ កុំអោយរបបហ្នឹង វិលមកវិញអញ្ចឹងអា៎ ហើយក៏ក្នុងជានេះមួយ នៅក្នុងការជុំញអោយមានការតុលាការកើតមាន អីអញ្ចឹងអា៎ អញ្ចឹងខ្ញុំអរគុណបងច្រើនមែនទែន

ភ៉ាឌីៈ បាទ